# ទស្សនាវដ្ដី ព្រៃឈើ ៦១



រដ្ឋបាលព្រៃឈើ

ឧសភា ២០២០

# មាតិកាអត្ថបទ

ល.រ ឈ្មោះអត្ថបទ | ទំព័រ


១- ព្រះរាជសុន្ទរកថា ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធី "រុក្ខទិវា" នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលដំរី ស្ថិតក្នុងភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ ........ ១

២- របាយការណ៍ ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធី "រុក្ខទិវា" ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលដំរី ភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ ........ ៥

៣- សកម្មភាព និងលទ្ធផលការងារប្រចាំឆ្នាំ២០១៩ របស់រដ្ឋបាលព្រៃឈើ ........ ១១

៤- ការសិក្សាស្រាវជ្រាវផលិតថង់បណ្តុះកូនឈើដែលផ្ទុកសារធាតុចិញ្ចឹម និងងាយស្រួលក្នុងធម្មជាតិ ........ ៥២

៥- ការផលិតកូនអាកាស្យាតាមរយៈការកាត់ត្រួយមែកអាកាស្យាបណ្តុះ ........ ៥៤

៦- រុក្ខជាតិឱសថ "អង្គាបុស្ស" ........ ៥៨

៧- អាថ៌កំបាំងរបស់សត្វឃ្មុំ ........ ៥៩

៨- វឌ្ឍនភាពនៃការសិក្សាស្រាវជ្រាវតាមដានអំពីហានិភ័យនៃជំងឺឆ្លងពីថនិកសត្វតូចៗ ប្រចៀវ និងជ្រូក មកមនុស្ស........ ៦៣

៩- កម្សាន្ត ........ ៦៨

១០- កំណាព្យ "កង្វល់ម្រឹគព្រៃ" ........ ៦៩



យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានជួយឧបត្ថម្ភ ផ្តល់នូវអត្ថបទ និងរូបភាពសម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តីរបស់យើងខ្ញុំៗ ទន្ទឹមនឹងនេះ យើងខ្ញុំសូមអំពាវនាវដល់ប្រិយមិត្តអ្នកអានទាំងអស់ សូមមេត្តាជួយជ្រោមជ្រែង ផ្តល់នូវមតិរិះគន់ស្ថាបនា ផ្តល់អត្ថបទមានអត្ថប្រយោជន៍ផ្សេងៗដើម្បីចុះផ្សាយក្នុងទស្សនាវដ្តីជាបន្តបន្ទាប់ទៀតៗ *(ទំនាក់ទំនងព័ត៌មាន-ផ្តល់អត្ថបទ* **077 98 17 98***)*

*សូមអរគុណ !*

*រដ្ឋបាលព្រៃឈើ*





អគារលេខ ៤០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ (កម្ពុជា)

E-mail : tech6777@gmail.com

Website: www.forestry.gov.kh




**ព្រះរាជសុន្ទរកថា**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**
ក្នុងពិធី **រុក្ខទិវា** នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលដំរី
ស្ថិតក្នុងភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ
**ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩**

- សូមក្រាបថ្វាយបង្គំព្រះតេជគុណ ព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ
- **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ
- **សម្តេចចៅហ្វាវាំង សម្តេចក្រឡាហោម** ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងប្រិយមិត្តបរទេស ជាទីមេត្រី
- ជនរួមជាតិ លោកតា លោកយាយ មាមីង បងប្អូន និងក្មួយៗទាំងអស់ ជាទីស្រឡាញ់ និងជាទីនឹករលឹកដ៏ជ្រាលជ្រៅបំផុត!

ថ្ងៃនេះ ខ្ញុំព្រះករុណា ខ្ញុំ មានហឫទ័យរីករាយឥតឧបមា ដោយបានមកចូលរួមពិធី **រុក្ខទិវា ៩កក្កដា** ដ៏ឧត្តុង្គឧត្តម នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលដំរី ស្ថិតក្នុងភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះដ៏ស្រស់បំព្រងនេះ ។

ជាបឋម ខ្ញុំព្រះករុណា ខ្ញុំ សូមពាំនាំមកនូវព្រះរាជបណ្ដាំផ្ញើពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នូវសេចក្តីសួរសុខទុក្ខ សេចក្តីនឹករឭក និងព្រះរាជទានពរបវរមហាប្រសើរ មកប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជូនសម្តេច ឯកឧត្តម លោកជំទាវ ប្រិយមិត្តបរទេសទាំងអស់ លោក លោកស្រី លោកតា លោកយាយ មាមីង ក្មួយៗ និងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបទៅដោយសេចក្តីសុខចម្រើន និងមានសុភមង្គលគ្រប់ប្រការ ។

ខ្ញុំព្រះករុណា ខ្ញុំ សូមអរគុណចំពោះឯកឧត្តមអភិបាលខេត្តក្រចេះ ដែលបានថ្លែងសុន្ទរកថាស្វាគមន៍យ៉ាងកក់ក្តៅ និងបានរៀបរាប់យ៉ាងក្បោះក្បាយអំពីសមិទ្ធផលជាច្រើន ដែលសម្រេចបានលើគ្រប់វិស័យនៅខេត្តក្រចេះ ដែលផ្តើមចេញពីកិច្ចខិតខំប្រឹងប្រែង និងការចូលរួមយ៉ាងសកម្មរបស់ព្រះសង្ឃ រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ផ្នែក និងបងប្អូនជនរួមជាតិទាំងអស់ ដើម្បីថែរក្សាសុខសន្តិភាព និងអភិវឌ្ឍខេត្តក្រចេះ ។

ទន្ទឹមនឹងនេះដែរ ខ្ញុំព្រះករុណា ខ្ញុំ សូមអរគុណឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានលើកឡើងអំពីសមិទ្ធផលនានាដែលសម្រេចបានជាផ្លែផ្កាក៏ដូចជាទស្សនវិស័យវែងឆ្ងាយក្នុងការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជាឱ្យមានលក្ខណៈទំនើប ។ ជាមួយនេះដែរ ខ្ញុំព្រះករុណា ខ្ញុំ សូមចូលរួមអបអរសាទរដែលព្រះរាជាណាចក្រកម្ពុជាយើង បានចូលជា **សមាជិកពេញសិទ្ធិនៃអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី និងអង្គការបណ្ដាញអន្តរជាតិសម្រាប់ឫស្សី និងផ្ដៅ ទី៤៤** នៅក្នុងឆ្នាំ២០១៩នេះ ដែលយើងនឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើន ។

- ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- សម្ដេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនជនរួមជាតិ ជាទីមេត្រី

ដូចបងប្អូនជនរួមជាតិបានជ្រាបរួចមកហើយថា ពិធី **រុក្ខទិវា** នេះ ត្រូវបានរៀបចំឡើងតាំង ពីសម័យ **សង្គមរាស្ត្រនិយម** ក្រោមព្រះរាជបូជនីយកិច្ចដឹកនាំដ៏ថ្លៃថ្លាបំផុតរបស់ **ព្រះករុណាព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។ ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលមាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានបន្តប្រារព្ធពិធី **រុក្ខទិវា** នៅតាមរាជធានី-ខេត្តទូទាំងប្រទេស ។ ប្រជាជនកម្ពុជាយើងបានយល់ប្រាកដណាស់ថាព្រៃឈើជាសម្បត្តិធម្មជាតិដ៏មហាសាល សម្រាប់ជីវិតមនុស្ស និងសត្វរស់នៅលើភពផែនដីយើងនេះ ។ ព្រៃឈើបានរួមចំណែករក្សាលំនឹងធម្មជាតិ និងចូលរួមអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ ទេសចរណ៍ ការសិក្សាស្រាវជ្រាវ ប្រព័ន្ធការពារដីនៅទីជម្រាល ប្រព័ន្ធការពារជីវៈចម្រុះជាដើម ។ ដូចនេះការបាត់បង់ព្រៃឈើ គ្រប់ប្រភេទ អាចបណ្ដាលឱ្យមានទឹកជំនន់ ខ្យល់កន្ត្រាក់ និងរន្ទះ និងការរាំងស្ងួតដែលបានធ្វើឱ្យទីតម្កល់ទឹកធានាសម្រាប់តម្រូវការរបស់មនុស្ស សត្វ ត្រូវរីងស្ងួត ឈានទៅរកការបាត់បង់ប្រាក់ចំណូល សត្វព្រៃ ធនធានមច្ឆជាតិគ្រប់ប្រភេទ ហើយអាចបង្កឱ្យមានភាពរហោស្ថាន និងការធ្លាក់ចុះគុណភាពដីផងដែរ ។

នាឱកាសនៃការប្រារព្ធពិធី **រុក្ខទិវា** ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវចំពោះព្រះសង្ឃ អាជ្ញាធរដែនដី និងបងប្អូនជនរួមជាតិនៅទូទាំងប្រទេសសូមព្រះមេត្តា និងមេត្តាដាំដើមឈើគ្រប់ប្រភេទ ក្នុងនោះក៏មានដើមត្នោតផងដែរ នៅតាមទីវត្តអារាម ទីសាធារណៈ និងរមណីយដ្ឋាន តាមដងផ្លូវលំ ផ្លូវជាតិ តាមដងប្រឡាយ ភូមិដ្ឋាននានា និងតាមភ្លឺស្រែចម្ការ ដើម្បីបានម្លប់ជាជម្រកមនុស្ស សត្វ បានជាឈើសំណង់ អុស ធ្យូង បង្កើនជីវជាតិដីកសិកម្ម ដើម្បីកាត់បន្ថយការប្រើប្រាស់ឈើធម្មជាតិ ជួយទប់កម្លាំងខ្យល់កន្ត្រាក់ និងបម្រែបម្រួលធាតុអាកាសផងដែរ ។ ជាពិសេសគួរយកចិត្តទុកដាក់រៀបចំដើម្បីឱ្យគូស្រករទើបរៀបអាពាហ៍ពិពាហ៍ ដាំដើមឈើទុកជាអនុស្សាវរីយ៍នៅសួនអាពាហ៍ពិពាហ៍ដែលបានបង្កើតឡើងដោយរដ្ឋបាលព្រៃឈើឱ្យបានគ្រប់ៗគ្នា នៅតាមទីប្រជុំជនស្រុក ក្រុង ឃុំ សង្កាត់ ភូមិ ។

ម្យ៉ាងទៀតសូមបងប្អូនជនរួមជាតិជួយទប់ស្កាត់ និងបញ្ឈប់ការកាប់ឈើ ការកាប់រាន ដុត ឈូសឆាយដីព្រៃ ការបរបាញ់-ការដាក់អន្ទាក់ចាប់សត្វព្រៃដោយខុសច្បាប់ ហើយចូលរួមថែរក្សា ការពារព្រៃឈើជាពិសេសការពារភ្លើងឆេះព្រៃ នៅតាមតំបន់ដែលបងប្អូនរស់នៅ ដើម្បីរក្សាការពារឱ្យបាននូវធនធានព្រៃឈើសម្រាប់កូនចៅរបស់យើងជំនាន់នេះ និងជំនាន់ក្រោយៗទៀត ។ ពិសេសត្រូវចូលរួមយកចិត្តទុកដាក់ធ្វើកសិកម្មចម្រុះនៅតាមសហគមន៍នីមួយៗ ទៅតាមសក្តានុពលដីប្រកបដោយភាពវៃឆ្លាត ដោយមិនពឹងអាស្រ័យទៅលើតែផល-អនុផលព្រៃឈើនោះឡើយ និងមានការចូលរួមជួយណែនាំបន្ថែមពីមន្ត្រីជំនាញបច្ចេកទេស ។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណា ខ្ញុំ សូមអរគុណដ៏ជ្រាលជ្រៅបំផុតចំពោះប្រទេសជាមិត្ត អង្គការជាតិ-អន្តរជាតិនានា ដែលបាននឹងកំពុងយកចិត្តទុកដាក់ចូលរួមជួយដល់ការងារដាំដើមឈើ ការថែរក្សា និងការពារធនធានព្រៃឈើ-សត្វព្រៃ ក៏ដូចជាចូលរួមក្នុងការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា ក្នុងពេលអតីតកាលនិងបច្ចុប្បន្ននេះ ហើយសូមមេត្តាជួយបន្តទៅមុខទៀត ដើម្បីសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ។

ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរព្រះគុណនិងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះព្រះសង្ឃគ្រប់ព្រះអង្គ រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលព្រៃឈើ ព្រមទាំងរដ្ឋបាលខេត្តក្រចេះ ដែលបានយកចិត្តទុកដាក់សហការយ៉ាងល្អប្រសើរជាមួយក្រសួងព្រះបរមរាជវាំង គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ រៀបចំពិធី **រុក្ខទិវា** ក្នុងខេត្តក្រចេះយើងនេះ ប្រកបដោយជោគជ័យ ។

ខ្ញុំព្រះករុណា ខ្ញុំ សូមឧទ្ទិសពិធី **រុក្ខទិវា** នេះស្ថិតក្នុងបេះដូងរបស់បងប្អូនជនរួមជាតិគ្រប់ៗរូប និងក្លាយជាប្រពៃណីនៃការរួមសាមគ្គីគ្នាដាំដើមឈើគ្រប់ប្រភេទ រួមគ្នាថែរក្សា និងការពារធនធានព្រៃឈើ-សត្វព្រៃដ៏មានតម្លៃរបស់យើងឱ្យបានគង់វង្សរហូតទៅ ។

ជាទីបញ្ចប់ ខ្ញុំ ព្រះករុណាខ្ញុំ សូមប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រិយមិត្តបរទេស លោកតា លោកយាយ មា មីង ក្មួយៗ និងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយព្រះពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ ៕

សូមអរព្រះគុណ និងសូមអរគុណ

៤


សូមថ្វាយព្រះពរបវរមហាប្រសើរ









**របាយការណ៍**
**ឯកឧត្តម វេង សាខុន**
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធី "រុក្ខទិវា"**
**ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ក្បាលដំរី**
**ភូមិស្រែគ្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ**
ថ្ងៃអង្គារ ៨កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹងថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩

ជាបឋម ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំបាទ :

- សូមក្រាបថ្វាយបង្គំព្រះតេជព្រះគុណ ព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមក្រាបថ្វាយបង្គំ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមគោរព :

- សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេចចៅហ្វាវាំង **គង់ សំអុល** វរៀងជ័យ អធិបតីស្រីង្គារ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ជាទីគោរព
- ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី ភ្ញៀវ កិត្តិយសជាតិ-អន្តរជាតិ និងបងប្អូនជនរួមជាតិទាំងអស់ ជាទីមេត្រី

ថ្ងៃនេះជាទិវាដ៏មហានក្ខត្តឫក្សដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយរដ្ឋបាលខេត្តក្រចេះ និងបងប្អូនជនរួមជាតិទាំងអស់ដែលមានវត្តមាននៅទីនេះ មានមហាកិត្តិយសដ៏ឧត្តុង្គឧត្តម និងមនោសញ្ចេតនារំភើបរីករាយជាអនេកប្បការ សូមព្រះរាជានុញ្ញាតសម្តែងនូវអភិវន្ទនាការ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះព្រះរាជវត្តមានដ៏ថ្លៃថ្លារបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យឆ្លៀតព្រះវរោកាសដ៏មានតម្លៃយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធី "**រុក្ខទិវា**" ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលដំរី ភូមិស្រែគ្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះដ៏ស្រស់ត្រកាលនេះ។ ព្រះរាជបេសកកម្មដ៏ឧត្តុង្គឧត្តមនេះពិតជាផ្តល់នូវមហាកិត្តិយសដ៏ធំធេង និងភាពកក់ក្តៅយ៉ាងក្រៃលែងសម្រាប់ប្រជារាស្ត្រខេត្តក្រចេះទាំងមូល ដែលតែងតែទន្ទឹងរង់ចាំចង់ឃើញព្រះភ័ក្ត្រ និងស្តាប់ព្រះសូរសៀងដោយផ្ទាល់របស់ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ហើយជាសក្ខីភាពយ៉ាងប្រត្យ័ក្សបង្ហាញអំពីព្រះទ័យយកចិត្តទុកដាក់ខ្ពស់បំផុត ចំពោះសម្បត្តិព្រៃឈើជាតិតាមគន្លងនៃព្រះរាជតម្រិះ និងព្រះរាជចក្ខុវិស័យដ៏ត្រចះត្រចង់របស់ **ព្រះវររាជបិតា ព្រះបរមរតនកោដ្ឋ** និង**ព្រះវររាជមាតា** របស់ព្រះអង្គដែលបានបង្កើតបុណ្យព្រៃឈើហៅ

1 -ទិវារុក្ខទិវា ៩កក្កដា- ២០១៩ នៅភូមិស្រែគ្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ

ថា"រុក្ខទិវា" នេះឡើងតាំងពីឆ្នាំ១៩៥២មកម្ល៉េះ។ ជាមួយនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមសម្ដែងនូវគារវកិច្ចដ៏ជ្រាលជ្រៅចំពោះ **សម្ដេចវិបុលសេនាភក្ដី សម្ដេចអគ្គមហាពញាចក្រី សម្ដេចអគ្គមហាសេនាបតីតេជោ សម្ដេចចៅហ្វាវាំង** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃអញ្ជើញចូលរួមជាកិត្តិយសដ៏ឧត្ដុង្គឧត្ដមបំផុត និងសូមថ្លែងអំណរគុណជាអនេកចំពោះវត្តមានរបស់ សម្ដេច ឯកឧត្ដម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្ដម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ និងបងប្អូនជនរួមជាតិទាំងអស់ដែលបានយាង និងអញ្ជើញមកចូលរួមយ៉ាងមហោឡារិក នៅក្នុងឱកាសប្រារព្ធ "រុក្ខទិវា" ដ៏វិសេសវិសាលនេះ។

ក្នុងបរិយាកាសដ៏មហាប្រសើរនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំបាទ សូមព្រះរាជានុញ្ញាត អនុញ្ញាតរំឭកឡើងវិញអំពីទស្សនវិស័យ និងព្រះរាជបញ្ញាញាណដ៏ភ្លឺស្វាងបំផុតរបស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គបានបំផុសចលនាដាំដើមឈើ ហៅថា "រុក្ខទិវា" នេះឡើងតាមរយៈព្រះរាជក្រឹត្យលេខ៧៣៨ នស.រកត ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៥២ ហើយព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យដឹកនាំកូនចៅដាំដើមឈើជារៀងរាល់ឆ្នាំ ក្នុងខណៈពេលដែលប្រទេសជាតិយើងសម្បូរព្រៃឈើនៅឡើយនាសម័យកាលនោះ។ មកដល់ពេលនេះមានរយៈពេល ៦៧ឆ្នាំហើយ ស្របពេលដែលសាកលលោកទាំងមូលកំពុងផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅលើការប្រែប្រួលអាកាសធាតុជាចម្បង។ ព្រះអង្គបានបណ្ដុះនូវស្មារតីដល់កូនចៅគ្រប់ៗរូបឱ្យយល់ដឹងអំពីបរិស្ថាន អត្ថប្រយោជន៍នៃព្រៃឈើ ហើយព្រះអង្គមានព្រះរាជបន្ទូលថា "**ការចូលរួមចំណែកការពារ និងថែរក្សាព្រៃឈើ ជាកាតព្វកិច្ចចាំបាច់របស់ពលរដ្ឋគ្រប់ៗរូប ហើយករណីយកិច្ចនេះ គឺតកូន តចៅ និងបានបង្កឱ្យអាកាសធាតុមានប្រក្រតីភាពជាវិជ្ជមាន ចំពោះវិស័យកសិកម្ម និងមនុស្សជាតិ**"។ ផ្អែកលើចក្ខុវិស័យដ៏ត្រចះត្រចង់នេះ និងដើម្បីបន្តស្នាព្រះហស្តដ៏ថ្លៃថ្លារបស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបង្កើតឡើងវិញ នូវ "**រុក្ខទិវា**" តាមសេចក្ដីសម្រេចលេខ ០៨ ស.ស.រ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលត្រូវប្រារព្ធឡើង នៅថ្ងៃទី៩ កក្កដា ហើយច្បាប់ស្ដីពីព្រៃឈើឆ្នាំ ២០០២ ក៏បានកំណត់ ទិវាពលកម្មដាំដើមឈើជាប្រពៃណីជាតិ ហៅថា "**រុក្ខទិវា**" នេះនៅថ្ងៃទី៩ កក្កដា ជារៀងរាល់ឆ្នាំ។

- **ព្រះតេជព្រះគុណ ព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ**
- **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**
- **អង្គពិធីទាំងមូល ជាទីមេត្រី**

បច្ចុប្បន្ននេះ វិស័យកសិកម្មជាវិស័យអាទិភាពមួយដែលបាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថា ការបង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ការគ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍវារីវប្បកម្ម ការគ្រប់គ្រងនិងអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ ព្រមទាំងការពង្រឹងសេវាគាំទ្រនិងអភិវឌ្ឍធនធានមនុស្ស គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីប្រែក្លាយ "*កសិកម្មកម្ពុជា ជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ ប្រកបដោយវិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា*"។ បច្ចុប្បន្ននេះ សេដ្ឋកិច្ចជាតិបានរីកចំរើនធាត់យ៉ាងឆាប់រហ័ស ហើយរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាក៏កំពុងផ្លាស់ប្ដូរពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្មទៅជាប្រទេសដែលពឹងផ្អែកជាសំខាន់លើវិស័យឧស្សាហកម្ម និងសេវាកម្មវិញ ហើយកសិករយើងកំពុងប្រែក្លាយខ្លួនចេញពី "**កសិករ**" ទៅជា "**កសិ-ពាណិជ្ជករ**" ដើម្បីទទួលបានតម្លៃ

2 "ទិវារុក្ខទិវា ៩កក្កដា" ២០១៩ នៅភូមិស្រែគ្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ

បន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួនដោយសារចរន្តនៃការរីកចម្រើនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលត្រូវបានគេហៅថា "បដិវត្តន៍ឧស្សាហកម្មទី៤ និងឌីជីថលភាវូបនីយកម្ម"។ តាមការវាយតម្លៃពីអង្គសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាខែមីនាឆ្នាំ២០១៩ កន្លងមកនេះ បានបង្ហាញថា វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ២៣,៥% នៃផលិតផលក្នុងស្រុកសរុប ក្នុងនោះ ផ្នែកដំណាំបានចូលរួម ៥៨,១% ផ្នែកផលិតកម្មសត្វ ១១,២% ផ្នែកជលផល ២៤% និងផ្នែកព្រៃឈើ ៦,៧%។ ម្យ៉ាងទៀត ដំណើរការវិវឌ្ឍន៍នៃយន្តូបនីយកម្មកសិកម្មកំពុងមាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់។ ជាក់ស្តែង ការភ្ជួររាស់ដាំដុះដំណាំស្រូវវស្សាដោយគ្រឿងយន្តកសិកម្មមាន ៩៦,៨៦% ដែលជាកត្តាមួយជួយសម្រួលដល់ការធ្លាក់ចុះនៃកម្លាំងពលកម្មនៅជនបទធៀបនឹងកម្លាំងពលកម្មសរុប រីឯការប្រើប្រាស់កម្លាំងគោ-ក្របីមាន៣,២%។ មកទល់ពេលនេះ ល្បឿនការងារបង្កបង្កើនផលដំណាំរដូវវស្សាមានសភាពយឺតជាងឆ្នាំមុនបន្តិច ដោយសម្រេចបាន ៤៩,៦៥% លើផ្ទៃដីសរុប ២ ៥៨៦ ១៥២ ហិកតា (ឆ្នាំមុនសម្រេចបាន៥៩,៤៦%) នៃផែនការដាំដុះបើប្រៀបធៀបរយៈពេលដូចគ្នា ដោយសារនៅដើមរដូវវស្សាឆ្នាំនេះទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងឆ្នាំមុនដោយកត្តាប្រែប្រួលធាតុអាកាស។ រីឯការនាំចេញកសិផលផ្សេងៗទៀតក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ បើប្រៀបធៀបរយៈពេលដូចគ្នានឹងឆ្នាំមុន។

ដោយឡែក ក្នុងឆ្នាំ២០១៨នេះ រដ្ឋបាលព្រៃឈើដែលជាអង្គភាពជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានខិតខំយកចិត្តទុកដាក់អនុវត្តលើសកម្មភាពការងារជាច្រើន ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់ រួមមានការអភិវឌ្ឍសហគមន៍ព្រៃឈើ ដែលគិតមកទល់ពេលនេះ បានកើនដល់ ៦១៤ សហគមន៍ គ្របដណ្តប់លើផ្ទៃដីសរុបទំហំជាង ៥០៨ពាន់ហិកតា បណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន ៦៦៧ពាន់ដើម ចែកចាយជូនប្រជាជនសរុបចំនួន ៤២២ពាន់ដើម ដាំដើមឈើជាចម្ការថ្មីលើផ្ទៃដីសរុបទំហំ ៣៤៣ ហ.ត ជីកប្រឡាយការពារចម្ការឈើដាំគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូងក្នុងខេត្តកំពង់ធំ ព្រមទាំងបានបំពេញទម្រង់បែបបទសុំចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន៣៨ទីតាំង លើផ្ទៃដីទំហំជាង ២១២ ពាន់ហិកតា។ ទន្ទឹមនឹងនេះ អង្គភាពជំនាញកំពុងខិតខំជំរុញសហគមន៍ទាំងនោះឱ្យងាកមកធ្វើកសិកម្មចម្រុះទៅតាមស្ថានភាពជាក់ស្តែង ដោយមិនត្រូវទុកដីចោលទំនេរ និងពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើ ឬការកាប់ឈើខុសច្បាប់ដើម្បីជីវភាពប្រចាំថ្ងៃនោះឡើយ។

ម្យ៉ាងទៀត រដ្ឋបាលព្រៃឈើបានសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់ និងបានបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ ការកាប់រានដីព្រៃខុសច្បាប់សរុបចំនួន១ ០៩៣ករណីគឺថយចុះ៣៣៥ករណី បើប្រៀបធៀបឆ្នាំ២០១៧ ក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរ-ការណ៍ ចំនួន ៥៨២ករណី បញ្ជូនទៅតុលាការចំនួន ៥១១ករណី។ ទន្ទឹមនឹងនេះ បានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ លិខិតបទដ្ឋាននានាដល់អ្នកពាក់ព័ន្ធ ព្រមទាំងចុះពង្រឹងការអនុវត្តច្បាប់យ៉ាងសកម្មផងដែរ។ ចំពោះការងារកែទម្រង់ផ្នែកគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ក្រសួងបានធ្វើការណែនាំអនុវត្តនូវចំណុចគន្លឹះមួយចំនួនតាមរយៈវេទិកាសាធារណៈ ដើម្បីបន្តនិរន្តរភាពលើការគ្រប់គ្រង និងអភិវឌ្ឍដីសម្បទានសេដ្ឋកិច្ចក៏ដូចជាវិស័យកសិកម្មទាំងមូលប្រកបដោយប្រសិទ្ធភាពខ្ពស់។ ជាមួយនេះ យើងបានសហការយ៉ាងល្អប្រសើរជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា ព្រមទាំងបានចូលរួមជាមួយគណៈកម្មាធិការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិយ៉ាងសកម្ម ។ ពិសេសបានរៀបចំ "រុក្ខទិវា ០៩ កក្កដា" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៅស្រុកទឹកឈូ ខេត្តកំពតផងដែរ។ ម្យ៉ាងទៀត ជារៀងរាល់ឆ្នាំនៅថ្ងៃទី១៧ ខែមិថុនា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែងតែសហការរៀបចំទិវាពិភពលោក ដើម្បីប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម ឬការធ្លាក់ចុះគុណភាពដីដែលឆ្នាំនេះបានប្រារព្ធធ្វើនៅខេត្តកំពត និងមានសមាសភាពចូលរួមប្រមាណ១ ០០០នាក់ ដើម្បី

3 "ទិវារុក្ខទិវា ៩កក្កដា" ២០១៩ នៅភូមិស្រែគ្រេង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ

បំផុសចលនាដល់ប្រជាពលរដ្ឋឲ្យចូលរួមដាំដើមឈើឱ្យបានសស្រាក់សស្រាំផងដែរ ឆ្លើយតបទៅនឹងកម្មវិធីសកម្មភាពជាតិប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី ដែលត្រូវបានរាជរដ្ឋាភិបាលអនុម័តកាលពីដើមខែមេសា ឆ្នាំ២០១៨ កន្លងមកនេះ ព្រមទាំងមានការអនុម័តគាំទ្រលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCo) និងការចូលជាសមាជិកនៃអង្គការបណ្តាញអន្តរជាតិសម្រាប់ឫស្សី និងផ្តៅ (INBAR) ដែលត្រូវបានរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា អនុម័តនាពេលថ្មីៗនេះ។

ជារួម ជាមួយនឹងសមិទ្ធផលដែលសម្រេចបានដូចបានរៀបរាប់ខាងលើ វិស័យកសិកម្មក៏នៅជួបបញ្ហាប្រឈមមួយចំនួនដែលជាក្តីកង្វល់ក្នុងការអភិវឌ្ឍវិស័យនេះមានជាអាទិ៍៖ ផលិតភាពនៃផលិតកម្មដំណាំកសិកម្មនៅទាបនៅឡើយ ការធ្វើពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មនៅមានកម្រិត កង្វះការវិនិយោគលើការកែច្នៃ គុណភាពកសិផលនៅទាបមិនទាន់ឆ្លើយតបតាមតម្រូវការទីផ្សារ ថ្លៃដើមផលិតកម្មខ្ពស់ពិបាកប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូល។ ការងារស្រាវជ្រាវ និងសេវាផ្សព្វផ្សាយកសិកម្ម មិនទាន់បានទូលំទូលាយ ប្រព័ន្ធស្រោចស្រពដីចម្ការនិងកសិដ្ឋានដែលនៅឆ្ងាយមិនទាន់គ្រប់គ្រាន់។ ការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្មឱ្យចំគោលដៅ និងសក្តានុពលភាពនៅតាមភូមិសាស្ត្រនីមួយៗ ស្ថិតនៅតែជាបញ្ហា។ ការទប់ស្កាត់បទល្មើសព្រៃឈើ ជលផល ការនាំចូលសត្វ និងសម្ភារកសិកម្មខុសច្បាប់ រួមទាំងការត្រួតពិនិត្យ អនាម័យនិងភូតគាមអនាម័យនៅមានកម្រិត ពិសេសខេត្តនៅជាប់ព្រំដែន។ សកម្មភាពកាប់រានហ៊ុមព័ទ្ធដីព្រៃឈើ ព្រៃលិចទឹក ដោយខុសច្បាប់ នៅតែកើតមានរហូតមកទល់បច្ចុប្បន្ននេះ។ល។

ទោះជាយ៉ាងណា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំដោះស្រាយនូវមូលបញ្ហាខាងលើនេះ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។ ជាមួយនេះ ខ្ញុំព្រះករុណាខ្ញុំបាទ សូមថ្លែងអំណរគុណ និងសូមអំពាវនាវ ដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងគ្រប់ដៃគូពាក់ព័ន្ធទាំងអស់តាមអភិក្រម **"រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍-សហគមន៍"** មេត្តាយកចិត្តទុកដាក់ចូលរួមដោះស្រាយនូវក្តីកង្វល់ខាងលើនេះ តាមភារកិច្ចដើម្បីផ្តល់ភាពកក់ក្តៅដល់ប្រជាកសិករយើង ព្រមទាំងត្រូវចូលរួមទប់ស្កាត់ការកាប់រាន ដុត ឈូសឆាយហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើជាកម្មសិទ្ធិដោយខុសច្បាប់ក៏ដូចជាបទល្មើសផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយភាពម្ចាស់ការ និងចូលរួមដាំដើមឈើឡើងវិញគ្រប់ទីកន្លែងឱ្យបានផុសផុល ជួយគាំទ្រលើការស្តារ និងអភិវឌ្ឍវិស័យព្រៃឈើ និងសត្វព្រៃនៅកម្ពុជា តាមព្រះរាជតម្រិះដ៏ភ្លឺស្វាងរបស់**ព្រះករុណាព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ** ដើម្បីបង្កើនធនធានឈើប្រើប្រាស់ និងចូលរួមកាត់បន្ថយការឡើងកម្តៅនៅភពផែនដី ការប្រែប្រួលអាកាសធាតុនៅក្នុងដំណាក់កាលអន្តរកាលនេះក៏ដូចជាការថែរក្សាធនធានធម្មជាតិ និងអភិរក្សជីវៈចម្រុះដ៏មានតម្លៃដើម្បីជាប្រយោជន៍ជាតិប្រកបដោយបរិយាប័ន្ន ភាតរបរិស្ថានសម្រាប់អនាគតកូនចៅជំនាន់ក្រោយៗទៀត។ ពិសេសវិស័យកសិកម្មទាំងមូលដើម្បីផលប្រយោជន៍របស់ប្រជាសហគមន៍ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៅជនបទឱ្យបានល្អប្រសើរ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំបាទ សូមពិតពុទ្ធដីកាព្រះថេរានុត្ថេរៈសូមបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ និងជម្រាបជូនអង្គពិធីទាំងមូលមេត្តាជ្រាបថា ទីតាំងប្រារព្ធពិធីរុក្ខទិវានេះ ជាអតីតដីក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចដែលត្រូវបានរាជរដ្ឋាភិបាលនិរាករណ៍ ហើយរដ្ឋបាលព្រៃឈើក៏បានរៀបចំបង្កើតជាស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើនេះឡើង តាមរយៈប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលេខ២៦៧ប្រក.កសក ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៧ ក្នុងគោលបំណងដាំស្តារព្រៃឈើឡើងវិញ អភិវឌ្ឍន៍ចំណេះដឹងបច្ចេកទេសដាំឈើ បំផុសការចូលរួមដាំឈើដើម្បីទប់ស្កាត់ការហូរច្រោះដីជាតិដី កែលម្អគុណភាពដី អភិវឌ្ឍន៍ជីវៈចម្រុះ ចូលរួមចំណែកកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើភពផែនដី ទប់ស្កាត់ការប្រែប្រួលអាកាសធាតុ និងទ្រទ្រង់សកម្មភាពផ្សេងៗទៀតជាច្រើនសម្រាប់ផលប្រយោជន៍របស់ប្រជាសហគមន៍។ រីឯ

ផ្ទៃដីប្រារព្ធ "**រុក្ខទិវា**" នាពេលនេះមានទំហំ ១០ហិកតា នៃផ្ទៃដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលដំរី ទំហំ ៩៨៧ហិកតា ហើយកូនឈើដែលត្រូវយកមកដាំ រួមមាន ឈើគ្រញូង ធ្នង់ កកោះ អង្កាញ់ សរុបចំនួន ១៣ ៦០០ដើម។

- **ព្រះតេជព្រះគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ**
- **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**
- **អង្គពិធីទាំងមូល ជាទីមេត្រី**

ជាថ្មីម្តងទៀត តាងនាមឱ្យថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងរដ្ឋបាលខេត្តក្រចេះ និងបងប្អូនជនរួមជាតិទាំងអស់ដែលមានវត្តមាននៅទីនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតដែលព្រះអង្គបានសព្វព្រះរាជហឫទ័យយាងចូលរួមក្នុងឱកាស "**រុក្ខទិវា**" ជាប្រវត្តិសាស្ត្រ នៅលើទឹកដីខេត្តក្រចេះ ដ៏ស្រស់ត្រកាលនេះ។ ជាមួយនេះដែរ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ វិស័យឯកជន និងបងប្អូនជនរួមជាតិទាំងអស់ ដែលបានចូលរួម យ៉ាងសស្រាក់សស្រាំក្នុងព្រឹត្តិការណ៍ដ៏មានអត្ថន័យនេះ និងសូមថ្លែងអំណរគុណជាអនេកកប្បការចំពោះ **សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីវង្គារ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងសហការី** ព្រមទាំងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ដែលបានផ្តល់កិច្ចសហការយ៉ាងកក់ក្តៅក្នុងការរៀបចំពិធី "**រុក្ខទិវា**" នេះឱ្យប្រព្រឹត្តទៅយ៉ាងឱឡារិកក្នុងបរិយាកាសរីករាយ និងមោទនភាពយ៉ាងក្រៃលែង។

ជាទីបញ្ចប់ ជាមួយនឹងមនោសញ្ចេតនាអបអរសាទរ "**រុក្ខទិវា**" នាពេលនេះ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំបាទ សូមលំឱនកាយវាចាចិត្តគោរពបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ពិសេសទេវតារក្សាព្រះមហាស្វេតច្ឆ័ត្រ និងព្រះរាជបល្ល័ង្គ ព្រះបារមីអតីតព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ **ព្រះបរមរតនកោដ្ឋ** ព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ សូមតាមជួយប្រោះព្រំបីបាច់ថែរក្សា **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះស្រីលោកធម្មិករាជ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទាំងទ្វេមានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា និងព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិជាម្លប់ដ៏ត្រជាក់ត្រជុំ សុខដុមរមនារបស់ប្រជារាស្ត្រព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។ សូមប្រគេនពរជ័យ សិរីមង្គល ចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមគោរពជូនពរបវរមហាប្រសើរជូនចំពោះ សម្តេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមទទួលនូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរព្រះគុណ និងសូមអរគុណ**!

5 -ទិវារុក្ខទិវា ៩កក្កដា- ២០១៩ នៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ

## រូបភាពសកម្មភាពពិនិត្យ និងរៀបចំទីតាំងប្រារព្ធពិធី "រុក្ខទិវា"

### នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលដំរី ភូមិស្រែគ្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ

### ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩

















# សកម្មភាព និងលទ្ធផលការងារ ប្រចាំឆ្នាំ២០១៩ របស់រដ្ឋបាលព្រៃឈើ

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលបានកំណត់គោលដៅជាយុទ្ធសាស្ត្រក្នុងការកែទម្រង់វិស័យព្រៃឈើ គឺការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព រួមជាមួយប្រព័ន្ធការពារធនធានធម្មជាតិ និងការអនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើប្រកបដោយប្រសិទ្ធភាពសំដៅចូលរួមអភិវឌ្ឍសេដ្ឋកិច្ច សង្គម កាត់បន្ថយភាពក្រីក្រ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការកើនឡើងកម្តៅនៃភពផែនដី។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ រដ្ឋបាលព្រៃឈើ ដែលជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ និងអង្គការអន្តរជាតិជាដៃគូអភិវឌ្ឍន៍នានា បំពេញតួនាទីភារកិច្ចទៅតាមអាណត្តិរបស់ខ្លួន ដោយសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ដូចខាងក្រោម ៖

## ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

ក្នុងឆ្នាំ២០១៩នេះ រដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់បានសហការជាមួយកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរដែនដី និងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត ក្នុងទូទាំងប្រទេសធ្វើការបង្ក្រាបបទល្មើសព្រៃឈើ-សត្វព្រៃ និងបទល្មើសកាប់រានដីព្រៃ ដោយទទួលបាននូវលទ្ធផលវិជ្ជមាន។

-សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន**១២០១**ករណី ដែលក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន**៥៩៨**ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន**៦០៣**ករណី។

ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងសរុបចំនួន **៣៩៧**ម៉ែត្រគ្រីគុណ ឈើអារសរុបចំនួន**២៩៦៧**ម៉ែត្រគ្រីគុណ ឈើគ្រាក់គ្រញូង**២**ម៉ែត្រគ្រីគុណ សត្វព្រៃចម្រុះប្រភេទសរុបចំនួន**៤៤៨១**ក្បាល **និង៨៧៦**,**៨០**គីឡូក្រាម ផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ**១៧៧៣**ហិកតា(ចំនួន**៧២**ករណី៖ ខេត្តកំពង់ឆ្នាំង១៧ករណី ក្រចេះ១៥ករណី ព្រះវិហារ ០៩ករណី ស្ទឹងត្រែង០៧ករណី រតនគិរី០៧ករណី មណ្ឌលគិរី០៧ករណី កំពង់ស្ពឺ០៤ករណី ព្រះសីហនុ ០៤ករណី ពោធិ៍សាត់០១ករណី និងខេត្តបាត់ដំបង ០១ករណី) និងអនុផលព្រៃឈើព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត។

-បានធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃ តាមរយៈសាលក្រម និងដីកាសម្រេចរបស់សាលាដំបូងខេត្តព្រះវិហារចំនួន៤៣ករណី និងបង់ពិន័យដោយតុលាការសរុបចំនួន១៥ករណី ក្នុងនោះមានខណ្ឌរដ្ឋបាលព្រៃឈើកំពង់ស្ពឺចំនួន០៣ករណី កំពង់ចាមចំនួន ០៣ករណី រតនគិរីចំនួន០១ករណី បាត់ដំបងចំនួន០១ករណី និងខណ្ឌរដ្ឋបាលព្រៃឈើក្រចេះចំនួន១៤ករណី។

- បានណែនាំ និងកែលំអសំណុំរឿងបទល្មើសព្រៃឈើដល់រដ្ឋបាលព្រៃឈើមូលដ្ឋានចំនួន០៧ករណី។





សកម្មភាពចុះល្បាតសហគមន៍ព្រៃឈើភ្នំដងរែកសំរែកព្រៃស្រស់





សកម្មភាពរបស់ក្រុមការងារឃាត់ចាប់រថយន្តកូរ៉េ០១គ្រឿង ដឹកឈើប្រភេទក្រៅលំដាប់(ពពេលខែ) ចំនួន១៦៦សន្លឹក ស្មើនឹង ២ម៉ែត្រគ្រីគុណ៩៨០ នៅត្រង់ចំណុចភូមិត្រពាំងចាន់ ឃុំត្រពាំងចាន់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង





សកម្មភាពស្រាវជ្រាវរកបទល្មើសព្រៃឈើក្នុងដែនសហគមន៍ព្រៃឈើភ្នំឆ្កែលូ ដែលស្ថិតនៅក្នុងភូមិសាស្ត្រ ភូមិក្រពើ ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប

## ផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបែបបទបច្ចេកទេសច្បាប់ពាក់ព័ន្ធព្រៃឈើ

បានផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធព្រៃឈើចំនួន៣៨លើក ក្នុងខេត្តចំនួន១៦ គឺ ខេត្តកំពង់ស្ពឺចំនួន០៣លើក កោះកុងចំនួន០១លើក កែបចំនួន០១លើក បន្ទាយមានជ័យចំនួន០៣លើក ឧត្តរមានជ័យចំនួន០៤លើក ក្រចេះចំនួន០២លើក មណ្ឌលគិរីចំនួន០២លើក កំពតចំនួន០២លើក តាកែវចំនួន០២លើក ស្ទឹងត្រែងចំនួន០៣លើក រតនគិរីចំនួន០១លើក កំពង់ឆ្នាំងចំនួន០៤លើក ពោធិ៍សាត់ចំនួន០២លើក សៀមរាបចំនួន០២លើក ព្រះវិហារចំនួន០៣លើក និងខេត្តកំពង់ធំចំនួន០៣លើក ដែលមានអ្នកចូលរួមសរុបចំនួន១ ៤៦៣នាក់(ស្រី៥៦៦នាក់) និងចែកឯកសារចំនួន៨៣០ច្បាប់។





សកម្មភាពចុះផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបែបបទបច្ចេកទេសច្បាប់ពាក់ព័ន្ធព្រៃឈើនៅសហគមន៍កូនខ្លែង ស្ថិតក្នុងឃុំប៉ោយចារ្យ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ





សកម្មភាពចុះផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ លិខិតបទដ្ឋានគតិយុត្ត និងបែបបទបច្ចេកទេសច្បាប់ពាក់ព័ន្ធព្រៃឈើ នៅសហគមន៍ព្រៃឈើចំរើន ស្ថិតនៅភូមិឆក់ ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ

## ស្រង់ព័ត៌មានព្រៃឈើពីសារព័ត៌មាន និងស្រាវជ្រាវផ្ទៀងផ្ទាត់ព័ត៌មាននិងចាត់វិធានការតាមនីតិវិធីនៃច្បាប់

ស្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យព្រៃឈើក្នុងបណ្តាញសារព័ត៌មាននានាបានចំនួន **១ ១៣៨**ករណី ដែលមានកម្ពុជាថ្មីចំនួន**១៣៨**ករណី រស្មីកម្ពុជាចំនួន**១៦៦**ករណី កោះសន្តិភាពចំនួន**១៦១**ករណី ភ្នំពេញប៉ុស្តិ៍ចំនួន**១២២**ករណី នគរវត្តចំនួន**៣៨៥**ករណី និងនគរធំចំនួន**១៦៦**ករណី ក្នុងនោះអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គមានចំនួន**៥០៨**ករណី អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាបមានចំនួន**២៥១**ករណី អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាបមានចំនួន**៣៤៩**ករណី

និងអធិការដ្ឋានរដ្ឋបាលព្រៃឈើឈូងសមុទ្រមានចំនួន **៣០**ករណី។ អត្ថបទដែលចុះផ្សាយពីរដ្ឋបាលព្រៃឈើចំនួន**២៩១**ករណី មានអត្ថបទសកម្ម(ស្នាដៃ) ចំនួន**១២៤**ករណី អត្ថបទអសកម្មចំនួន**១៦៧**ករណី និងអាជ្ញាធរពាក់ព័ន្ធចំនួន**៨៤៧**ករណី មានអត្ថបទសកម្ម(ស្នាដៃ) ចំនួន**៥៩១**ករណី អត្ថបទអសកម្មចំនួន**២៥៦**ករណី ក្នុងនោះចុះស្ទួនចំនួន**៤៨២**ករណី។ អត្ថបទសារព័ត៌មានដែលបានចុះផ្សាយពាក់ព័ន្ធនឹងបញ្ហាព្រៃឈើ សត្វព្រៃ និងដីព្រៃឈើទាំងអស់ត្រូវបានរក្សាទុកជាឯកសារ និងបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ព្រមទាំងផ្ទៀងផ្ទាត់ឲ្យមានសុក្រឹតភាព។



ផ្ទៀងផ្ទាត់សំណុំរឿងបទល្មើសនៅខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង



កិច្ចប្រជុំនៅខណ្ឌរដ្ឋបាលព្រៃឈើព្រៃវែង ស្តីការបំភ្លឺ
លើការចុះផ្សាយពីបទល្មើសព្រៃឈើរបស់សារព័ត៌មាន



ពិនិត្យវត្ថុតាងរក្សាទុកនៅផ្នែករដ្ឋបាលព្រៃឈើកំពង់ថ្ម



កិច្ចប្រជុំនៅខណ្ឌរដ្ឋបាលព្រៃឈើឧត្តរមានជ័យ ស្តីការបំភ្លឺ
លើការចុះផ្សាយពីបទល្មើសព្រៃឈើរបស់សារព័ត៌មាន



ពិនិត្យវត្ថុតាងរក្សាទុកនៅសង្កាត់រដ្ឋបាលព្រៃឈើព្រះរំកិល

# ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ និង សហគមន៍ព្រៃឈើ

## ១-ការវាយតម្លៃគម្របព្រៃឈើ និងទិដ្ឋភាព

-បានបញ្ចប់ការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៨ ជាលទ្ធផលផ្ទៃដីគម្របព្រៃឈើសរុប៨ ៥២៩ ៣៧២ហិកតា ស្មើនឹង ៤៦,៩៧% នៃផ្ទៃដីសរុបទូទាំងប្រទេស និងផ្ទៃដីគ្មានគម្របព្រៃឈើសរុប ៩ ៦៣១ ៣០២ហិកតា ស្មើនឹង ៥៣,០៣% នៃផ្ទៃដីសរុបទូទាំងប្រទេស




-បានទាញយករូបភាពផ្កាយរណប(Landsat8) ឆ្នាំ២០១៩ បានចំនួន១២ផ្ទាំង សម្រាប់ការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០



រូបភាពផ្កាយរណប(Landsat8) ឆ្នាំ២០១៩

-បានចុះបណ្តុះបណ្តាលបង្កើនសមត្ថភាពបច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) និងប្រព័ន្ធកំណត់ទីតាំងលើផែនដី(GPS) ជូនមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើកំពង់ស្ពឺ ត្បូងឃ្មុំ ប៉ៃលិន បន្ទាយមានជ័យ និងតាកែវ ដែលមានមន្ត្រីចូលរួមសរុបចំនួន ៧៩រូប។



វគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពបច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) និងប្រព័ន្ធកំណត់ទីតាំងលើ ផែនដី(GPS)

## ២-សហគមន៍ព្រៃឈើ

### ក-ការបង្កើត និងការគ្រប់គ្រងព្រៃសហគមន៍

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្តីប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ១០សហគមន៍ លើផ្ទៃដី ៥.៥១៣ហិកតា ស្ថិតនៅក្នុងខេត្តបាត់ដំបង

-បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ១២កន្លែង មានផ្ទៃដីសរុបទំហំ ៧ ៥០១ហិកតា៤៩ ក្នុងខេត្តចំនួន ០៣ មានខេត្តមណ្ឌលគិរី ចំនួន ០១កន្លែង លើផ្ទៃដីទំហំ ១ ១០៤ ហិកតា ខេត្តបាត់ដំបង ចំនួន ១០កន្លែង លើផ្ទៃដីទំហំ ៦ ០៧៤ហិកតា៤៩ និងខេត្តកោះកុង ចំនួន ០១កន្លែង លើផ្ទៃដីទំហំ ៣២៣ហិកតា

-បានទទួលសេចក្តីយល់ព្រមជាគោលការណ៍ពីរដ្ឋបាលព្រៃឈើ លើផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ០៩កន្លែង លើផ្ទៃដីសរុបទំហំ ៨២៦៨ហិកតា៦២ ក្នុងនោះខេត្តកំពង់ធំចំនួន០៣កន្លែង លើផ្ទៃដីទំហំ១០៦៨ហិកតា១៤ ខេត្តក្រចេះចំនួន ០២កន្លែង លើផ្ទៃដីទំហំ ១ ២៧៦ហិកតា ខេត្តរតនគិរីចំនួន ០១កន្លែង លើផ្ទៃដីទំហំ ២ ៣៣០ហិកតា និងខេត្តស្ទឹងត្រែងចំនួន០៣កន្លែង លើផ្ទៃដីទំហំ ៣ ៥៩៤ហិកតា៤៨។





ពិធីចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ខេត្តកោះកុង

**ខ-ការបង្កើនជីវភាព និងផ្តល់សេវាកម្មដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ**

-បានលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋ ក្នុងសហគមន៍ព្រៃឈើ តាមរយៈការអនុវត្តប្រព័ន្ធកសិ-រុក្ខកម្មសហគមន៍ព្រៃឈើគោលដៅចំនួន ០៥កន្លែង រួមមានសហគមន៍ព្រៃឈើភ្នំធំចំណងសាមគ្គី និងសហគមន៍ព្រៃឈើខ្លាខាំប៉ែន ស្ថិតនៅឃុំតាកែន ស្រុកឈូក សហគមន៍ព្រៃឈើព្រៃខ្មៅ សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ភូមិដំណាក់ស្នួល និងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ភូមិត្បែងពក ស្ថិតនៅក្នុងឃុំស្រែក្នុង ស្រុកជុំគិរី ខេត្តកំពត



តំបន់កសិ-រុក្ខកម្ម សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន



ដំណាំកសិ-រុក្ខកម្ម សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

-បានចុះផ្សព្វផ្សាយពង្រឹងយន្តការដោះស្រាយទំនាស់ក្នុងសហគមន៍ព្រៃឈើចំនួន ២០កន្លែង នៅក្នុងខេត្តចំនួន ១០រួមមាន ខេត្តកំពង់ធំ សៀមរាប ក្រចេះ ស្ទឹងត្រែង កំពង់ស្ពឺ កំពត កំពង់ឆ្នាំង ពោធិ៍សាត់ កែប និងខេត្តតាកែវ មានអ្នកចូលរួមសរុបចំនួន ៦៣១នាក់(ស្ត្រី ២៩៤នាក់)



សកម្មភាពចុះផ្សព្វផ្សាយពង្រឹងយន្តការដោះស្រាយទំនាស់ក្នុងសហគមន៍ព្រៃឈើមូលដ្ឋាន

-បានចុះតាមដានត្រួតពិនិត្យការងារសហគមន៍ព្រៃឈើចំនួន៦០កន្លែង ក្នុងខេត្តចំនួន១០ មានខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបង កំពង់ធំ កំពត ក្រចេះ ស្ទឹងត្រែង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ មានអ្នកចូលរួមសរុបចំនួន ១ ៦៩២នាក់(ស្ត្រី៦១៦នាក់)



សកម្មភាពចុះតាមដានត្រួតពិនិត្យការងារ
ក្នុងសហគមន៍ព្រៃឈើមូលដ្ឋាន

-បានចុះកំណត់ផ្ទៃដីព្រៃសហគមន៍ត្រូវដាំស្តារឡើងវិញនៅក្នុងសហគមន៍ព្រៃឈើចំនួន ១៦កន្លែង ក្នុងខេត្តចំនួន ០៨ មានខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ធំ កំពង់ស្ពឺ កំពង់ឆ្នាំង បន្ទាយមានជ័យ កំពត និងខេត្តក្រចេះ។



សកម្មភាពចុះកំណត់ផ្ទៃដីព្រៃសហគមន៍ត្រូវដាំដើមឈើស្តារ
ឡើងវិញក្នុងសហគមន៍ព្រៃឈើមូលដ្ឋាន

**៣-ការគ្រប់គ្រងផល អនុផលព្រៃឈើ**

**ក-ការចុះបញ្ជិកា ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្ត**

បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ៧១គ្រឿង និងយានយន្តចំនួន ១០៧គ្រឿង ជូនក្រុមហ៊ុនចំនួន ០៦ និងអ្នកស្នើសុំចំនួន ០៣នាក់។

**ខ-ការផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ**

បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ១៣ និងអ្នកស្នើសុំចំនួន ៥ ដែលមានឈើហ៊ុបមូលចំនួន៣៣ ១០៣ម៉ែត្រត្រីគុណ ឈើអារចំនួន ៤ ១៨៤ម៉ែត្រត្រីគុណ ឈើប្រណីតចំនួន១០៨ម៉ែត្រត្រីគុណ និង៧៤៣គីឡូក្រាម ឈើជ្រុងចំនួន ២ ៧៩០ ម៉ែត្រត្រីគុណ កូនឈើចំនួន ២០០០១៨ដើម អុសចម្រុះចំនួន ៥៣១៨១ស្ទែរ ជន្លង់ម្រេចចំនួន ២៣៩ដើម សសរចំនួន ៥៦ដើម ធ្យូងចំនួន ១៨ ២១៧គីឡូក្រាម គ្រាប់ស្លែងចំនួន ៥៣៧គីឡូក្រាម គល់ធ្នង់និងគល់បេងចំនួន ៥៩០ គីឡូក្រាម ពកបេងចំនួន ៣៩៤គីឡូក្រាម និងជ័រទឹកចំនួន ៤៨២តោន។

**គ-ការធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ**

បានធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ និងបានរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ០៣ក្រុមហ៊ុន គឺក្រុមហ៊ុនឆាយណាហ្រ្វេតខស(ខេមបូឌា) អ៊ិនវេសមេន នៅខេត្តព្រះវិហារ ក្រុមហ៊ុន ណេង ណា អ៊ិនវេសម៉ិន និងក្រុមហ៊ុន វិជ្ជរី អ៊ីមផត អិចផត នៅខេត្តមណ្ឌលគិរី ។





សកម្មភាពចុះធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ

# ការអភិវឌ្ឍចម្ការឈើដាំ និង រុក្ខវប្បកម្ម

នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន ទទួលខុសត្រូវអនុវត្តនូវសកម្មភាពចំនួន០៥ធំៗក្នុងចង្កោមសកម្មភាព៤.១.២"ការអភិវឌ្ឍចម្ការឈើដាំ និងរុក្ខវប្បកម្ម" នៃអនុកម្មវិធី ៤.១ "ការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ"។ សកម្មភាព និងលទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០១៩ នេះមានដូចតទៅៈ

## ១-លិខិតបទដ្ឋានគតិយុត្ត

-សេចក្តីសម្រេចលេខ២៣៨៧ រព.នពដ ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០១៩ របស់រដ្ឋបាលព្រៃឈើស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ថ្នាលបណ្តុះកូនឈើ និងចម្ការរុក្ខទិវា

-ប្រកាសលេខ៥២៧ ប្រក.កសកចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតសួនភូតគាម ស្ថិតក្នុងភូមិសាស្ត្រភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

-ប្រកាសលេខ ៥២៨ ប្រក.កសកចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសំបួរមាស ស្ថិតក្នុងភូមិសាស្ត្រភូមិសំបួរមាស ឃុំស្នឹង ស្រុកបាណន់ ខេត្តបាត់ដំបង

-ប្រកាសលេខ ៥៥៤ ប្រក.កសកចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើភ្នំខ្លង់ ស្ថិតក្នុងភូមិសាស្ត្រឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

-បានចុះកិច្ចព្រមព្រៀងស្តីពីការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើសហការដៃគូរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន ណេងណា អ៊ិនវេសមិន ឯ.ក លើផ្ទៃដីទំហំសរុប ៣ ០០០ហិកតាស្ថិតនៅឃុំរយោះ ស្រុកកោះញែក ខេត្តមណ្ឌលគិរី នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩

-បានចុះកិច្ចសន្យាជំហាន២ស្តីពីការលក់ ទិញដើមឈើអាកាស្យា និងប្រេងខ្យល់ ពីចម្ការឈើរដ្ឋរវាងរដ្ឋបាលព្រៃឈើ និងក្រុមហ៊ុន HMM International Co., Ltd លើផ្ទៃដីទំហំ ៣ ២៦៨ហិកតាស្ថិតនៅក្នុងខេត្តចំនួន៦ រួមមានខេត្តស្វាយរៀង ព្រៃវែង កោះកុង កំពត តាកែវ និងខេត្តកំពង់ឆ្នាំង នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩។

## ២-ការងារគ្រប់គ្រងស្ថានីយដាំឈើ ថ្នាលបណ្តុះកូនឈើ និងសួនឧទ្យាន

### ២.១-ការដាំឈើជាចម្ការថ្មី

បានដាំឈើជាចម្ការថ្មីប្រចាំឆ្នាំ២០១៩លើផ្ទៃដីសរុបទំហំ១៤៨៧ហិកតា ក្នុងនោះបានដាំដោយរដ្ឋលើផ្ទៃដីទំហំ ១៥២ហិកតានៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសន្ទុក ខេត្តកំពង់ធំ និងដាំដោយក្រុមហ៊ុនដៃគូសហការ និងបុគ្គលឯកជនលក្ខណៈគ្រួសារលើផ្ទៃដី១៣៣៥ហិកតា។





ចម្ការឈើដាំ នៅស្រុកសន្ទុក ខេត្តកំពង់ធំ

## ២.២-ការថែទាំចម្ការឈើចាស់ឆ្នាំទី១ ដល់ឆ្នាំទី៥

### ក-ការថែទាំចម្ការឈើចាស់ និងចម្ការឈើរុក្ខទិវា

បាន និងកំពុងថែទាំចម្ការឈើសរុប ១ ០៣០ហិកតា ក្នុងនោះចម្ការពូជឈើ៨៧ហិកតា ឡូត៍បង្ហាញកសិ-រុក្ខកម្ម ៤២ហិកតា ចម្ការឈើដាំទំហំ៨៥២ហិកតា និងចម្ការរុក្ខទិវា ៩កក្កដា សរុបទំហំ៥០ហិកតា ស្ថិតក្នុងខេត្តកំពត តាកែវ កណ្ដាល សៀមរាប ព្រះសីហនុ ស្វាយរៀង និង ខេត្តកំពង់ធំ។





សកម្មភាពនៃការថែទាំចម្ការឈើចាស់

### ខ-ការប្រារព្ធពិធីរុក្ខទិវា

បានប្រារព្ធពិធីរុក្ខទិវាប្រចាំឆ្នាំ២០១៩ លើផ្ទៃសរុប ទំហំ៣៦ហិកតា៦៨២ ក្នុងនោះ រុក្ខទិវាថ្នាក់ជាតិ ០៩កក្កដា ឆ្នាំ២០១៩ ក្រោមព្រះរាជាធិបតីភាព **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្នុង ស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើក្បាលដំរី ភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ លើផ្ទៃដីទំហំ១០ហិកតា និងរុក្ខទិវាថ្នាក់ខេត្តលើផ្ទៃដីទំហំ២៥ហិកតា៦៨៤។





**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងដាំដើមឈើ និង ចែកកូនឈើក្នុងពិធីរុក្ខទិវា ៩ កក្កដា ២០១៩ នៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ



សកម្មភាពរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ប្រជាពលរដ្ឋចូលរួម ដាំដើមឈើក្នុងពិធីរុក្ខទិវាថ្នាក់ជាតិ ៩ កក្កដា ២០១៩ នៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ



ទិដ្ឋភាពរួមនៃទីតាំងប្រារព្ធពិធីរុក្ខទិវាថ្នាក់ជាតិ ៩ កក្កដា ២០១៩ នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលដំរី ក្នុងភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ



សកម្មភាពក្នុងពិធីរុក្ខទិវា នៅក្នុងបរិវេណវត្តប៉ាក់ណាម ឃុំព្រែកជ្រៃ ស្រុកកោះធំ ខេត្តកណ្តាល ថ្ងៃទី១១-០៦-២០១៩



សកម្មភាពក្នុងពិធីរុក្ខទិវា នៅភូមិបឹងអំពិល ឃុំស្ពោ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ថ្ងៃទី០៥-០៧-២០១៩



សកម្មភាពក្នុងពិធីរុក្ខទិវា នៅវត្តអូរត្រេះ ភូមិ៦ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ថ្ងៃទី១៥-០៧-២០១៩



សកម្មភាពក្នុងពិធីរុក្ខទិវា នៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ថ្ងៃទី១៨-០៧-២០១៩

## ២.៣-ការងារបណ្តុះកូនឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋដាំអាស្រ័យផល

បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន **៨០៥ ៧៥៧ ដើម** ក្នុងនោះថ្នាលបណ្តុះកូនឈើចំនួន៦ទីតាំងដែលបានទទួលថវិកាពីនាយកដ្ឋានបានចំនួន **៩០ ០០០ដើម** និងថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសបានចំនួន **៧១៥ ៧៥៧ដើម** និងបានប្រគេន និងចែកចាយកូនឈើដល់ប្រជាពលរដ្ឋ និងព្រះសង្ឃសរុបចំនួន **៦៧៨ ៧៤៧ដើម** ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសបានចំនួន **៥៨៨ ៧៤៧ដើម** និងថ្នាលបណ្តុះកូនឈើចំនួន៦ទីតាំង ដែលបានទទួលថវិកាពីនាយកដ្ឋានបានចំនួន**៩០ ០០០ដើម**។

**២.៤-ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្នាលបណ្ដុះកូនឈើ**

បានរៀបចំ និងសាងសង់ថ្នាលបណ្ដុះកូនឈើចំនួន ៣កន្លែងមានដូចជា ថ្នាលបណ្ដុះកូនឈើ **សម្ដេច ហ៊ុន សែន** ភ្នំតាម៉ៅ ថ្នាលបណ្ដុះកូនឈើតាខ្មៅ និងថ្នាលបណ្ដុះកូនឈើខេត្តកំពង់ឆ្នាំង ដើម្បីបណ្ដុះកូនឈើចែកជូនប្រជាពលរដ្ឋ ឆ្នាំ២០១៩-២០២០ សម្រេចបានចំនួន១០០%(ឈូសឆាយដីទំហំ១ហិកតា ថ្នាលមានគម្របសំរែទំហំ ១០០០ម² ថ្នាលលំហាមិនមានគម្របទំហំ២០០០ម² ប្រព័ន្ធស្រោចស្រពចំនួន ០១ឈុត រទេះរុញចំនួន០១គ្រឿង ម៉ូទ័រ និងក្លោងទ្វារ និងស្លាកឈ្មោះធ្វើអំពីដែក លាបថ្នាំ)។





ថ្នាលបណ្ដុះកូនឈើ សម្ដេច ហ៊ុន សែន ភ្នំតាម៉ៅ ស្ថិតនៅក្នុងភូមិកណ្ដឹងធំ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ

**២.៥-ការងារដឹកប្រឡាយការពារតំបន់ចម្ការឈើដាំគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ**

បានដឹកប្រឡាយការពារចម្ការឈើដាំគ្រញូងក្នុងឆ្នាំ ២០១៩ គឺអនុវត្តសម្រេចគ្រប់តាមផែនការប្រចាំឆ្នាំ២០១៩ មានប្រវែងសរុប៨ ០០០ម៉ែត្រ ក្នុងនោះស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំប្រវែង ៥ ០០០ម៉ែត្រ និងអូរថ្ម ខេត្តព្រះសីហនុ ប្រវែង៣ ០០០ម៉ែត្រ។





ប្រឡាយការពារចម្ការឈើដាំគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ

**២.៦-សិក្ខាសាលាផ្សព្វផ្សាយពិគ្រោះយោបល់ស្តីពីការដាំឈើដល់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ**

បានរៀបចំផ្សព្វផ្សាយសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការដាំឈើដល់សហគមន៍មូលដ្ឋានចំនួន៦ ក្នុងខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ដែលមានអ្នកចូលរួមចំនួនសរុប២៥២នាក់ (ស្រី១១៩នាក់)។

**២.៧-ចុះសិក្សាទីតាំងដីសម្រាប់បង្កើតស្ថានីយ និងចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ**

ក្រុមការងារនាយកដ្ឋានបានចុះពិនិត្យ និងតាមដានលទ្ធផលនៃការចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើនៅខេត្តក្រចេះ តាកែវ កំពង់ធំ បន្ទាយមានជ័យ កំពង់ឆ្នាំង មណ្ឌលគិរី និងខេត្តស្ទឹងត្រែងដូចខាងក្រោម៖

- បានបំពេញបែបបទសុំចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសរុបចំនួន ០៦ ក្នុងខេត្តក្រចេះ ទំហំ

៣៤ ០០៧ហិកតា តាកែវទំហំ ១ ៩១៨ហិកតា កំពង់ឆ្នាំង ទំហំ២៩ ០៦៥ហិកតា បន្ទាយមានជ័យទំហំ១ ១៦៥ហិកតា កំពង់ធំទំហំ ៧៧៤ហិកតា (ចម្ការឈើទំហំ៦៧០ហិកតា និង ចម្ការពូជឈើស្រល់និងតាត្រាវទំហំ១០៤ហិកតា) និង ខេត្តកណ្តាល ៣៥៧ហិកតា៨៩

• ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ០៤ ដែលមានទីតាំងក្នុងខេត្តតាកែវ កំពង់ឆ្នាំង មណ្ឌលគិរី និង ខេត្តស្ទឹងត្រែង បានកំពុងវាស់វែងដោយគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត

• បានទទួលវិញ្ញាបនបត្រសម្គាល់អចលនវត្ថុចំនួន ០៦ប័ណ្ណ ដែលមានផ្ទៃដីសរុបទំហំ២៩ ០៦៥ហិកតាក្នុងនោះ ៣១៣ហិកតា៩៩៧ ស្ថិតនៅក្នុងស្ថានីយម្យៅក្រជាស ហ៊ុន សែន មានក ស្ថិតនៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង និងទីតាំងដីអតីតព្រៃគុបក្នុងឃុំភ្លុកទំហំ ២០០០ហិកតានៅខេត្តស្ទឹងត្រែង។

## ៣-ការអភិវឌ្ឍគ្រាប់ពូជឈើ និងធនធានសេនេទិច

### ៣.១-ការបង្កើតចម្ការពូជឈើក្នុងស្រុក

បានបង្កើតចម្ការពូជឈើប្រភេទគ្រញូង និងធ្នង់លើផ្ទៃដីទំហំ១២ហិកតា នៅទីតាំងសួនអាពាហ៍ពិពាហ៍វល្លិយាវ នៅភូមិត្រពាំងចំបក់ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។



ទីតាំងចម្ការពូជឈើប្រភេទគ្រញូង និងធ្នង់ នៅសួនអាពាហ៍ពិពាហ៍វល្លិយាវ

### ៣.២-ការងារបេះប្រមូលគ្រាប់ពូជឈើ

បានបេះប្រមូលគ្រាប់ពូជឈើក្នុងស្រុកបានទម្ងន់ ៥០៥គីឡូក្រាម រួមមានគ្រាប់ពូជធ្នង់ ១៦០គីឡូក្រាម កកោះ១៩៥គីឡូក្រាម ផ្ចៀក១១០គីឡូក្រាម និងគគីរ ៤០គីឡូក្រាម និងបានចែកចាយគ្រាប់ពូជឈើដល់អ្នកប្រើប្រាស់ទៀតផង។

### ៣.៣- ការងារពិសោធន៍លើប្រភេទអ័រម៉ូនដើម្បីសាកល្បងបណ្តុះកូនឈើតាមរយៈការកាត់ត្រួយកូនឈើអាកាស្យា និងប្រេងខ្យល់

បានដាំកូនឈើប្រភេទប្រេងខ្យល់(G9) ចំនួន៥ ០០០ ដើម និងអាកាស្យាហាយប្រីតចំនួន៥ ០០០ដើម សម្រាប់ទុកធ្វើដើមមេ ព្រមទាំងបានរៀបចំរបាយការណ៍លទ្ធផលនៃការពិសោធន៍កាត់ត្រួយបណ្តុះដោយប្រើប្រាស់អ័រម៉ូនចំនួនបីប្រភេទ គឺ អ័រម៉ូនទឹកប្រភេទ Vitamin B-1 (0-2-0) អ័រម៉ូនទឹកប្រភេទ Extra TONIC root និងអ័រម៉ូនម្សៅ Hormoril 0.8%។



កូនអាកាស្យាហាយប្រីត



លទ្ធផលនៃការពិសោធន៍បច្ចេកទេសកាត់ត្រួយបណ្តុះ

៣.៤- ការងារលើកកម្ពស់ការយល់ដឹងអំពីបច្ចេកទេសកាត់ត្រួយបណ្តុះ

បានចុះផ្សព្វផ្សាយសិក្ខាសាលាលើកកម្ពស់ការយល់ដឹងអំពីបច្ចេកទេសផលិតកូនឈើអាកាស្យាតាមរយៈការកាត់ត្រួយបណ្តុះ នៅឃុំឆ្លករៀន ឃុំសេដ្ឋី ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង មានអ្នកចូលរួមពីសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធសរុបចំនួន១៣៨នាក់ (ស្រី៤៧នាក់)។

## ៤-កសិ-រុក្ខកម្ម

៤.១-ការបង្កើតឡូត៍បង្ហាញកសិ-រុក្ខកម្ម

បានបង្កើតឡូត៍បង្ហាញកសិ-រុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើចំបក់ហោះ ស្ថិតនៅស្រុករវៀង ខេត្តព្រះវិហារ លើផ្ទៃដីទំហំ១២ហិកតា ដោយបានដាំចម្រុះប្រភេទកូនឈើពាណិជ្ជកម្មចំនួន២ ៧០០ដើម រួមមានគ្រញូង បេង និងធ្នង់ ជាមួយកូនស្វាយចន្ទីចំនួន២ ៥០០ដើម ចេកចំនួន ១ ៣៥០ដើម។



ឡូត៍បង្ហាញកសិ-រុក្ខកម្មចម្រុះ ស្វាយចន្ទី និងចេក

៤.២- ការងារធ្វើបច្ចុប្បន្នភាពផ្ទៃដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ និងតំបន់ប្រភពគ្រាប់ពូជឈើ

បានចុះធ្វើបច្ចុប្បន្នភាពផ្ទៃដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន០៣ទីតាំងរួមមាន ស្ថានីយផ្សព្វផ្សាយជីផាត ខេត្តកោះកុង ស្ថានីយបឹងទូក និងជុំគីរី ខេត្តកំពត តំបន់ប្រភពគ្រាប់ពូជឈើស្រល់ និងតាគ្រាវ ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ និងចម្ការពូជឈើនាងនួនស្ថិតនៅក្នុងឃុំប៉ាលហាល ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។

៤.៣-ការងារលើកកម្ពស់ការយល់ដឹងពីការអនុវត្តបច្ចេកទេសកសិ-រុក្ខកម្ម

បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់ការយល់ដឹងពីការអនុវត្តបច្ចេកទេសកសិ-រុក្ខកម្មដល់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធចំនួន១០៨នាក់ នៅសហគមន៍វាលអូរក្តី ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ចំនួន៥៤នាក់ និងសហគមន៍ព្រៃឈើចំបក់ហោះ ស្រុករវៀង ខេត្តព្រះវិហារ ចំនួន៥៤នាក់។



សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់ការយល់ដឹងពីការអនុវត្តបច្ចេកទេសកសិ-រុក្ខកម្មសហគមន៍មូលដ្ឋាន

## ៥-ការងារគ្រប់គ្រងព្រៃឯកជន និងដៃគូសហការ

៥.១- សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីវិធានព្រៃឯកជន និងលិខិតបទដ្ឋានគតិយុត្តដល់វិស័យឯកជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ

បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីវិធានព្រៃឯកជន និងលិខិតបទដ្ឋានគតិយុត្តដល់វិស័យឯកជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធសហគមន៍ព្រៃឈើព្រែកជីក ខេត្តកោះកុង សហគមន៍ព្រៃឈើជ្រោះស្វាយ ខេត្តកំពង់ស្ពឺ សហគមន៍ព្រៃឈើព្រៃយ៉ាវ ខេត្តកំពត និងសហគមន៍ព្រៃឈើត្រពាំងធំ ខេត្តតាកែវ មានអ្នកចូលរួមសរុបចំនួន ១៧៣នាក់(ស្រី៤៩នាក់)។

**៥.២-ការងារចុះពិនិត្យការអនុវត្តការងារដាំឈើវិស័យឯកជន ក្រុមហ៊ុនដៃគូសហការ និង លក្ខណៈគ្រួសារ**

បានចុះពិនិត្យ និងតាមដានការអនុវត្តការងារដាំឈើរបស់ក្រុមហ៊ុនដៃគូសហការ(រដ្ឋជាមួយឯកជន) និងដៃគូសហការជាលក្ខណៈគ្រួសារ ចំនួន៤លើក នៅស្ថានីយសហការដៃគូក្នុងខេត្តក្រចេះ មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តបន្ទាយមានជ័យ។

**៥.៣-ការងារចុះប្រមូលទិន្នន័យ និងសិក្ខាសាលាពិគ្រោះយោបល់សម្រាប់រៀបចំគោលការណ៍ណែនាំស្តីពីការបង្កើតព្រៃឯកជន**

បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ដល់ក្រុមហ៊ុនព្រៃដៃគូសហការ និងបុគ្គលឯកជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធចំនួន៨ខេត្ត ដើម្បីប្រមូលទិន្នន័យសម្រាប់រៀបចំគោលការណ៍ណែនាំស្តីពីការបង្កើតព្រៃឯកជន មានអ្នកចូលរួមសរុបចំនួន៣៦០នាក់ (ស្រីចំនួន៧៣នាក់) ក្នុងខេត្តកោះកុង កំពង់ស្ពឺ កំពង់ចាម កំពង់ធំ សៀមរាប កំពង់ឆ្នាំង បាត់ដំបង និង ខេត្តបន្ទាយមានជ័យ។

## ៦-ការងារអាជីវកម្មកាប់ប្រមូលផលឈើដាំជាមួយក្រុមហ៊ុន HMM International Co., Ltd

-ក្រុមការងាររដ្ឋបាលព្រៃឈើបានសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋានចុះត្រួតពិនិត្យ តាមដាន វាស់វែង និង ប្រគល់-ទទួល ផលឈើពីចម្ការឈើដាំរបស់រដ្ឋ ដើម្បីប្រមូលចំណូលថវិកាចូលជាតិនៅខេត្តតាកែវ ចំនួន **៣ ៣៩៥ ស្ទែរឌុប ៣១៨** គិតជាទឹកប្រាក់ចំនួន **៧១ ៣០១ដុល្លារ៦៨**





សកម្មភាពត្រួតពិនិត្យ វាស់វែងផលឈើពីចម្ការឈើដាំរបស់រដ្ឋ

-បានចុះធ្វើសារពើភ័ណ្ឌប៉ាន់ស្មានធនធានឈើដាំលើផ្ទៃដីចម្ការឈើក្នុងកិច្ចសន្យាជំហាន២ និងផ្ទៃដីចម្ការឈើសេសសល់ក្នុងកិច្ចសន្យាជំហាន១ នៅខេត្តព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង តាកែវ កំពត និងខេត្តកោះកុង លើផ្ទៃដីទំហំ ៦៩៩៦ហិកតា៩២ មានបរិមាណឈើសរុបចំនួន ៣១០ ៦០៨ម៉ែត្រគ្រីគុណ៤០១ ស្មើនឹង ៤៦៥ ៩១២ស្ទែរវាយ៥២៥ គិតជាស្ទែរឌុបស្មើនឹង **២១១ ៧៧៨ស្ទែរឌុប៤២២** និងគិតជាទឹកប្រាក់ចំនួន **៤ ៤៤៧ ៣៤៦ដុល្លារ ៦៨។**



សកម្មភាពធ្វើសារពើភ័ណ្ឌប៉ាន់ស្មានធនធានចម្ការឈើដាំ

# ការងារផ្សព្វផ្សាយព្រៃឈើ-សត្វព្រៃ

## ការផលិតសម្ភារផ្សព្វផ្សាយព្រៃឈើ

ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្សព្វផ្សាយព្រៃឈើឲ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ក្រុមការងារបានរៀបចំបោះពុម្ព និងចែកផ្សាយសម្ភារផ្សព្វផ្សាយព្រៃឈើដែលបានផលិតរួចជាបន្តបន្ទាប់ទៅតាមបណ្ដាអង្គភាព និងស្ថាប័នមួយចំនួន ដូចជាទស្សនាវដ្ដីព្រៃឈើលេខ លេខ៥៩ លេខ៦០ សៀវភៅកម្រងពិធី"រុក្ខទិវា" ៩ កក្កដា ឆ្នាំ២០១៨-២០១៩ សៀវភៅទិនានុលេខន៍ ២០២០ រូបត្លុក អាវយឺត មួកសម្រាប់ប្រារព្ធពិធី"រុក្ខទិវា" ៩ កក្កដា ២០១៩ ដែលមានអត្ថន័យ "ដាំដើមឈើផ្ដើមចេញពីអ្នក" និង " ខ្ញុំបានចូលរួមដាំដើមឈើ"។

## សកម្មភាពគ្រប់គ្រងបណ្ណាល័យ

បានថែរក្សា និងសម្អាតបណ្ណាល័យព្រៃឈើជាប្រចាំដើម្បីផ្ដល់ភាពងាយស្រួល និងជាសុខភាពដល់អ្នកស្រាវជ្រាវ និងអ្នកមានចំណាប់អារម្មណ៍មកសិក្សាស្វែងយល់ និងបានសម្របសម្រួលចែករំលែកព័ត៌មាន និងផ្ដល់ឯកសារពាក់ព័ន្ធវិស័យព្រៃឈើដល់ថ្នាក់ដឹកនាំ ដល់មន្ត្រីក្រោមឱវាទរដ្ឋបាលព្រៃឈើ និងអ្នកស្រាវជ្រាវនានាទៅតាមតម្រូវការផ្សេងៗ។

## សកម្មភាពផ្សព្វផ្សាយព្រៃឈើ

ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងវិស័យព្រៃឈើឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព ក្រុមការងារផ្សព្វផ្សាយបានអនុវត្តការងារដូចខាងក្រោម៖

-បានបោះពុម្ព និងចែកផ្សាយឯកសារទស្សនាវដ្ដីព្រៃឈើលេខ៥៩ លេខ៦០ សៀវភៅកម្រងពិធី "រុក្ខទិវា" ៩ កក្កដា ឆ្នាំ២០១៨-២០១៩ សៀវភៅទិនានុលេខន៍ ២០២០ ជូនដល់បណ្ដាអង្គភាពផ្សេងៗ និងក្នុងពិធី "រុក្ខទិវា" ៩ កក្កដា ឆ្នាំ២០១៩

-បានរៀបចំរូបភាពសម្រាប់បោះពុម្ពលើមួក និងលើអាវយឺតក្នុងពិធី"រុក្ខទិវា" ៩ កក្កដា ២០១៩

-បានរៀបចំគំរូត្រាថ្មីសម្រាប់ផ្នែករដ្ឋបាលព្រៃឈើប្រើប្រាស់ឡើងវិញនៅតាមបណ្ដាខេត្ត ក្រុងទូទាំងប្រទេស

-បានបោះពុម្ពរូបភាពអប់រំផ្សព្វផ្សាយក្នុងវិស័យព្រៃឈើ ចំនួន ៥ប្រភេទ(ទំហំA4 ចំនួន ៤ ប្រភេទ និង A1 ចំនួន ១ប្រភេទ) សម្រាប់ចែកផ្សាយក្នុងពិធី"រុក្ខទិវា" ៩ កក្កដា ២០១៩ នៅខេត្តក្រចេះ

-បានចុះរៀបចំកម្មវិធីបណ្ដុះបណ្ដាលលើកកម្ពស់ការយល់ដឹងអំពីគុណប្រយោជន៍ទូទៅនៃ ជីវចម្រុះព្រៃឈើជាសាធារណៈ និងការងារគ្រប់គ្រងព្រៃឈើឡើងវិញ នៅតាមបណ្ដាខេត្តបានចំនួន១២លើក ស្ថិតក្នុងខេត្តព្រះវិហារ សៀមរាប កំពង់ធំ ក្រចេះ ស្ទឹងត្រែង កំពត ខេត្តកែប ត្បូងឃ្មុំ និងកំពង់ចាម



សកម្មភាពក្រុមការងារចុះសម្របសម្រួល និងរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីគុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសបង្កើតព្រៃឈើឡើងវិញជាមួយសមាជិកសហគមន៍ព្រៃឈើមូលដ្ឋាន ស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ



សកម្មភាពក្រុមការងារចុះសម្របសម្រួល និងរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីគុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសបង្កើតព្រៃឈើឡើងវិញជាមួយសមាជិកសហគមន៍ព្រៃឈើចង្កោរធំជ្រោះជ្រាំជ្រៃ និងពញាគង់ ខេត្តកំពង់ស្ពឺ



សកម្មភាពក្រុមការងារចែកឯកសារ និងរូបផ្ទាំងក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីគុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសបង្កើតព្រៃឈើឡើងវិញជាមួយសមាជិកសហគមន៍ព្រៃឈើមូលដ្ឋាន នៅខេត្តពោធិ៍សាត់

-បានចូលរួម និងថតរូបបិទផ្សាយជាសាធារណៈនៅរដ្ឋបាលព្រៃឈើស្ដីពីសន្និបាតបូកសរុបការងារវិស័យព្រៃឈើឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០១៩ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ២០១៩ និងពិធីទិវាអន្តរជាតិនារី៨មីនាឆ្នាំ២០១៩ ដែលប្រារព្ធធ្វើនៅរដ្ឋបាលព្រៃឈើ សកម្មភាពនៃកិច្ចប្រជុំ ពង្រឹងការអនុវត្តច្បាប់ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត នៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

-បានចូលរួមតាំងបង្ហាញសមិទ្ធផលព្រៃឈើ ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំ២០១៩ ដែលបានប្រព្រឹត្តទៅនៅខេត្តតាកែវ ក្នុងពិធី "រុក្ខទិវា" ៩ កក្កដា ឆ្នាំ២០១៩ នៅខេត្តក្រចេះ ក្នុងពិធីសម្ភោធវិមាន ឈ្នះឈ្នះ ស្ថិតនៅសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងក្នុងទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៩ នៅខេត្តពោធិ៍សាត់

-បានរៀបចំបង្កើតក្រុមការងារដើម្បីរៀបចំប្រមូលចងក្រង និងផលិតទស្សនាវដ្ដីព្រៃឈើ និងបានធ្វើការប្រជុំក្រុមការងារនាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដោយបង្កើតក្រុមតេឡេក្រាមមួយដើម្បីជាមធ្យោបាយផ្ដល់ឯកសារ និងព័ត៌មានផ្សេងៗ

ការផ្សព្វផ្សាយ គឺជាសកម្មភាពមួយរួមចំណែកក្នុងការផ្ទេរចំណេះដឹង ព័ត៌មាន និងកសាងសមត្ថភាពក្នុងវិស័យព្រៃឈើដល់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសប្រជាជនមូលដ្ឋានដែលមានលំនៅដ្ឋានក្បែរឬក្នុងតំបន់ព្រៃ និងអ្នក





ពិព័រណ៍សមិទ្ធផលវិស័យព្រៃឈើក្នុងព្រះរាជពិធី "រុក្ខទិវា" ៩ កក្កដា ឆ្នាំ២០១៩ នៅខេត្តតាកែវ

ដែលអាស្រ័យផលព្រៃឈើទាំងអស់។ ម្យ៉ាងទៀតការងារនេះបានជួយសម្របសម្រួលផ្ដល់នូវលទ្ធភាពងាយស្រួលក្នុងការស្វែងយល់នូវខ្លឹមសារនៃគោលនយោបាយក្នុងវិស័យព្រៃឈើ កម្មវិធីព្រៃឈើជាតិ និងបច្ចេកទេសនៃការងារអភិវឌ្ឍន៍ក្នុងវិស័យព្រៃឈើ តាមរយៈនៃការជួបប្រជុំ ការប្រើប្រាស់រូបផ្ទាំង និងសម្ភារងាយយល់ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយច្រើនយ៉ាងរួមមាន ឯកជន និងរដ្ឋ មានដូចជា វិទ្យុ ទូរទស្សន៍ វីដេអូ កាសែត និងសារព័ត៌មានជាច្រើនទៀត។ល។ ការប្រើប្រាស់នូវគ្រប់មធ្យោបាយ និងវិធីសាស្ត្រផ្សព្វផ្សាយទាំងអស់ខាងលើ ដើម្បីធានាការប្រើប្រាស់ និងការគ្រប់គ្រងធនធានព្រៃឈើឱ្យមានរយៈពេលយូរអង្វែងនៅប្រទេសកម្ពុជា។ លើសពីនេះ ការងារផ្សព្វផ្សាយក៏បានចូលរួមផងដែរក្នុងការងារសិក្សាស្រាវជ្រាវបង្ហាញនូវរបកគំហើញថ្មីនៃបច្ចេកទេសសមស្រប និងមានប្រសិទ្ធភាពសម្រាប់មុខងារស្ដារព្រៃឈើឡើងវិញនៅកម្ពុជា។

# ការងារស្រាវជ្រាវ និងពង្រឹងសមត្ថភាព ក្នុងវិស័យព្រៃឈើ







ការបំបែកកោសិកាសូម៉ាទិចអំប្រីយ៉ុង ស្លឹកឈើគ្រញូង និងស្លឹកឈើនាងនួន តាមរយៈឧបករណ៍ម៉ាស៊ីនស្វ័យប្រវត្តិ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃរដ្ឋបាលព្រៃឈើ និងមានតួនាទីសំខាន់ក្នុងការពង្រឹងសមត្ថភាពក្នុងវិស័យព្រៃឈើ ព្រមទាំងការសិក្សាស្រាវជ្រាវនូវបច្ចេកទេសថ្មីៗសំដៅចូលរួមចំណែកក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ក្នុងឆ្នាំកន្លងទៅនេះ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ឯកឧត្តមប្រតិភូ បានខិតខំស្វែងរកដៃគូសហការឧបត្ថមថវិកាក្នុងការអនុវត្តគម្រោងពង្រឹងសមត្ថភាព និងគម្រោងស្រាវជ្រាវមួយចំនួនដែលក្នុងនេះភាគច្រើន គឺផ្តោតលើបច្ចេកទេសដាំស្តារព្រៃឈើរេចរឹល និងការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន។ ក្នុងឆ្នាំ២០១៩បានសម្រេចនូវលទ្ធផលការងារជាសង្ខេបដូចខាងក្រោម៖

## ១-ការងារពិសោធន៍ជាលិកាវប្បកម្ម

### ក-សកម្មភាពទី១ បានសាកល្បងបណ្តុះកូនគ្រញូង និងកូននាងនួនតាមបច្ចេកទេសជាលិកាវប្បកម្ម

បានសាកល្បងកាត់បណ្តុះស្លឹកគ្រញូង និងនាងនួនចំនួន៥០កំណាត់ តាមវិធីសាស្ត្របណ្តុះអំប្រីយ៉ុង ដោយកាត់យកស្លឹកគ្រញូង និងស្លឹកនាងនួនចេញពីកូនដំណុះដែលបណ្តុះដោយគ្រាប់ពូជក្នុងកែវបិទជិតយកមកបណ្តុះនៅក្នុងកែវបិទជិតតាមបច្ចេកទេសជាលិកាវប្បកម្ម។ ចាប់ពីថ្ងៃបណ្តុះរហូតដល់ការចេញសូម៉ាទិចអំប្រីយ៉ុង (Somatic embryos) មានរយៈពេល១១សប្តាហ៍។

ការបណ្តុះកូនឈើតាមរយៈជាលិកានេះទទួលបានលទ្ធផល៦០% ដែលចេញរូបរាងជាកូនរុក្ខជាតិ។

### ខ-សកម្មភាពទី២ ការបណ្ដុះបណ្ដាលដល់អង្គភាពផ្សេងៗ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ បានផ្ដល់ការបណ្ដុះបណ្ដាលស្ដីពី ការបណ្ដុះកូនឈើតាមបែបជាលិកាវប្បកម្មដល់និស្សិតមកពីសាលាជាតិកសិកម្មព្រែកលៀប សាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង និងមន្ត្រីថ្មីនៃរដ្ឋបាលព្រៃឈើ ចំនួន១២នាក់។







វគ្គបណ្ដុះបណ្ដាលនិស្សិតវិទ្យាសាស្ត្រព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង និងសាលាជាតិកសិកម្មព្រែកលៀប ស្ដីពីរបៀបបង្កាត់លំអងផ្កាអ័រគីដេ ការបង្កើតសារធាតុចិញ្ចឹម និងការកាត់បណ្ដុះឈើតាមបែបជាលិកាវប្បកម្ម

### ២-គម្រោង « ការធ្វើសមាហរណកម្មផែនការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃឈើ និងការធ្វើគម្រោងបង្ហាញស្ដីពី ការស្ដារព្រៃឈើនៅក្នុងមហាអនុតំបន់មេគង្គ»

**គោលបំណង៖** រៀបចំផែនការសកម្មភាពអភិវឌ្ឍន៍សហគមន៍គំរូតាមរយៈពង្រឹងការគ្រប់គ្រងការស្ដារ និងសុវត្ថិភាពកម្មព្រៃឈើ។

#### ២.១- រៀបចំផែនការសកម្មភាពអភិវឌ្ឍន៍សហគមន៍

ក្រុមការងារបានសហការជាមួយសាស្ត្រចារ្យនៃវិទ្យាស្ថាន គ្រឹះស្ថានព្រៃឈើក្រុងយុនមីងចុះប្រជុំពិភាក្សា និងប្រមូលព័ត៌មានជាមួយអាជ្ញាធរដែនដី គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងអ្នកពាក់ព័ន្ធដើម្បីស្វែងយល់ពីការប្រកបមុខរបរប្រចាំថ្ងៃរបស់ប្រជាជន ដំណើរការគ្រប់គ្រងព្រៃសហគមន៍ និងស្ថានភាពព្រៃសហគមន៍សម្រាប់ចងក្រងធ្វើជាផែនការសកម្មភាពអភិវឌ្ឍន៍សហគមន៍។ ក្រោយការរៀបចំសេចក្ដីព្រាង ផែនការសកម្មភាពជាមួយអ្នកពាក់ព័ន្ធ និងធ្វើការកែសម្រួលថតចម្លងចំនួន ៦០ក្បាល និងបានចែកជូនគណៈកម្មការ និងសមាជិកសហគមន៍គោលដៅគម្រោង។



កិច្ចប្រជុំពិគ្រោះយោបល់ជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងមេភូមិដកពរ ខេត្តកំពង់ស្ពឺ






ដាក់ស្លាកផ្សព្វផ្សាយកុំឱ្យលែងគោចូលតំបន់ដាំកូនឈើ និងទប់ស្កាត់បទល្មើស

### ២.២-ការងារល្បាតព្រៃ និងបោះបង្គោលព្រំព្រៃសហគមន៍

#### ក-ការងារល្បាតព្រៃសហគមន៍

គម្រោងបានជួយគាំទ្រដល់សកម្មភាពល្បាតព្រៃដើម្បីទប់ស្កាត់បទល្មើសកាប់ឈើ រុករានដីព្រៃ ការបរបាញ់សត្វព្រៃ ភ្លើងឆេះព្រៃ និងទប់ស្កាត់ការលែងគោចូលក្នុងឡូត៍ស្តារព្រៃឈើ។ សហគមន៍ព្រៃឈើដំរីចាក់ធ្លកមានក្រុមល្បាតចំនួន២១ក្រុម ដែលក្រុមនីមួយៗ មានសមាជិក២០នាក់-៣០នាក់។ ក្រៅពីការងារល្បាតព្រៃក្រុមនេះក៏មានភារកិច្ចចូលរួមក្នុងការងារសង្គមផងដែរដូចជាជួយយាមល្បាតក្នុងភូមិ ពិធីបុណ្យប្រពៃណី ឬក៏ជួយសង់ផ្ទះជូនសមាជិកក្រីក្រចាស់ជរាក្នុងភូមិឃុំ។ល។

#### ខ-ការងារបោះបង្គោលព្រំ

គម្រោងបានជួយឧបត្ថម្ភបង្គោលបេតុង និងបោះបង្គោលព្រំជុំវិញព្រៃសហគមន៍ចំនួន ១០០បង្គោល ដោយបានលាបថ្នាំពណ៌សម្គាល់បង្គោលព្រំ និងដាក់លេខនិយាមកាចំណុចបោះបង្គោល និងលើកផ្ទាំងរូបភាពផ្សព្វផ្សាយការចូលរួមគ្រប់គ្រង និងការពារធនធានព្រៃឈើ។ គោលបំណងនៃការបោះបង្គោលព្រំព្រៃសហគមន៍គឺដើម្បីទប់ស្កាត់ការកាប់រានស្រែ-ចម្ការនៅជាប់ និងក្នុងព្រៃសហគមន៍ផ្សព្វផ្សាយការចូលរួមរបស់សហគមន៍ឱ្យមានការយល់ដឹងពីសារប្រយោជន៍នៃធនធានព្រៃឈើ។





ការផលិត និងបោះបង្គោលព្រំព្រៃសហគមន៍ដំរីចាក់ធ្លក ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

**២.៣-ការសង់រោងល្បាតព្រៃសហគមន៍**

គម្រោងបានជួយឧបត្ថម្ភរោងទំហំ ៥ម គុណ ៧ម សង់អំពីដែកប្រក់សង្ក័សីចំនួន០២កន្លែង សម្រាប់ក្រុមល្បាតព្រៃស្នាក់នៅ និងប្រជុំនានារបស់សមាជិកសហគមន៍។ រោងទាំង០២នេះ សាងសង់ក្នុងព្រៃសហគមន៍ តំបន់ដាំស្តារព្រៃឈើឡើងវិញ និងតំបន់ថ្មខ្សាច់ (Sand stone) ដែលមានសក្តានុពលសម្រាប់បង្កើតជាតំបន់អេកូទេសចរណ៍ សម្រាប់ភ្ញៀវទេសចរណ៍ចូលលេងកម្សាន្ត។





តំបន់ថ្មខ្សាច់ និងរោងល្បាតព្រៃសហគមន៍

**២.៤-ការស្តារ និងធ្វើសុវឌ្ឍកម្មព្រៃឈើ**

ការងារស្តារនិងសុវឌ្ឍកម្មព្រៃឈើអនុវត្តនៅតំបន់ដែលមានប្រភេទព្រៃផ្សេងៗ គ្នា សរុប ១៦ហិកតា គឺ៖១) តំបន់គ្មានគម្របព្រៃឈើ ២)តំបន់ព្រៃរេចរឹលខ្លាំង ៣) តំបន់ព្រៃរេចរឹលបង្គួរ និង ៤) តំបន់ព្រៃក្រាស់។ គម្រោងបានធ្វើការដាំបញ្ចូលនូវប្រភេទឈើ មានតម្លៃពាណិជ្ជកម្មរួមមាន ធ្នង់ បេង គ្រញូង នាងនួន ម៉ៃសាក់ កកោះ និងអង្គាញ់ សរុប ៤៥.៤០០ដើម។ បានធ្វើការសម្អាតស្មៅ ដាក់ជី អិន ប៉េ កា និងសារធាតុរក្សាទឹក ( Water retaining agent ) និងសកម្មភាពផ្សេងទៀតរួមមាន៖

- ធ្វើផ្លូវភ្លើងជុំវិញតំបន់ដាំស្តារព្រៃឈើឡើងវិញទំហំទទឹង៥ម៉ែត្រ បណ្តោយប្រវែង ៣៥០០ម៉ែត្រ
- តម្លើងអាងស្តុកទឹកកម្ពស់ ៦ម៉ែត្រ ធុងស្តុកទឹកចំណុះ ១០០០លីត្រ ចំនួន ០១ និងបណ្តាញទឹកក្នុងឡូត៍ស្តារព្រៃឈើប្រវែង ២៥០០ម៉ែត្រ





សកម្មភាពដាំជួស ជ្រួយដី និងដាក់ជីកូនឈើ

- ធ្វើផ្លូវចូលតំបន់ភ្លើងថ្មខ្សាច់ និងផ្លូវភ្លើងក្នុងព្រៃសហគមន៍ដែលមានទទឹង ៥ម៉ែត្រ និងបណ្តោយប្រវែង៨០.០២០ម៉ែត្រ និងលើកដីកន្លែងទំនាប និងដាក់លូរំដោះទឹកបានចំនួន ០៤កន្លែង អស់លូ ទំហំ ០,៥០ម គុណ ១ម អស់២១លូ
- ជីកស្រះសម្រាប់រក្សាទឹកស្រោចស្រពកូនឈើឡូត៍ស្តារព្រៃឈើ ទំហំ ២០ម៉ែត្រ គុណ ២០ម៉ែត្រ និងជម្រៅ ៣,៣០ម៉ែត្រ
- សង់របងលួសបន្លាជុំវិញឡូត៍ទំហំផ្ទៃដី ១២ហិកតា





ការរៀបចំប្រព័ន្ធស្រោចស្រពកូនឈើឡូតិ៍ស្តារព្រៃឈើ



ការធ្វើផ្លូវភ្លើង និងដាក់លូឆ្លងកាត់ផ្លូវនៅ
សហគមន៍ព្រៃឈើដំរីចាក់ធ្លក ខេត្តកំពង់ស្ពឺ

### ២.៥-ការថែទាំស្រះទឹក និងប្រព័ន្ធទឹក

បានដាំកូនឈើ លើកដីបំពេញចង្អូរលើខ្នងទំនប់ជុំវិញស្រះទឹកដើម្បីការពារការហូរច្រោះដី បានប្រវែង ២៨០ម៉ែត្រ។





ការច្រកដីក្នុងបាវទប់ស្កាត់ការហូរច្រោះ
និងដាំកូនឈើជុំវិញខ្នងទំបន់ស្រះទឹក

### ២.៦-ការរៀបចំប្រព័ន្ធកសិ-រុក្ខកម្ម និងសួនបន្លែលំនៅដ្ឋាន

ដោយមានការសម្របសម្រួល និងសហការជាមួយគណកម្មការសហគមន៍ព្រៃឈើដំរីចាក់ធ្លក បានប្រជុំពិភាក្សាជ្រើសរើសគ្រួសារសម្រាប់អនុវត្តសាកល្បងកសិ-រុក្ខកម្មចំនួន០២គ្រួសារ លើទំហំផ្ទៃដី ១ហិកតា៥០ និងសួនបន្លែលំនៅដ្ឋានចំនួន០២គ្រួសារ មានផ្ទៃដីសរុប ០ ហិកតា៩០។

#### ក-ឡូត៍កសិ-រុក្ខកម្ម

គម្រោងបានសហការជាមួយកសិករម្ចាស់ដី រៀបចំសម្អាតដី បែងប្លុកសម្រាប់ដាំកូនឈើ ក្នុងនោះមានចំនួន

០៣ប្លុក ដែលប្លុកនីមួយៗ មានទទឹង ៣០ម៉ែត្រ និងបណ្តោយ ១១០ម៉ែត្រ និងចែកជា០២អនុប្លុក ដោយរក្សាទុកព្រៃធម្មជាតិទទឹង ៥ម៉ែត្រ គុណ ១១០ម៉ែត្រ ចំនួន ០៣ខ្សែ ដើម្បីទប់ស្កាត់ការហូរច្រោះដី តបណ្តាញ ស្រោចស្រពតាមប្លុកនីមួយៗ និងធ្វើរបងលួសបន្លាព័ទ្ធជុំវិញឡូត៍ ទំហំ ១១០ម៉ែត្រ គុណ ១៣០ម៉ែត្រ។

គម្រោងបានដាំបញ្ចូលនូវប្រភេទឈើហូបផ្លែរួមមាន៖

- ម៉ាកាដាមៀ *Macadamia ternifolia* (macadamia nut) ចំនួន១៤៤ដើម
- ក្រូចថ្លុង *Zizyphus mauritiana* (green date) ចំនួន ១៤៤ដើម
- ស្វាយចន្ទី *Mangifera indica* (mango) ចំនួន ១៤៤ដើម
- ឬស្សីផ្អែមចំនួន២០គុម្ព និងពូជដំណាំសម្រាប់ឆ្លាស់តាមចន្លោះជួរដាំឈើហូបផ្លែមួយចំនួនដូចជា ម្រេច ត្រប់វែង ល្ពៅ ត្រឡាច ត្រសក់ សណ្តែកកួរ ត្រកួន សកម្មភាពនេះ គោលបំណងគឺដើម្បីរួមចំណែកលើកកម្ពស់តាមរយៈការដាំដំណាំឆ្លាស់។ ទន្ទឹមនឹងការគាំទ្រថវិកា បច្ចេកទេស និងពូជដំណាំ គម្រោងបានចូលរួមសហការជាមួយកសិករធ្វើការសម្អាតស្មៅ ដាក់ជី ពូនគល់ ដាក់ជី និងស្រោចទឹកកូនឈើ ដោយមានការសម្របសម្រួលបច្ចេកទេសពីមន្ត្រីគម្រោង និងទីប្រឹក្សាចិន។



ការដាំដុះពហុដំណាំក្នុងឡូត៍កសិ-រុក្ខកម្ម

ខ-សួនបន្លែលំនៅដ្ឋាន

បានជ្រើសរើសកសិករចំនួន ០២គ្រួសារដើម្បីអនុវត្តសាកល្បងសួនបន្លែលក្ខណៈគ្រួសារ ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពលើផ្ទៃដីសរុប០ហិកតា៩០។ ក្រុមការងារបានរៀបចំដីបែងចែកប្លុក សម្រាប់ធ្វើការដាំដុះឈើហូបផ្លែ និងដំណាំឆ្លាស់ ក្នុងនោះរួមមាន ម៉ាកាដាមៀ ចំនួន ៤១ដើម ក្រូចថ្លុង៤១ដើម និងស្វាយចន្ទីចំនួន៤១ដើម។ បន្ថែមលើនេះគម្រោងបានជួយពូជដំណាំ ម្រេច ល្ពៅ ត្រឡាច ពោត ត្រសក់ សណ្តែកកួរ ម្ទេង ល្មៀត និងខ្ទាយ សម្រាប់ដាំបញ្ចូលចន្លោះកូនឈើហូបផ្លែ និងក្រោមម្លប់ឈើព្រៃ និងបានតប្រព័ន្ធស្រោចស្រព។





សកម្មភាពថែទាំ និងស្រោចទឹកដំណាំ ក្នុងឡូត៍សួនបន្លែលំនៅដ្ឋាន

**២.៧-សន្និដ្ឋាន (សង្ខេបអំពីលទ្ធផល ការរំពឹងទុករបស់អ្នកដឹកនាំអនុវត្តលើការងារទាំងនេះ)**

ការងារអនុវត្តនៅទីវាលជួបប្រទះបញ្ហាប្រឈមខ្លះ ដូចជា កត្តាស្ថានភាពដីពុំសូវអំណោយផលដល់ការដាំដុះ គ្មានប្រភពទឹក ខ្វះខាតកម្លាំងពលកម្ម ប្រជាជនពុំសូវបទពិសោធន៍ ចំណេះដឹងធ្វើដំណាំឆ្លាស់ (កសិ-រុក្ខកម្ម ឬសួនបន្លែលក្ខណគ្រួសារ) ខ្វះខាងទីផ្សារលក់ផលិតផលកសិកម្ម និងរចនាសម្ព័ន្ធគមនាគមន៍ ទម្លាប់ការព្រលែងសត្វពាហនៈក្រោយរដូវប្រមូលផល ការដុតជញ្ជ្រាំង ឬស្មៅក្នុងចម្ការ ។ល។ ទោះបីមានការជួបប្រទះនូវភាពប្រឈមមួយ ចំនួនក៏ដោយក៏ថ្នាក់ដឹកនាំ មន្ត្រីអនុវត្តគម្រោងបានសហការជាមួយរដ្ឋបាលព្រៃឈើថ្នាក់ខេត្ត អាជ្ញាធរដែនដី តំណាងសហគមន៍ជម្រុញការងារ ឱ្យបានរួចរាល់តាមផែនការ និងបានស្វះស្វែងរកបច្ចេកទេសថ្មីៗ អប់រំផ្សព្វផ្សាយទប់ស្កាត់ការដុតភ្លើងព្រៃ ផ្តល់បច្ចេកទេសថែទាំ ដឹកនាំអនុវត្ត និងពិនិត្យតាមដានការងារទីវាលជាប្រចាំជាមួយកសិករ។ ដោយមានកិច្ចសហការចូលរួមខាងលើនេះ បានធ្វើឱ្យកសិករមួយចំនួនកែប្រែទម្លាប់ពីដាំដំណាំឯក មកជាពហុដំណាំ កាត់បន្ថយការដុតស្រែ-ចម្ការបន្ទាប់ពីប្រមូលផល ការរៀបចំសួនបន្លែជាលក្ខណៈគ្រួសារ ចិញ្ចឹមសត្វចតុបាតដាក់ទ្រុង និងការធ្វើផែនការសម្រាប់រៀបចំមុខរបរ ។ល។ ទន្ទឹមនឹងភាពរីកចម្រើន ការកែប្រែទម្លាប់ទាំងនេះ ក៏ហាក់មិនបានបំពេញនូវមហិច្ឆិតាដែលគម្រោងចង់ បានក៏ដោយ ក៏យើងនៅតែបន្តឱ្យមានការកែប្រែកាន់តែប្រសើរជាងបច្ចុប្បន្នតាមរយៈការលើកទឹកចិត្តដល់អ្នកចូលរួមមានឱកាសចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ឬទស្សនកិច្ចសិក្សាក្នុងគោលដៅដៃគូរអភិវឌ្ឍន៍នានា។

## ៣-គម្រោង«ការអភិរក្សធនធានសេនេទិចនៃប្រភេទឈើក្នុងអំបូរគ្រញូងនៅក្នុងតំបន់ទន្លេមេគង្គ»

ប្រភេទឈើសំខាន់ៗនៅកម្ពុជា នាពេលបច្ចុប្បន្នកំពុងទទួលរងនូវការគំរាមកំហែមយ៉ាងខ្លាំង ជាពិសេសប្រភេទឈើនៅក្នុងអំបូរគ្រញូង (គ្រញូង នាងនួន និងគ្រញូងស្វា)។ ដើម្បីឆ្លើយតបទៅនឹងតម្រូវ និងការគំរាមកំហែងនេះ ការអភិរក្សធនធានសេនេទិច នៃប្រភេទឈើក្នុងអំបូរគ្រញូងគឺមានសារសំខាន់ខ្លាំងណាស់នាពេលបច្ចុប្បន្ន។

គម្រោងបានសម្រេចនូវសកម្មភាពសំខាន់ៗ រួមមាន៖

**៣.១-ការពិសោធន៍លើបច្ចេកទេសកាត់ដោតមែកគ្រញូង**

ក្រុមការងារគម្រោងបានសិក្សាទៅលើបច្ចេកទេសនៃការកាត់ដោតមែកគ្រញូង។ ការសាកល្បងពិសោធន៍ចំនួន៦លើកត្រូវបានធ្វើ ដោយប្រើមធ្យោបាយផ្សេងៗគ្នា ដើម្បីចង់ដឹងពីបច្ចេកទេសនៃការកាត់ដោតមែកគ្រញូងនេះ។ សារធាតុគីមីចំនួន៥ ប្រភេទត្រូវបានប្រើរួមមាន៖ NAA , IBA, Liger-Root, Rooting hormone, និង Tricoderma-X។ ជាលទ្ធផលនៃការពិសោធន៍នេះ ៦០% នៃមែកគ្រញូងដុះលូតលាស់ល្អ។ ការប្រើRooting hormone មានអត្រាដុះលូតលាស់ល្អជាងសារធាតុគីមីផ្សេងទៀត។



ការពិសោធន៍លើការកាត់ដោតមែកគ្រញូង

**៣.២-ការពិសោធន៍លើបច្ចេកទេសកាត់តដើមគ្រញូង**

ក្រុមការងារគម្រោងកំពុងព្យាយាមសិក្សាទៅលើបច្ចេកទេសនៃការកាត់តមែកគ្រញូង។ ការសាកល្បងនេះបានធ្វើឡើងចំនួន ៤លើក ។



សកម្មភាពកាត់តមែកគ្រញូង

### ៣.៣- ការបង្កើតចម្ការពូជគ្រញូង និង វិភាគ DNA

បានចុះប្រមូលសំណាកស្លឹក និងគ្រាប់ពូជគ្រញូងសម្រាប់បង្កើតចម្ការពូជ និងវិភាគ DNA ពីខេត្តចំនួន៣ រួមមាន ខេត្តកំពង់ធំ ពោធិ៍សាត់ និងខេត្តសៀមរាប សរុបចំនួន ៥០សំណាកស្លឹក និងសំណាកគ្រាប់ សរុបចំនួន ២៥សំណាក។ សកម្មភាពប្រមូលសំណាកស្លឹក និងគ្រាប់គ្រញូង និងនាងនួន នេះនឹងបន្តធ្វើនៅខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តព្រះវិហារ។ សំណាកស្លឹក និងគ្រាប់គ្រញូង និងនាងនួន នឹងត្រូវបញ្ជូនទៅសាកលវិទ្យាល័យ Oxford នៃចក្រភពអង់គ្លេស ដើម្បីធ្វើការវិភាគនៅដើមខែកុម្ភៈ ២០២០។



សកម្មភាពចុះបេះប្រមូលស្លឹក និងគ្រាប់ពូជ

លទ្ធផលរំពឹងទុកសំខាន់ៗដែលនឹងទទួលបានពីការអនុវត្តគម្រោងនេះរួមមាន៖

១.ការវាយតម្លៃថ្នាក់តំបន់អំពីស្ថានភាពនៃដំណុះ និងការអភិរក្សធនធានសេនេទិកនៃប្រភេទឈើគ្រញូង នាងនួន និងគ្រញូងស្វា

២.ការអភិរក្សក្នុងតំបន់ (*in-situ*) និងក្រៅតំបន់ (*ex-situ*)តាមរយៈការបង្កើតឡូត៍ បង្ហាញប្រៀបធៀបប្រភពកំណើតប្រភេទឈើក្នុងអំបូរគ្រញូង និង

៣.ការផលិតកូនឈើដោយសហគមន៍មូលដ្ឋានដើម្បីបង្កើនប្រាក់ចំណូល និងកាត់បន្ថយសម្ពាធដល់ដំណុះឈើធម្មជាតិ។

## ៤-ការជំរុញការងារស្តារព្រៃឈើនៅកម្ពុជា និងវៀតណាម តាមរយៈការបង្កើតឡូត៍បង្ហាញ និងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធចែកចាយគ្រាប់ពូជឈើ

ដើម្បីឆ្លើយតបទៅនឹងតម្រូវការគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញការងារស្តារព្រៃឈើនៅកម្ពុជានាពេលបច្ចុប្បន្ន វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ នៃរដ្ឋបាលព្រៃឈើ បានសម្រេចនូវសកម្មភាពសំខាន់ៗរបស់គម្រោងក្នុងឆ្នាំ២០១៩ រួមមាន ៖

### ៤.១-ប្រភពគ្រាប់ពូជឈើ

គម្រោងបានរៀបចំកែសម្រួលបញ្ជីឈ្មោះប្រភពគ្រាប់ពូជឈើដោយដាក់បញ្ចូលគ្នានូវតំបន់ផលិតគ្រាប់ពូជឈើ ចម្ការពូជឈើសំខាន់ៗនៅកម្ពុជា និងប្រភពគ្រាប់ពូជឈើនៅក្នុងដំណុះព្រៃធម្មជាតិ។ នៅក្នុងបញ្ជីឈ្មោះមានទីតាំងសរុបចំនួន២៤កន្លែង ដោយរួមមានប្រភេទឈើអាទិភាពសម្រាប់ដាំដុះ និង អភិរក្សប្រមាណជា ២០ប្រភេទ។

### ៤.២-ចម្ការពូជឈើ

គម្រោងបានថែទាំចម្ការឈើ ឆាំឆា តាត្រាវ ច្រេស អាកាស្យាស្លឹកតូច អាកាស្យាស្លឹកធំ ព្រមទាំងបានធ្វើឲ្យរហាលនៅក្នុងចម្ការឈើអាកាស្យា។ ចម្ការពូជឈើនីមួយៗមានទំហំ១ហិកតា ស្ថិតនៅឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលនឹងក្លាយទៅជាតំបន់ផលិតគ្រាប់ពូជឈើនាថ្ងៃអនាគត។



ចម្ការពូជឈើច្រេស បន្ទាប់ពីថែទាំរួច

### ៤.៣-ឡូត៍បង្ហាញស្តារព្រៃឈើ

បានថែទាំឡូត៍បង្ហាញស្តារព្រៃឈើដោយដាំឈើចម្រុះប្រភេទនិងឡូត៍បង្ហាញស្តារព្រៃឈើដាំឈើដោយគ្រាប់ នៅក្នុងឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប។



សកម្មភាពថែទាំឡូត៍បង្ហាញស្តារព្រៃឈើ

### ៤.៤-សិក្ខាសាលា និងកិច្ចប្រជុំ

#### ក. សិក្ខាសាលាបញ្ចប់គម្រោង

សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងសំខាន់ៗ រួមមាន៖១.បង្កើនការយល់ដឹងអំពីសារសំខាន់នៃការប្រើប្រាស់គ្រាប់ពូជឈើដែលមានគុណភាពក្នុងចំណោមអ្នកពាក់ព័ន្ធ ២.ផ្សព្វផ្សាយអំពីប្រភពគ្រាប់ពូជឈើ និងអ្នកទំនាក់ទំនងដើម្បីទិញគ្រាប់ពូជឈើ ៣.ចែករំលែកនូវមេរៀន បទពិសោធន៍លើការងារស្តារព្រៃឈើ និងការបង្កើតប្រភពគ្រាប់ពូជឈើ និងការប្រើប្រាស់គ្រាប់ពូជឈើ ដែលទទួលបានពីការអនុវត្តគម្រោងក្នុងរយៈពេល៥ឆ្នាំកន្លងមក។ សិក្ខាសាលានេះ មានអ្នកចូលរួមសរុបចំនួន៤៣នាក់ មកពីរដ្ឋបាលព្រៃឈើថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន តំណាងក្រុមហ៊ុនដាំឈើ អង្គការជាតិ-អន្តរជាតិ និងសាកលវិទ្យាល័យ។



សិក្ខាសាលាបញ្ចប់គម្រោង

#### ខ. កិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោង

កិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោងនេះរៀបចំឡើងដើម្បីពិភាក្សាវាយតម្លៃលើសមិទ្ធផល និងបទពិសោធន៍ដែលគម្រោងសម្រេចបានក្នុងរយៈពេលអនុវត្តន៍៥ឆ្នាំកន្លងមកនេះ។ កិច្ចប្រជុំនេះ មានតំណាងមកពីសាធារណរដ្ឋកូរ៉េ ចំនួន ៥នាក់ តំណាងមកពីប្រទេសវៀតណាម ចំនួន ៥នាក់ និងតំណាងពីកម្ពុជាចំនួន ១៤នាក់។





សកម្មភាពនៃកិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោង

៤.៥-ការងារបោះពុម្ព

បានបោះពុម្ពសៀវភៅ "មេរៀន និងបទពិសោធន៍" ពីការអនុវត្តគម្រោង ចំនួន១០០ក្បាល សៀវភៅ ព្រមទាំងខិត្តប័ណ្ណស្តីពី "ភាពជោគជ័យនៃកសិករប្រកបមុខរបរលក់គ្រាប់ពូជឈើ និងកូនឈើ" ចំនួន៥០០សន្លឹក និងខិត្តប័ណ្ណស្តីពី "ប្រភពគ្រាប់ពូជឈើ" ចំនួន ១០០០សន្លឹក។

**លទ្ធផលសំខាន់ៗដែលគម្រោងសម្រេចបានក្នុងរយៈពេលប្រាំឆ្នាំកន្លងមករួមមានៈ**

-ប្រភពគ្រាប់ពូជឈើនៅក្នុងដំណុះព្រៃធម្មជាតិចំនួន ១៥ កន្លែង (និងអ្នកទំនាក់ទំនង) ត្រូវបានកំណត់

-បានបណ្តុះបណ្តាលសហគមន៍ចំនួន១៣ និងមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន ដែលមានលទ្ធភាពផ្គត់ផ្គង់គ្រាប់ពូជឈើ អំពីការបេះប្រមូលគ្រាប់ពូជ ការវេចខ្ចប់ និងការលក់គ្រាប់ពូជ

-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីប្រភពគ្រាប់ពូជឈើ និងឡូត៍បង្ហាញស្តារព្រៃឈើ

-បានផលិតជាឯកសារផ្សព្វផ្សាយអំពីប្រភពគ្រាប់ពូជឈើ(Leaflet) សៀវភៅស្តីពី ប្រភពគ្រាប់ពូជឈើ និងឡូត៍បង្ហាញស្តារព្រៃឈើ បង្កើតឡើងក្រោមជំនួយថវិកាពី AFoCO សៀវភៅស្តីពី ការដាំឈើដោយគ្រាប់ សៀវភៅស្តីពី មេរៀន និងបទពិសោធន៍នៃគម្រោង និងផ្ទាំងផ្សព្វផ្សាយអំពីសមិទ្ធផលគម្រោង

-បន្ទប់មួយនៅក្នុងអគារ វ.ស.អ. ត្រូវបានបំលែងទៅជាមន្ទីរពិសោធន៍គ្រាប់ពូជឈើ និងបានបំពាក់សម្ភារមួយចំនួនសម្រាប់ឲ្យមន្ទីរពិសោធន៍គ្រាប់ពូជឈើ

-មន្ត្រី វ.ស.អ មួយរូប (អ្នកស្រី រិន ចិន្តា) បានទទួលការបណ្តុះបណ្តាលនៅសាធារណរដ្ឋកូរ៉េ លើមុខជំនាញបច្ចេកវិជ្ជាគ្រាប់ពូជឈើ និងមន្ត្រី វ.ស.អ ៥ រូបទៀតបានទទួលការបណ្តុះបណ្តាលលើជំនាញគ្រាប់ពូជឈើនៅក្នុងប្រទេសតាមរយៈវគ្គបណ្តុះបណ្តាលខ្លីៗដែលរៀបចំដោយគម្រោង

-បានដំណើរការមន្ទីរពិសោធន៍ជាលិកាវប្បកម្ម ដែលមានមន្ត្រីចូលរួមសរុបចំនួន៤នាក់

-បានបង្កើតចម្ការឈើ ឆាំឆា តាត្រាវ ច្រេស អាកាស្យាស្លឹកតូច អាកាស្យាស្លឹកធំ ដែលចម្ការពូជឈើនីមួយៗមានទំហំ១ហិកតា (សរុប ៥ហិកតា) នៅក្នុងឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

-បានបង្កើតឡូត៍បង្ហាញស្តារព្រៃឈើដោយដាំឈើចម្រុះប្រភេទ (២៦ ប្រភេទ) ក្នុងកំរិតដង់ស៊ីតេខ្ពស់ទំហំ ២ហិកតា និងឡូត៍បង្ហាញស្តារព្រៃឈើដាំឈើដោយគ្រាប់ទំហំ ១ហិកតា នៅក្នុងឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

-ថែរក្សាឡូត៍បង្ហាញស្តារព្រៃឈើដាំដោយគ្រាប់ទំហំ ២ហិកតា នៅក្នុងឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

## ៥-ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសេនេទិចព្រៃឈើសម្រាប់ស្តារប្រភេទឈើសំខាន់ៗនៅកម្ពុជា

ភាពមិនទាន់ច្បាស់លាស់ពីប្រភពគ្រាប់ពូជឈើ ធ្វើឲ្យមានផលលំបាកក្នុងការអនុវត្តផែនការស្តារព្រៃឈើទ្រង់ទ្រាយធំឲ្យមានប្រសិទ្ធិភាពខ្ពស់។ យោងលើបញ្ហានេះ នាឆ្នាំ២០១៦វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ(វសអ)នៃរដ្ឋបាលព្រៃឈើបានសហការជាមួយអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី-កូរ៉េ (AFoCO) ធ្វើការស្រាវជ្រាវពីបច្ចេកទេសបង្កាត់ពូជឈើមួយ ដែលផ្តល់ប្រភពធនធានសេនេទិចច្បាស់លាស់ និងក្លាយជាប្រភពគ្រាប់ពូជមួយដែលបានជ្រើសរើសដើមពូជល្អៗទៅតាមបច្ចេកទេសត្រឹមត្រូវ។

### ៥.១-ចម្ការ ( ឡូត៍ពិសោធន៍ ) បង្កាត់ពូជឈើ (Seed Orchard)

ចម្ការបង្កាត់ពូជឈើចំនួន០៦ហិកតា ត្រូវបានបង្កើតឡើងក្នុងខេត្តសៀមរាប នាឆ្នាំ២០១៦(ទីតាំងទី១) និងឆ្នាំ២០១៧ (ទីតាំងទី២) ដើម្បីធ្វើការពិសោធន៍ពីវិធីសាស្ត្របន្សុទ្ធពូជឈើបីប្រភេទរួមមាន គ្រញូង ធ្នង់ និងក្រាច ដែលមានប្រភពមកពីខេត្តចំនួន១១ក្នុងប្រទេសកម្ពុជា។ ប្រភេទនីមួយៗ ត្រូវបានដាំលើផ្ទៃដីទំហំ០២ហិកតា និងមាន

កូនឈើចំនួន៨០០ដើមស្មើៗគ្នា ដែលកូនទាំងនោះបាន មកពីការអនុវត្តវិធីសាស្ត្រសាកវប្បកម្ម (grafting) (យក មែកពីដើមពូជចំនួន១០០ដើម/ប្រភេទ មកតភ្ជាប់ជាមួយ កូនដែលបណ្ដុះដោយគ្រាប់) ចំពោះប្រភេទគ្រញូង និងធ្នង់ ចំណែកឯគ្រាច គឺបណ្ដុះដោយគ្រាប់ (ព្រោះបរាជ័យក្នុង វិធីសាស្ត្រតមែក)។ ទន្ទឹមគ្នានេះដែរ ចម្ការប្រៀបធៀប ដើមពូជ(Progeny Test Plantation) ចំនួន២៤ហិកតា (០៨ហិកតា/ប្រភេទ) ក៏ត្រូវបានបង្កើតឡើងដោយប្រើប្រាស់ កូនដែលបណ្ដុះដោយគ្រាប់របស់ដើមមេបាដូចគ្នានឹងមេបា របស់ចម្ការបង្កាត់ពូជឈើដែរ ដើម្បីធ្វើការប្រៀបធៀបរក មេបាណាខ្លះដែលអាចចាត់ទុកជាពូជល្អ ដោយយោងលើ លក្ខណៈវិនិច្ឆ័យដូចជាអង្កត់ផ្ចិត កម្ពស់ និងកន្សោមស្លឹក លូតលាស់ល្អ ទម្រង់ដើមត្រង់ មែកតិច ហើយធន់នឹង ជំងឺ។ ទិន្នន័យទាំងនេះ នឹងត្រូវប្រើជាមូលដ្ឋានសម្រាប់រក្សា ទុកដើមមេពូជក្នុងចំការបង្កាត់ពូជឈើ ហើយធ្វើការកាត់ ចេញនូវដើមមេបាណាដែលមិនត្រូវនឹងលក្ខខណៈវិនិច្ឆ័យ ទាំងអស់នេះ។



រូបថតពីលើអាកាសចម្ការបង្កាត់ពូជឈើនៅទីតាំងទី១
ស្រុកបន្ទាយស្រី ខេត្តសៀមរាប

### ៥.២-ការបណ្ដុះបណ្ដាល

វាជាការចាំបាច់ណាស់ ក្នុងការបណ្ដុះបណ្ដាលធន ធានមនុស្សឲ្យបានច្រើន សម្រាប់ការងារស្រាវជ្រាវ និង អភិវឌ្ឍន៍។ ក្រៅពីរៀបចំវគ្គបណ្ដុះបណ្ដាលដល់ក្រុមអនុវត្តន៍ គម្រោង ក្រុមការងារបានរៀបចំកម្មសិក្សា ដល់ក្រុមនិស្សិត សកលវិទ្យាល័យដែលកំពុងសិក្សាមុខជំនាញវិទ្យាសាស្ត្រ ព្រៃឈើប្រមាណជាង៣០នាក់ក្នុងមួយឆ្នាំ គោលបំណងចង់ ឲ្យពួកគាត់បានដកស្រង់បទពិសោធន៍ការងារជាក់ស្ដែងនៅ ទីវាល បានរៀនសូត្រពីការងារពិសោធន៍នានា ជាពិសេស ពាក់ព័ន្ធនឹងវិធីសាស្ត្រស្តារព្រៃឈើ។ បន្ថែមពីនេះ គម្រោង បានជួយគាំទ្រការសរសេរនិក្ខេបបទរបស់និស្សិតបញ្ចប់ការ សិក្សាចំនួន០៣រូបក្នុងឆ្នាំ២០១៩នេះ ដើម្បីឲ្យពួកគាត់បាន សិក្សាកាន់តែស៊ីជម្រៅបន្ថែមទៀតអំពីការងារស្រាវជ្រាវ។ ក្រៅពីនេះ ប្រជាពលរដ្ឋដែលរស់នៅជុំវិញទីតាំងគម្រោងក៏ ទទួលបានការបណ្ដុះបណ្ដាលដែរពាក់ព័ន្ធនឹងការបណ្ដុះកូន ឈើ ការប្រមូលគ្រាប់ពូជ ការដាំឈើ ការថែទាំកូនឈើ និងការការពារភ្លើងឆេះព្រៃជាដើម។





ការបណ្ដុះបណ្ដាលក្រុមនិស្សិត (រូបលើ) និង
ការបណ្ដុះបណ្ដាលប្រជាពលរដ្ឋ(រូបក្រោម)

## ៥.៣-ការផ្សព្វផ្សាយ

ដើម្បីចែករំលែកចំណេះដឹង បទពិសោធន៍និងព័ត៌មានទាក់ទងនឹងការសិក្សាស្រាវជ្រាវនេះ ក្រុមការងារបានធ្វើការផ្សព្វផ្សាយតាមរយៈមធ្យោបាយផ្សេងៗ ដូចជាចូលរួមធ្វើបទបង្ហាញអំពីគម្រោងក្នុងសិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ សម្របសម្រួលដល់ក្រុមទស្សនកិច្ចសិក្សា រៀបចំវេទិកាផ្សព្វផ្សាយជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន រៀបចំខិត្តប័ណ្ណស្តីអំពីគម្រោង ចងក្រងសៀវភៅ ប្រភពគ្រាប់ពូជឈើ និងកំពុងចងក្រងសៀវភៅគោលការណ៍ណែនាំអំពីការបង្កាត់ពូជឈើ។



ការបង្ហាញឡូត៍ពិសោធន៍ដល់ក្រុមទស្សនកិច្ចសិក្សា ដែលអញ្ជើញមកពីរដ្ឋសភានៃសាធារណរដ្ឋកូរ៉េ




ខិត្តប័ណ្ណស្តីពីគម្រោងសម្រាប់ធ្វើការផ្សព្វផ្សាយ

## ៥.៤-ការងារគ្រប់គ្រង និងសហប្រតិបត្តិការ

ដើម្បីធានាថាការងារស្រាវជ្រាវនេះប្រព្រឹត្តទៅតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ ក្រុមការងារបានធ្វើការទំនាក់ទំនងជាប្រចាំជាមួយទីប្រឹក្សាជាតិរបស់គម្រោង អ្នកជំនាញការមកពីវិទ្យាស្ថានវិទ្យាសាស្ត្រព្រៃឈើជាតិកូរ៉េ (NIFoS) និងសាស្ត្រាចារ្យនៃសកលវិទ្យាល័យជាតិសេអ៊ូល (SNU) នៃសាធារណរដ្ឋកូរ៉េ ដើម្បីពិគ្រោះយោបល់ និងសួរនាំពីបច្ចេកទេសនានាពាក់ព័ន្ធនឹងការងារពិសោធន៍។ បន្ថែមលើនេះទៀត ក្រុមការងារបានរៀបកិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោង (Project Steering Committee)ដែលមានសមាសភាពចូលរួមដូចជា ថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើ តំណាងលេខាធិការដ្ឋានអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី-កូរ៉េ វិទ្យាស្ថានជាតិស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើកូរ៉េ ព្រឹទ្ធបុរសនៃមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើនៃសកលវិទ្យាល័យភូមិន្ទកសិកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប និងក្រុមការងារគម្រោងរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃនៃរដ្ឋបាលព្រៃឈើជារៀងរាល់ឆ្នាំ ដើម្បីត្រួតពិនិត្យលើការងារដែលបានអនុវត្តក្នុងឆ្នាំនីមួយៗ និងផ្តល់អនុសាសន៍ណែនាំដល់សកម្មភាពដែលត្រូវធ្វើបន្តក្នុងឆ្នាំបន្ទាប់។




កិច្ចប្រជុំលើកទី០៥ របស់គណៈកម្មការដឹកនាំគម្រោង

# ការការពារ និងអភិរក្សសត្វព្រៃ

## ការអភិរក្សសត្វព្រៃ និងជីវចម្រុះ

### ១-ពង្រឹងការថែរក្សាសត្វព្រៃក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍

**ក. ការអន្តរាគមន៍សត្វព្រៃតាមបណ្ដារាជធានី-ខេត្ត**

បានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការ ជួញដូរសត្វព្រៃ នៅខេត្តមណ្ឌលគិរី ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ កោះកុង និងខេត្តរតនគិរី ដោយបានចាប់ឃាត់សាច់សត្វជ្រូកព្រៃចំនួន ៩៦គីឡូក្រាម សាច់សត្វឈ្លូសចំនួន២៩គីឡូក្រាម រណារយន្ត០២គ្រឿង ដោះអន្ទាក់៣០ខ្សែ សត្វត្រកួតរស់ចំនួន១៥ក្បាល សត្វអន្សងរស់ចំនួន០២ក្បាល អណ្ដើករស់ចំនួន០៨ក្បាល និងបានដោះលែងសត្វរស់ចូលទៅព្រៃធម្មជាតិវិញ ព្រមទាំងបានដុតកំទេចចោលសាច់សត្វព្រៃទាំងនោះផងដែរ។





សកម្មភាពនៃការដុតកំទេចវត្ថុតាងសាច់សត្វជ្រូកព្រៃស្រស់ដែលរឹបអូសបានពីជនល្មើស





សកម្មភាពនៃការដោះលែងសត្វព្រៃទៅក្នុងព្រៃធម្មជាតិ

បានសហការជាមួយអង្គការ UNODC បើកវគ្គបណ្ដុះបណ្ដាល សិក្ខាសាលាស្ដីពីបច្ចេកទេសស៊ើបអង្កេតបទល្មើសសត្វព្រៃ ដែលបានប្រព្រឹត្តទៅនៅខែឧសភា និងខែកញ្ញា ឆ្នាំ២០១៩ ដោយមានសិក្ខាកាម ចូលរួមសរុបចំនួន១៤នាក់ និងមានអ្នកចូលរួមសរុបចំនួន៣៤នាក់។





សកម្មភាពនៃការចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសស៊ើបអង្កេតបទល្មើសសត្វព្រៃ

**ខ-ការផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការជួញដូរសត្វព្រៃ និងសារសំខាន់សត្វព្រៃ**

បានសហការជាមួយនឹងរដ្ឋបាលព្រៃឈើមូលដ្ឋាន ចុះធ្វើការផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការជួញដូរសត្វព្រៃ និងសារសំខាន់សត្វព្រៃ នៅខេត្តមណ្ឌលគិរី កំពង់ធំ ពោធិ៍សាត់ និងខេត្តក្រចេះដោយមានប្រជាជនចូលរួម សរុបចំនួន៤៥០នាក់(ស្រី២៧៧នាក់) និងបានចែកជូន ផ្ទាំងរូបភាពអប់រំ៤៥០សន្លឹក និងអាវយឺត៤៥០អាវ។



សកម្មភាពនៃការចុះផ្សព្វផ្សាយស្តីពីការទប់ស្កាត់ ការជួញដូរសត្វព្រៃ និងសារសំខាន់សត្វព្រៃ

**២-ការសិក្សាស្រាវជ្រាវ និងតាមដានវត្តមានសត្វព្រៃ និងជីវចម្រុះ**

ក-ការចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃ

បានចុះសិក្សាស្រាវជ្រាវ តាមដានវត្តមានសត្វព្រៃ នៅក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងតំបន់ព្រៃសហគមន៍ស្ថិតនៅក្នុងខេត្តស្ទឹងត្រែង រតនគិរី ក្រចេះ ឧត្តរមានជ័យ ពោធិ៍សាត់ ព្រៃវែង និងខេត្តព្រះវិហារ ដោយកត់ត្រាថនិកសត្វចំនួន៥៧ប្រភេទ បក្សីចំនួន២៣៣ ប្រភេទ និងឧរង្គសត្វចំនួន ៥៩ប្រភេទ។





ដានជើង និងលាមកសត្វទន្សោងដែលក្រុមការងារបានជួប ក្នុងពេលចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃ



សកម្មភាពនៃការចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃ

បានសហការជាមួយអង្គការ FFI ចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តចំនួន៣៩គ្រឿង ដែលបំពាក់សម្រាប់តាមដានកត្តាគំរាមកំហែងចំពោះសត្វព្រៃ និងសត្វដំរីព្រៃនៅតំបន់ជួរភ្នំក្រវាញក្នុងភូមិសាស្ត្រ ឃុំឫស្សីជ្រុំ ឃុំថ្មដូនពៅ និង ឃុំជីផាត ស្រុកថ្មបាំង និងឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង និងនៅតំបន់ភាគខាងត្បូង និងខាងកើតនៃឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ(គិរីរម្យ) ក្នុងភូមិសាស្ត្រ ភូមិព្រៃប្រសិទ្ធ ភូមិស្ទឹងប្រាល ឃុំកំពង់សិលា ស្រុកកំពង់សិលា ខេត្តព្រះសីហនុ និងភូមិប្រាំមួយ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដោយថតបានថនិកសត្វចំនួន ២១ប្រភេទ ត្រូវជាសត្វព្រៃចំនួន១.០៥០ក្បាល ដូចជា ដំរី ខ្ទីង ខ្លាឃ្មុំតូច ខ្លាពពក ឆ្មាជាវ ខ្លាភ្ញីថ្មកែវ ឆ្កែព្រៃ កាំប្រមា ប្រមោញ សំពោចអុជស្នង ស្វាគ្រោស ជ្រូកព្រៃ ក្ដាន់ញៀញ ខ្ទីង ប្រើស ឈ្លូស ជ្រូកពុល និងអកពស់ព្រៃ។



សត្វដំរីថតបានដោយម៉ាស៊ីនថតស្វ័យប្រវត្តនៅដេប៉ូឈើ តំបន់ថ្មបាំង ខេត្តកោះកុង



ការចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តនៅតំបន់ថ្មបាំង ខេត្តកោះកុង



សត្វខ្លាឃ្មុំតូចថតបានដោយម៉ាស៊ីនថតស្វ័យប្រវត្ត នៅវាលថ្ម តំបន់ថ្មបាំង ខេត្តកោះកុង

-បានចុះធ្វើសម្ភាសន៍ជាមួយប្រជាសហគមន៍ចំនួន ៨៥៦នាក់ (ស្រី៥០១នាក់) នៅខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកណ្ដាល ស្ដីពីការអនុវត្តការយល់ឃើញ និងចំណេះដឹងស្ដីពីការការពារជំងឺឆ្លងពីសត្វមកមនុស្សតាមរយៈការប្រើប្រាស់ និងការជួញដូរសត្វព្រៃ

-បានចុះប្រមូលសំណាកសេរ៉ូម និងឈាមពីប្រជាសហគមន៍ចំនួន ៤៦៥នាក់ ចំនួន ៨ឃុំ ក្នុងខេត្តកណ្ដាល កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពត និងខេត្តកំពង់ចាម ដើម្បីយកទៅវិភាគរកមេរោគដែលអាចឆ្លងពីមនុស្ស-សត្វ-មនុស្ស

-បានចុះប្រមូលសំណាក(ជាលិកា ឈាម ទឹកមាត់ លាមក) ពីពពួកថនិកសត្វតូចៗ និងសត្វប្រចៀវ ចំនួន ១១.៦៧១សំណាក ស្មើនឹង ១.៣០៤ក្បាល ត្រូវជា ៥០ប្រភេទក្នុងនោះ ប្រចៀវចំនួន ៣៥ប្រភេទ ថនិកសត្វតូចៗ(កណ្ដុរនិងសត្វកកេរ)ចំនួន១៥ប្រភេទ ពី០៧ទីតាំង នៅក្នុងខេត្តចំនួន ១៨ គឺ ខេត្តកណ្ដាល កំពង់ចាម កំពង់ស្ពឺ តាកែវ កំពត ព្រះសីហនុ កោះកុង ក្រចេះ កំពង់ធំ សៀមរាប មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង ក្រចេះ ព្រះវិហារ និងខេត្តព្រៃវែង។ សំណាកដែលប្រមូលបានទាំងអស់ត្រូវបានរក្សាទុក និងធ្វើវិភាគនៅវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ និងបសុព្យាបាលនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

-បានរៀបចំទស្សនកិច្ចសិក្សាតំបន់ទេសភាពព្រៃឈើនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី ២៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ដែលមានអ្នកចូលរួមសរុបចំនួន ២៣នាក់ ក្នុងនោះមានប្រតិភូមកពីប្រទេសចិន២នាក់ ថៃ២នាក់ ឡាវ២នាក់ វៀតណាម២នាក់ កម្ពុជា១១នាក់ (រដ្ឋបាលព្រៃឈើ ៦នាក់ ខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ ៤នាក់ ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប ០១នាក់) កងរាជអាវុធហត្ថ ២នាក់ និងអង្គការ APFNet ២នាក់។



កិច្ចប្រជុំប្រចាំឆ្នាំរបស់គម្រោងសិក្សាតាមដានហានិភ័យនៃការចម្លងជំងឺមកមនុស្សពីប៉ារ៉ាស៊ីតរបស់ពពួកថនិកសត្វតូចៗ និងសត្វប្រចៀវ



វគ្គបណ្ដុះបណ្ដាលស្ដីពី កម្មវិធីវិភាគ “R and Occupancy Model Training”





ការសម្ភាសន៍ប្រជាសហគមន៍ អំពី ការអនុវត្តការយល់ឃើញ និងចំណេះដឹងស្ដីពីការការពារជំងឺឆ្លងពីសត្វមកមនុស្សតាមរយៈការប្រើប្រាស់ និងការជួញដូរសត្វព្រៃ




សកម្មភាពនៃការដំឡើងសំណាញ់ចាប់សត្វប្រចៀវដើម្បីប្រមូលសំណាកទឹកមាត់លាមកពិនិត្យជំងឺឆ្លង




ចូលរួមសន្និសីទស្តីពី ការស្រាវជ្រាវសត្វប្រចៀវអន្តរជាតិលើកទី ១៨ នៅខេត្តភូកេត ប្រទេសថៃ




ការប្រមូលយកសំណាកថនិកសត្វតូចៗ និងសត្វប្រចៀវសម្រាប់
ធ្វើតេស្តពិសោធន៍រកជំងឺដែលអាចឆ្លងពីថនិកសត្វតូចៗមកមនុស្ស

**ខ-ជម្លោះរវាងមនុស្ស និងសត្វព្រៃ**

បានរកឃើញមានជម្លោះរវាងមនុស្ស និងសត្វដំរីព្រៃកើតឡើងចំនួន៣៦ករណី ក្នុងនោះ០៦ករណីបានកើតនៅក្នុងភូមិសាស្ត្រភូមិប្រាំមួយ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ០៧ករណី នៅតំបន់ភូមិសាស្ត្រភូមិព្រៃប្រសិទ្ធិ ឃុំអូរបាក់រទេះ ស្រុកកំពង់សិលា ខេត្តព្រះសីហនុ និង ២៣ករណី នៅតំបន់អារ៉ែងភូមិសាស្ត្រ ភូមិថ្មដូនពៅ ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង ។ ដំណាំដែលសត្វដំរីបានបំផ្លាញរួមមានកូនចេកដាំចំនួន៣១០កូន និងដើមចេក ២៣១គុម្ព ដូងដាំ៦៣៣កូន ល្ហុង០៥ដើម ដំឡូងមី ១០រង ផ្លែស្វាយប្រហែល១៤តោន និងកាច់មែកស្វាយអស់១៨៥ដើម ផ្លែខ្នុរ៤០ផ្លែ ស៊ីស្រូវចម្ការអស់ប្រហែល ២៨.៤៧១ម៉ែត្រការ៉េ ពោត១០រង អំពៅ៤០គុម្ព និងដំណាំរួមផ្សំផ្សេងៗ ព្រមទាំងផ្ដួលរលំរបងលួសបន្លាប្រវែង ១០០ម៉ែត្រ ខ្ទមចាំចម្ការមួយខ្នងទំហំ០៦ម៉ែត្រការ៉េ និងទុយយោទឹក២០ម៉ែត្រ។



សកម្មភាពនៃការចែកកាំជ្រួចដល់ប្រជាជនដើម្បីដុតបង្អើលសត្វដំរីព្រៃដែលតែងតែមកបំផ្លាញដំណាំ និងផ្ទះទាំងនោះ

**គ-ការសិក្សាស្រាវជ្រាវរុក្ខជាតិកេសរកូល(អ័រគីដេព្រៃ)**

បានចុះប្រមូលសំណាករុក្ខជាតិកេសរកូល(អ័រគីដេព្រៃ) នៅខេត្តស្ទឹងត្រែង ពោធិ៍សាត់ មណ្ឌលគិរី កោះកុង ព្រះវិហារ និងខេត្តសៀមរាប បានចំនួន៨៩៣សំណាកត្រូវជា ៩១ប្រភេទ។ សំណាកទាំងនេះ ក្រុមការងារបានយកមកថែរក្សានៅក្នុងសួនអ័រគីដេភ្នំពេញថ្មីសម្រាប់តាមដានបន្តអំពីដំណុះពូជរុក្ខជាតិទាំងនេះ។





សកម្មភាពចុះប្រមូលសំណាកកេសកូលព្រៃក្នុងព្រៃធម្មជាតិ ខេត្តកុះកុង ព្រះវិហារ និងខេត្តសៀមរាប

**ឃ-ការសិក្សាស្រាវជ្រាវតំបន់ដែលមានសក្ដានុពលសម្រាប់ទេសចរណ៍ធម្មជាតិ**

បានចុះសិក្សាព្រៃឈើសហគមន៍ប្រាំបីមុំ ស្ថិតនៅក្នុងឃុំប្រាំបីមុំ ស្រុកថ្លុង ខេត្តកំពង់ស្ពឺ ដើម្បីកំណត់តំបន់ព្រៃឈើដែលមានសក្ដានុពលសម្រាប់ទេសចរណ៍ធម្មជាតិ។ ជាលទ្ធផលពិនិត្យឃើញថា តំបន់សហគមន៍ប្រាំមុំនេះមានសក្ដានុពលសម្រាប់មើលសត្វព្រៃ ពិសេសសត្វទន្សោង រួមទាំងសកម្មភាពកំសាន្តផ្សេងៗជាច្រើន ដែលធ្វើឲ្យភ្ញៀវ

ទេសចរណ៍អាចធ្វើដំណើរដោយទោចក្រយានយន្ត ឬក៏ ដោយថ្មើរជើងក្នុងការទស្សនាព្រៃឈើ និងសត្វព្រៃក្នុង តំបន់សហគមន៍។





សកម្មភាពនៃការបំពាក់ម៉ាស៊ីនថតស្វ័យប្រវត្តដើម្បី តាមដានវត្តមានសត្វទន្សោងនៅ សហគមន៍ប្រាំបីមុំ



ហ្វូងសត្វទន្សោងថតបានដោយម៉ាស៊ីនថតស្វ័យប្រវត្ត នៅសហគមន៍ប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ





ការត្រួតពិនិត្យមើលដានជើងឆ្លងកាត់ និងលាមកសត្វទន្សោង នៅសហគមន៍ប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

## ៣-ពង្រឹងការត្រួតពិនិត្យ ការចិញ្ចឹមសត្វព្រៃ តាមគ្រួសារ កសិដ្ឋាន និងសួនសត្វ

-បានផ្តល់លិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈ គ្រួសារជូនប្រជាពលរដ្ឋចំនួន៤១ច្បាប់ ក្នុងនោះ៣០ច្បាប់ សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង១១ច្បាប់សម្រាប់ ការថែរក្សាសត្វព្រៃប្រភេទផ្សេងទៀតដែលមានទីតាំងស្ថិត នៅរាជធានី ភ្នំពេញ ខេត្តកំពង់ចាម ព្រៃវែង កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ កោះកុង តាកែវ សៀមរាប បន្ទាយមានជ័យ រតនគិរី និងខេត្តមណ្ឌលគិរី។

-បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូន ក្រុមហ៊ុនជាត់ ភ្នំពេញ ឯ.ក ចំនួន២ច្បាប់ មានសត្វដំរីស្រុក

ញីចំនួន២ក្បាល ដឹកចេញពីស្រុកកែវសីមា ខេត្តមណ្ឌលគិរី ឆ្ពោះទៅកាន់សួនសត្វភ្នំពេញសាហ្វារី

-បានរៀបចំប្រកាសស្តីពីការដាក់ឲ្យប្រើគំរូលិខិតអនុញ្ញាតនាំចូល នាំចេញសត្វព្រៃមានដោយបង្ហូរដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ និងសម្រេច។

-បានផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ ១៧៧៩ រព.នសជ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការបំពេញបែបបទចុះបញ្ជីថែរក្សា ឬចិញ្ចឹមសត្វត្រចៀកកាំ ជាលក្ខណៈគ្រួសារ ជូនទៅគ្រប់ខណ្ឌរដ្ឋបាលព្រៃឈើរាជធានីខេត្ត និងបណ្តាញសង្គម





ការចុះត្រួតពិនិត្យសំណើ និងផ្តល់លិខិតអនុញ្ញាតចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារ

-បានចុះជំរុញការចុះបញ្ជីថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន២៩លើកត្រូវជា ២៦២ទីតាំង នៅខេត្តចំនួន ២០ ក្នុងនោះមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ កំពត ព្រះសីហនុ កោះកុង កំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង សៀមរាប ព្រះវិហារ កំពង់ធំ រតនគិរី បាត់ដំបង កែប ក្រចេះ ស្វាយរៀង ព្រៃវែង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តតាកែវ។







សកម្មភាពនៃការចុះត្រួតពិនិត្យទីតាំងស្នើសុំថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសារ

## ការគ្រប់គ្រងឧទ្យានសួនសត្វ និងសង្គ្រោះថែរក្សាសត្វព្រៃ

ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅបាននិងកំពុងអនុវត្តអនុកម្មវិធី៤.៣ ស្ដីពី "**ការគ្រប់គ្រងឧទ្យានសួនសត្វ និងសង្គ្រោះថែរក្សាសត្វព្រៃ**" មានគោលបំណងចូលរួមដើម្បីបង្កើនការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព។ ក្នុងឆ្នាំ២០១៩ នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ បានសម្រេចលទ្ធផលការងារដូចខាងក្រោម៖

### ១-ការសង្គ្រោះ ព្យាបាល និងថែរក្សាសត្វព្រៃ

បានសង្គ្រោះសត្វថ្មីចំនួន១ ១០៥ក្បាល ព្យាបាលសត្វព្រៃបានចំនួន២៧០ក្បាល។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងថែរក្សាសត្វព្រៃចំនួន១ ៤៨៦ក្បាល( បក្សី ៥៥ប្រភេទ ថនិកសត្វ៤៣ប្រភេទ និងល្មូន១៦ប្រភេទ)។



ការដកធ្មេញពុកស្អុយ លាងសម្អាតធ្មេញ និងការបូមយកស្លេសក្នុងសួតខ្លាឃ្មុំយកទៅមន្ទីរពិសោធន៍ពិនិត្យមើលជំងឺរបេង

### ២-ការស្ដារសត្វព្រៃឡើងវិញ

បានស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន **១ ៣៥២**ក្បាល។ ដោយឡែកគម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិមានដូចខាងក្រោម៖

-ក្រុមល្បាតសហគមន៍ចំនួន៣០នាក់បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន០៥ គឺ នៅអារ៉ែងឆាយរាប តំបន់ស្ដារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិសាត់)

-ដោះលែងក្រពើភ្នំពូជសុទ្ធ ២០ក្បាលទៅក្នុងដែនជម្រកធម្មជាតិនៅស្ទឹងខៀវ ខេត្តកោះកុង

-សហការជាមួយអង្គការកសិកម្មព្រហ្មវិហារធម៌ផ្ដល់ការប្រឹក្សាបច្ចេកទេស និងបណ្ដុះបណ្ដាលជូនប្រជាសហគមន៍ ២៥៣នាក់លើបច្ចេកទេសចិញ្ចឹមសត្វ បច្ចេកទេសដំណាំស្រូវដល់កសិករ៧១នាក់ បច្ចេកទេសចម្រាញ់ប្រេងស្លឹកគ្រៃជូនកសិករចំនួន០៦នាក់ បច្ចេកទេសការសន្សំ និងគ្រប់គ្រងការចំណាយប្រាក់ ដល់ប្រជាសហគមន៍ចំនួន១៩នាក់។

-តាមដានប្រចាំឆ្នាំវត្តមានក្រពើភ្នំតាមវិធីសាស្ត្រពំនុះកាត់ទទឹងដែនជម្រកនៅតំបន់ឆាយរាប អូរសោម ស្ទឹងដាច់ ដំណាក់ភ្លង ស្ទឹងអារ៉ែង ស្ទឹងខៀវ បានរកឃើញលាមកក្រពើភ្នំ៩៣ដុំ ដានជើង៤២កន្លែង និងឃើញក្រពើផ្ទាល់ ១២ក្បាល

-តាមដានក្រពើភ្នំដែលបានដោះលែងក្នុងឆ្នាំ២០១៨ តាមរយៈ Radio tracking បានរកឃើញក្រពើភ្នំលែងចំនួន០៧ក្បាល និងស្នាមដាន០១កន្លែង

-ចុះស្រាវជ្រាវក្រពើភ្នំនៅភូមិសាស្ត្រដែនជម្រកសត្វព្រៃស្រែពកបានរកឃើញលាមកក្រពើ១២ដុំ និងបានជួយហ្វឹកហ្វឺនមន្ត្រីបរិស្ថានលើការងារស្រាវជ្រាវក្រពើភ្នំ ចំនួន ១២នាក់

-បានចុះសិក្សាស្វែងរកតំបន់សក្ដានុពលសម្រាប់ទេសចរណ៍ធម្មជាតិបានមួយកន្លែង។

-ដាក់ Camera ស្វ័យប្រវត្តរកឃើញក្ងោក០៤ក្បាល មាន់ទឹក០២ក្បាល លលក០១ក្បាល ស្វាំង០១ក្បាល និងសំពោច០១ក្បាល

-ចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការហាមឈូសឆាយ កាប់ឆ្ការ ដុត រុករានដីព្រៃឈើយកជាកម្មសិទ្ធិដល់ប្រជាពលរដ្ឋនៅភូមិពោធិ៍បឹង ឃុំដងពែង ស្រុកថ្មបាំង ខេត្តកោះកុងចំនួន២៥នាក់

-បណ្តុះបណ្តាលប្រជាសហគមន៍ នៅអូរសោម ស្រុកវាលវែង និងនៅដងពែង ស្រុកស្រែអំបិលអំពីបច្ចេកទេសសាងសង់ទ្រុងមាន់ ជ្រើសពូជ ផលិតចំណីជ្រូក និងបច្ចេកទេសរៀបចំដី ជ្រើសរើសពូជស្រូវ ផលិតជីសរីរាង្គ និងផលិតថ្នាំសម្លាប់សត្វចង្រៃបែបធម្មជាតិបាន៧៦១នាក់ (ស្រី៤៤១នាក់)

-ស្វែងរកបានការគាំទ្រពីកសិដ្ឋានចំនួន០២នៅខេត្តសៀមរាប ក្នុងការចូលរួមចំណែកអភិរក្សក្រពើភ្នំ និងបានផ្តល់ក្រពើបាចំនួន០២ក្បាល និងកូនតូចៗចំនួន៥០ក្បាល





សកម្មភាពយកក្រពើភ្នំទៅដោះលែងនៅក្នុងដែនជម្រកធម្មជាតិស្ទឹងខៀវ ខេត្តកោះកុង

-រៀបចំសិក្ខាសាលាស្តីពី " ភាពជាដៃគូរបស់សហគមន៍មូលដ្ឋានក្នុងការអភិរក្ស" ដើម្បីពង្រឹងការយល់ដឹងផ្នែកបរិស្ថាន និងការចូលរួមរបស់សហគមន៍ក្នុងការអភិរក្សក្រពើភ្នំ និងដំរីព្រៃ និងការបូកសរុបលទ្ធផលការងារចែករំលែកបញ្ហាប្រឈម និងដំណោះស្រាយ

-បញ្ជូនសំណាកឈាមក្រពើ ចំនួន ៥២សំណាកទៅកាន់សាកលវិទ្យាល័យភូមិន្ទភ្នំពេញដើម្បីវិភាគ DNA រកក្រពើភ្នំពូជសុទ្ធ

-ចែកសៀវភៅសិក្សាដល់សិស្សានុសិស្ស ចំនួន ៣០០នាក់ នៅសាលាបឋមសិក្សាភូមិពោធិ៍បឹងកំលោតអូរសំរោង និងត្រើងស្អែកនូវសៀវភៅសរសេរចំនួន ៥០ក្បាល ប៊ិក ចំនួន៣០០ដើម និងខ្មៅដៃ ចំនួន៣០០ដើម។

### ៣- ការជួសជុល និងថែទាំ

ជួសជុលផ្លូវក្រាលគ្រួសក្រហមបានប្រវែង១៥ ១០៦ម និងជួសជុលផ្លូវភ្លើងបានប្រវែង២១ ០០០ម កាប់ឆ្ការអនាម័យព្រៃបានទំហំ៥២ហិកតា។





ការជួសជុលផ្លូវភ្លើងដើម្បីបង្ការទប់ស្កាត់ភ្លើងឆេះព្រៃ

# ការគ្រប់គ្រង និងអភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ ពាណិជ្ជកម្ម និងសហប្រតិបត្តិការអន្តរជាតិ

## ១-ការងារឧស្សាហកម្មព្រៃឈើ

ចុះពិនិត្យសិក្សា និងវាយតម្លៃទីតាំងជាក់ស្តែងចំពោះ៖

-បង្កើតរោងម៉ាស៊ីនកែច្នៃឈើចំនួន ០៩ ក្រុមហ៊ុន ស្មើនឹង ០៩កន្លែង

-ពន្យារសុពលភាពរោងម៉ាស៊ីនកែច្នៃឈើមានចំនួន ២០ក្រុមហ៊ុន ស្មើនឹង២៣កន្លែង

-សិក្សាអគ្រាកែច្នៃឈើចំនួន ០៥ក្រុមហ៊ុន ស្មើនឹង ០៦កន្លែង។







ការងារឧស្សាហកម្មព្រៃឈើ

-បង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន០១ក្រុមហ៊ុន ស្មើនឹង០១កន្លែង។

## ២-ការងារពាណិជ្ជកម្មផលិតផលព្រៃឈើ

### ២.១- ការនាំចេញផល អនុផលព្រៃឈើ

-នាំចេញផលិតផលរានទេវតា គ្រឿងសង្ហារិម និងឈើកែច្នៃទៅក្រៅប្រទេស(ជប៉ុន អាមេរិក ចិន វៀតណាម និងថៃ) មានបរិមាណចំនួន ២ ៣៣១ម៣ (ពីរពាន់បីរយសាមសិបមួយម៉ែត្រគ្រីគុណ) និងជ័រទឹកចំនួន ៣១១តោន (បីរយដប់មួយតោន) ដោយក្រុមហ៊ុនចំនួន ០៧







ចុះពិនិត្យផលិតផល ផល-អនុផលព្រៃឈើ
ដើម្បីផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញ

-ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ១៣ មានបរិមាណផលិតផលឈើកែច្នៃចំនួន ៣ ០៨០ម$^{៣}$ (បីពាន់ប៉ែតសិបម៉ែត្រគ្រីគុណ) ឈើអាកាស្យាកាត់ជាកង់ៗ ចំនួន ១ ៦៣២ស្ទេរ(មួយពាន់ប្រាំមួយរយសាមសិបពីរស្ទេរ) និង អនុផលព្រៃឈើចំនួន ៣៥៨តោន (បីរយហាសិបប្រាំបីតោន)។

**២.២-ការនាំចូលផល អនុផលព្រៃឈើ**

-នាំចូលផលិតផលឈើកែច្នៃមានបរិមាណចំនួន ១ ៨៤៣ម$^{៣}$ (មួយពាន់ប្រាំបីរយសែសិបបីម៉ែត្រគ្រីគុណ) ដោយក្រុមហ៊ុនចំនួន ០៤

-ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ០៤ មានបរិមាណផលិតផលឈើកែច្នៃ (Wood Panel, CHANFUTA, MDF, DOUSSIE និង MUSSIVI) ចំនួន ១ ៧៥២ម$^{៣}$(មួយពាន់ប្រាំពីររយហាសិបពីរម៉ែត្រគ្រីគុណ)។



ចុះពិនិត្យផ្ទៀងផ្ទាត់ផលិតផលឈើកែច្នៃនៅពេលនាំចូល

## ៣-ការងារឥណទានកាបូនព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការប្រែប្រួលអាកាសធាតុ ចំនួន០២លើក (ស្រុកសំឡូត ខេត្តបាត់ដំបង និងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់) ចូលរួមកិច្ចប្រជុំក្នុងប្រទេសចំនួន ១០លើក សិក្ខាសាលាចំនួន ០៩លើក និង ចូលរួមប្រជុំក្រៅប្រទេសចំនួន ០២លើក។



សកម្មភាពរៀបចំ និងបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពីការប្រែប្រួលអាកាសធាតុ នៅស្រុកសំឡូត ខេត្តបាត់ដំបង





សកម្មភាពរៀបចំ និងបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពីការប្រែប្រួលអាកាសធាតុ នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

## ៤-ការងារសហប្រតិបត្តិការអន្តរជាតិ

-សម្របសម្រួលទំនាក់ទំនងការងារ និងរៀបចំលិខិតជូនថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលព្រៃឈើសរុបចំនួន ៥៦នាក់ ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចូលរួមកិច្ចប្រជុំក្រៅប្រទេសចំនួន ២៨លើក សិក្ខាសាលាក្រៅ

ប្រទេសចំនួន២៦លើក សន្និសីទក្រៅប្រទេសចំនួន ០៧លើក ទស្សកិច្ចសិក្សាក្រៅប្រទេសចំនួន០៥លើក និងវេទិកាក្រៅប្រទេសចំនួន ០៣លើក

-គម្រោងសហប្រតិបត្តិការអន្តរជាតិក្នុងរដ្ឋបាលព្រៃឈើសរុបចំនួន ១០គម្រោង រួមមាន៖

១-គម្រោង Promotion of forest rehabilitation in Cambodia and Vietnam through demonstration needs and improvement of seed supply system អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

២-គម្រោង Establishment of forest genetic areas for forest restoration in Cambodia អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

៣-គម្រោង Integrated Forest Ecosystem Management Planing and demonstration Project in Great Mekong Sub-region អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

៤-គម្រោង Research and Development (R&D) of Cambodia Natural Fiber Composites for Industrial Application អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

៥-គម្រោង Korea-Cambodia REDD+ Joint Project (KCRP) អនុវត្តដោយនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

៦-គម្រោង The establishment of Korea-Cambodia Natural Recreation Forest Model Phase I អនុវត្តដោយនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

៧-គម្រោង Sustainable forest Management through REDD+ Mechanism in Kompong Thom អនុវត្តដោយនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

៨-គម្រោង Biological Control of Galling Insect Pests of Eucalypt Plantation in the Mekong Region អនុវត្តដោយនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃជាំ និងព្រៃឯកជន

៩-គម្រោង Forest Restoration and Promotion of Sustainable Forest Use in Southeast Asia អនុវត្តដោយនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

១០-គម្រោង Investigating the Risk of Human Disease from Parasites of Small Mammals and Buts អនុវត្តដោយនាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ។



ចូលរួមកិច្ចប្រជុំលើកទី៦នៃគណៈកម្មការសហប្រតិបត្តិការព្រៃឈើកូរ៉េ-មេគង្គ ឆ្នាំ២០១៩ នៅប្រទេសមីយ៉ាន់ម៉ា




ពិព័រណ៍ស្តង់ AFoCO ក្នុងព្រឹត្តិការណ៍សប្តាហ៍ព្រៃឈើ អាស៊ីប៉ាស៊ីហ្វិក ឆ្នាំ២០១៩ នៅទីក្រុងអ៊ីនឆន់ សាធារណរដ្ឋកូរ៉េ




ពិធីបិទកម្មវិធី Fellowship Program ឆ្នាំ២០១៩ នៅការិយាល័យលេខាធិការដ្ឋាន AFoCO

# ការសិក្សាស្រាវជ្រាវផលិតថង់បណ្ដុះកូនឈើ ដែលផ្ទុកសារធាតុចិញ្ចឹម និងងាយរលាយក្នុងធម្មជាតិ

ដោយ៖ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

បច្ចុប្បន្នកាកសំណល់ថង់ផ្លាស្ទិចបានក្លាយជាកង្វល់ដ៏ធំរបស់ពិភពលោក។ នៅក្នុងវិស័យព្រៃឈើថង់ផ្លាស្ទិចក៏ត្រូវបានគេប្រើប្រាស់យ៉ាងច្រើនផងដែរសម្រាប់បណ្ដុះកូនឈើ មុនពេលគេយកកូនឈើទាំងនោះទៅដាំនៅទីវាល។ ក្រោយពេលដាំ ថង់ផ្លាស្ទិចទាំងនេះត្រូវបានគេក្រវាត់ចោលនៅលើទីវាលទាំងនោះ ដែលបង្កជាកាកសំណល់បំពុល និងបាត់បង់សោភ័ណភាពបរិស្ថានរស់នៅ។ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយបញ្ហានេះ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ បានសហការជាមួយ Korea Institute of Material Sciences នៃសាធារណរដ្ឋកូរ៉េ ធ្វើការសិក្សាស្រាវជ្រាវផលិតថង់បណ្ដុះកូនឈើសរីរាង្គ សម្រាប់ប្រើប្រាស់ក្នុងការបណ្ដុះកូនឈើ។ ការសិក្សាស្រាវជ្រាវនេះដឹកនាំ និងអនុវត្តដោយបណ្ឌិត **សុខ ហេង** ប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ និងលោក **តាល់ មករា** មន្ត្រីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ នៃរដ្ឋបាលព្រៃឈើ។

លក្ខណៈសម្បត្តិសំខាន់ៗនៃថង់បណ្ដុះកូនឈើសរីរាង្គនេះរួមមាន ពេលដាំកូនឈើមិនចាំបាច់យកថង់ចេញដែលអាចរង្គើដល់ឫស និងជួយឲ្យកូនឈើមានអត្រារស់ខ្ពស់ និងចំណេញពេលវេលា។ ម្យ៉ាងវិញទៀតថង់បណ្ដុះកូនឈើប្រភេទនេះផ្ទុកសារធាតុជាតិ NPK ស្រាប់ និងមានសមត្ថភាពក្នុងការស្រូបយកទឹក ឬសំណើមខ្ពស់ដែលមានសារប្រយោជន៍ចំពោះការដាំកូនឈើនៅតំបន់ដែលមិនសូវមានភ្លៀងធ្លាក់។

## វិធីសាស្ត្រធ្វើ

# វត្ថុធាតុដើមសំខាន់ៗដែលមានក្នុងការស្រាវជ្រាវផលិតថង់បណ្ដុះរួមមាន ម្សៅសំបកបង្គា PVA (Polyvinyl Alcohol) ម្សៅដំឡូងមី ឬម្សៅពោត ជីអ៊ុយរ៉េ ឬ DAP (ដាក់ក៏បានមិនដាក់ក៏បាន)។ រយៈពេលរលាយក្នុងធម្មជាតិនៃថង់បណ្ដុះកូនឈើ អាចកំណត់បានតាមតម្រូវការរបស់កូនឈើ តាមរយៈការកំណត់បរិមាណនៃវត្ថុធាតុដើមទាំងនេះនៅពេលផលិត។




ការបង្កើតសូលុយស្យុងដើម្បីផលិតថង់



ថង់កូនឈើដែលបានផលិតរួច

ក្នុងការស្រាវជ្រាវនេះ ថង់បណ្ដុះកូនឈើមានបីប្រភេទត្រូវផលិតរួមមាន ១). ថង់បណ្ដុះកូនឈើដែលរលួយរយៈពេលខ្លី(ក្រោម៨ខែ) ត្រូវលាយម្សៅដំឡូងមី៤៥% PVA ៣០% និង ម្សៅបង្គា២៥% ២).ថង់បណ្ដុះកូនឈើដែលរលួយរយៈពេលមធ្យម(១៥ខែ) ត្រូវលាយម្សៅដំឡូងមី ២០% ម្សៅ PVA ៥០% និងម្សៅបង្គា៣០% និង៣). ថង់រលួយរយៈពេលវែង (៣ឆ្នាំ) ត្រូវលាយម្សៅដំឡូងមី ៥% ម្សៅ PVA ៧០% និងម្សៅបង្គា ៣៥%។



កូនឈើក្នុងថង់សរីរាង្គ

## លទ្ធផលនៃការស្រាវជ្រាវ

ថង់ទាំងបីប្រភេទដែលបានផលិតខាងលើត្រូវបានពិសោធន៍ក្នុងការដាំកូនឈើនៅថ្នាលបណ្ដុះកូនឈើរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ។ យោងតាមលទ្ធផលពិសោធន៍បង្ហាញថា កូនឈើដែលបណ្ដុះក្នុងថង់ដែលផ្ទុកសារធាតុចិញ្ចឹម និងរលួយដោយធម្មជាតិមានសុខភាពល្អ។ ថង់បណ្ដុះកូនឈើប្រភេទទី១ មានការពុកផុយលឿនដោយមានផ្សិតជាភ្នាក់ងារបំបែកថង់ប្រភេទនេះឲ្យវារលួយលឿន(លាយម្សៅដំឡូងមី៤៥%)។ ថង់កូនឈើប្រភេទនេះមានលក្ខណៈសមស្របសម្រាប់ប្រើប្រាស់ក្នុងការបណ្ដុះកូនឈើអាកាស្យា និងប្រេងខ្យល់។ ចំពោះថង់បណ្ដុះកូនឈើប្រភេទទី២ រំលាយយឺតជាងដោយសារម្សៅដំឡូងមីមានចំនួនតិចជាង៣០%។ ថង់ប្រភេទនេះមានលក្ខណៈសមស្របអាចប្រើប្រាស់ចំពោះ ប្រភេទកូនឈើហូបផ្លែ។ ដោយឡែកថង់បណ្ដុះកូនឈើប្រភេទទី៣ ពុកផុយយឺតជាងគេដោយសារតែលាយម្សៅដំឡូងមីតិចបំផុត(៥%)និងអាចប្រើប្រាស់សម្រាប់បណ្ដុះកូនឈើបេង គ្រញូង និងប្រភេទឈើផ្សេងៗទៀត។

បច្ចុប្បន្នការសិក្សាស្រាវជ្រាវនេះ កំពុងត្រូវបានធ្វើបន្តដើម្បីបង្កើនគុណភាព បន្ថយកម្រាស់ថង់ និងកាត់បន្ថយថ្លៃដើម សំដៅឈានទៅរកការផលិតថង់បណ្ដុះកូនឈើសរីរាង្គជាលក្ខណៈឧស្សាហកម្ម ដើម្បីអាចប្រើប្រាស់បានទូលំទូលាយ ចូលរួមកាត់បន្ថយការបំពុលបរិស្ថាន៕



ការពិនិត្យការលូតលាស់របស់កូនឈើ និងបម្រែបម្រួលថង់បណ្ដុះកូនឈើរយៈពេលវែង(ឆ្វេង) រយៈពេលមធ្យម(កណ្ដាល) ថង់រយៈពេលខ្លី (ស្ដាំ) ក្នុងរយៈពេល៣ខែ

# ការផលិតកូនអាកាស្យា តាមរយៈការកាត់ត្រួយមែកអាកាស្យាបណ្ដុះ

*ដោយ នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន នៃរដ្ឋបាលព្រៃឈើ*

បច្ចុប្បន្នតម្រូវការប្រើប្រាស់ឈើលើពិភពលោកកំពុងមានការកើនឡើងយ៉ាងខ្លាំង សម្រាប់ធ្វើលំនៅដ្ឋាន គ្រឿងសំណង់ ឈើថាមពល គ្រឿងសង្ហារឹម និងសម្ភារប្រើ ប្រាស់ក្នុងការិយាល័យជាដើម។ ផ្អែកតាមទិន្នន័យស្ថិតិព្រៃឈើរបស់រដ្ឋបាលព្រៃឈើបានបង្ហាញថា កម្ពុជាបាននាំចូលបន្ថែមនូវប្រភេទឈើអារ ឈើមូល ឈើកែច្នៃ ឈើអារស្រស់ ឈើជ្រុង និងឈើហ៊ុបជ្រុងប្រណិតជាដើម។ ចំពោះការនាំចេញនូវផលិតផលឈើវិញមានដូចជា ឈើឈូសមុខ ២-៤ ឈើក្ដារក្រាល ឈើជ្រុងទោល ឬបន្ទារអតិបរមា ២៥ស.ម ឈើដាំកែច្នៃ (អាកាស្យា និងប្រេងខ្យល់) និងឈើដើមចន្ទក្រស្នា។ ដោយមើលឃើញពីតម្រូវការប្រើប្រាស់ឈើក្នុងស្រុកមានការកើនឡើង ស្របពេលដែលធនធានព្រៃឈើធម្មជាតិមានការថយចុះ ដូច្នេះការផលិតកូនឈើអាកាស្យាតាមរយៈការកាត់ត្រួយបណ្ដុះ ជាបច្ចេកទេសល្អបំផុតសម្រាប់ការដាំឈើធ្វើពាណិជ្ជកម្ម និងដាំស្ដារព្រៃឈើឡើងវិញ។

បច្ចេកទេសក្នុងការកាត់ត្រួយមែកបណ្ដុះ ត្រូវបានអនុវត្តតាមជំហានសំខាន់ៗដូចខាងក្រោម៖

### ១-ការរៀបចំជ្រើសរើស និងដាំដើមមេ

ការដាំដើមមេអាកាស្យាគួរតែត្រូវបានជ្រើសរើសដើមដែលមានសុខភាពល្អ លូតលាស់លឿន និងធន់ទ្រាំនឹងជំងឺ។ ជាទូទៅគួរតែយកដើមដែលបានផលិតចេញពីជាលិកា (Tissue Culture) ដើមត្រង់ មែកតូចៗ និង មានសុខភាពល្អ គ្មានជំងឺ និងសត្វស៊ីស្លឹក។ ដើមដែលមានអត្រាដុះឫសយ៉ាងហោចណាស់ ៧០ភាគរយ។ ជាទូទៅការដាំដើមមេសម្រាប់កាត់ត្រួយមែក គឺមានគម្លាតចន្លោះដើមប្រមាណជា ៥០-៨០ស.ម តែប៉ុណ្ណោះ។

### ២-ការបង្កើតខ្នែងពីដើមមេ

ដើមអាកាស្យាដែលទើបនឹងដាំបានរយៈពេល ២ ទៅ ៣ខែ បន្ទាប់មានការលូតលាស់រឹងមាំ ត្រូវបានកាច់ផ្ដួលដើមនៅកម្ពស់ប្រមាណជា ២០-៣០ស.ម ពីដី(រក្សាឲ្យជាប់ដើមកុំឲ្យដាច់ពីគ្នា)។ ការធ្វើបែបនេះ គឺវាអាចកាត់បន្ថយកុំឲ្យដើមនោះងាប់ ឬក៏ងាប់ក្នុងបរិមាណតិចតួចបន្ទាប់ពីកាប់រំលំរួចហើយ ដើមនោះគួរតែស្រោចទឹកភ្លាមៗ និងដាក់ជីផងដែរ។

តាមការស្រាវជ្រាវបានបង្ហាញថា កំណាត់មែកដែលទទួលបានពីកូនឈើ ឬខ្នែងខ្ចីដែលមានលក្ខណៈពេញវ័យគ្រប់គ្រាន់មិនចាស់ពេក និងមិនខ្ចីពេក ដែលបានដុះចេញពី ដើមដែលបានផ្ដួលរំលំគឺមានអាត្រាដុះឫសខ្ពស់។





រូបភាពដើមមេ និងខ្នែងដុះចេញពីដើមមេអាកាស្យា hybrid

រយៈពេលសមស្របសម្រាប់ការកាប់រំលំដើមមេគួរតែចាប់ផ្ដើមធ្វើមុនរដូវភ្លៀង ជាពេលដែលមានការផ្គត់ផ្គង់ជីជាតិគ្រប់គ្រាន់ និងការលូតលាស់ដើមមេបានពេញលេញ។ ជាទូទៅក្រោយការកាត់រំលំ ដើមមេមានការដុះត្រួយរយៈពេល ២-៣សប្ដាហ៍ អាស្រ័យទៅលើការស្រោចទឹក និងកត្តា អាកាសធាតុផងដែរ។ ខ្នែងដែលល្អបំផុតគឺមានអាយុ ២ ទៅ ៣ខែ ដែលមានអត្រានៃដំណុះពី ៨០-៩៧%។

## ៣-ការរៀបចំថ្នាលសម្រាប់កាត់ត្រួយបណ្ដុះ ឬគូន

ថ្នាលសម្រាប់ដាក់បណ្ដុះត្រួយអាកាស្យា លៃយ៉ាងណាឲ្យមានសភាពស្រោះទឹកល្អ (មិនជាំទឹក) ដែលអាចនឹងប៉ះពាល់ដល់កូនឈើក្នុងថ្នាល ត្រូវការពារការរាលដាលជំងឺផ្សិត និងសត្វល្អិតជាដើម។ ទីតាំងថ្នាលដែលមានពន្លឺគ្រប់គ្រាន់ និងមិនចំទិសខ្យល់បក់ខ្លាំងជាកន្លែងល្អបំផុតសម្រាប់ការងារកាត់ត្រួយបណ្ដុះ។

### *ក.ការរៀបចំឃ្លប់*

ឃ្លប់ដាក់កូនឈើជាគ្រោងឆ្អឹងធ្វើអំពីដែក និងគ្របប្លាស្ទិចពីលើនៅជុំវិញ ដើម្បីធានានូវការភាយចេញសំណើមទៅបរិយាកាសខាងក្រៅ រក្សាសំណើមបានខ្ពស់ រក្សាសីតុណ្ហភាពបានទាប ទប់ទល់ល្បឿនខ្យល់បក់មកពីខាងក្រៅដែលអាចប៉ះពាល់ដល់កំណាត់មែក ការពារកំណាត់មែកក្នុងករណីភ្លៀងធ្លាក់ខ្លាំង ការពារពីការយាយីនៃពពួកសត្វចង្រៃនានា។

### *ខ.ការរៀបចំសំណាញ់បៃតង*

សំណាញ់បៃតងអាចកាត់បន្ថយពន្លឺថ្ងៃបាន៣០-៦០% ដែលចាំងចូល និងកម្ដៅព្រះអាទិត្យដែលមានឥទ្ធិពលយ៉ាងខ្លាំងដល់ការងារពិសោធន៍នេះ និងអាចកាត់បន្ថយល្បឿនខ្យល់បក់បានមួយចំនួនផងដែរ។

### *គ.ការរៀបចំប្រព័ន្ធស្រោចស្រព*

ប្រព័ន្ធស្រោចស្រពជាកត្តាសំខាន់សម្រាប់ការងារពិសោធន៍នេះ ចាំបាច់ត្រូវមានទឹកគ្រប់គ្រាន់ ទឹកថ្លាល្អ (pH= ៥.៥- ៦.៥) ជៀសវាងប្រើប្រាស់ទឹកល្អក់ ដែលអាចមានកករជាប់នឹងស្លឹករបស់វា ធ្វើឲ្យកំណាត់មែកមិនអាចដកដង្ហើមបានបណ្ដាលឲ្យវាងាប់ (រយៈពេលនេះ កំណាត់មែកដកដង្ហើមតាមស្លឹក)។

ចំណុចសំខាន់ក្នុងការរៀបចំប្រព័ន្ធទឹកគឺលៃយ៉ាងណាឲ្យមានទឹកជាប្រចាំ ម៉ូទ័របូមទឹកត្រូវរុញទឹកក្នុងសម្ពាធខ្ពស់ ដើម្បីបាញ់ទឹកជាចំហាយ (ដំណក់ទឹកតូចៗ)។

## ៤-ការរៀបចំកាត់ត្រួយអាកាស្យា

សកម្មភាពសំខាន់ៗត្រូវអនុវត្តមានដូចខាងក្រោម៖

- រៀបចំដីច្រក់ថង់ ឬកញ្ជ្រែងបានរួចរាល់ ដោយបាញ់ទឹកលាយជាមួយថ្នាំសម្លាប់ផ្សិតជាមុន ដើម្បីការពារការរាតត្បាតនៃជំងឺ
- ដីថ្នាលផ្សំត្រូវលាយមានសមាសធាតុផ្សេងៗដូចជាដីល្បាយខ្សាច់ ជីកំប៉ុស្ដិ៍ ឬភីត និងអាចម៍រណារជាដើម
- ល្បាយផ្សំក្នុងការបណ្ដុះឫស មានសារសំខាន់ណាស់ ព្រោះថាកំណាត់មែកផ្សំភាគច្រើនដុះឫសល្អលើដីល្បាយ ដែលមានខ្យល់អុកស៊ីសែនគ្រប់គ្រាន់ ទប់សំណើមបានល្អ មិនជាំទឹក រន្ធដោតមែកផ្សំត្រូវទប់កំណាត់មែកមិនឲ្យទ្រេត និងបង្កលក្ខណៈឲ្យឫសដុះ និងសមាសធាតុផ្សំគឺមិនបង្កជាជំងឺផ្សិត ឬឆ្លងជំងឺ។



ការកាត់ត្រួយអាកាស្យា Hybrid

មុនពេលកាត់ត្រួយ ត្រូវរៀបចំសម្ភារដូចជា កន្ត្រៃ ធុងស្នោ ទឹក ដែលអាចរក្សាកំណាត់មែកមិនឲ្យត្រូវថ្ងៃយូរពេកដែលធ្វើឱ្យវាខ្សោះជាតិទឹក និងបណ្ដាលឲ្យងាយងាប់។ ខ្នែងត្រួយដែលបានកាត់រួច ត្រូវយកមករក្សាទុកនៅកន្លែងម្លប់ និងមានអនាម័យល្អ បន្ទាប់មកត្រូវកាត់ទុកវាឲ្យបានវែងបន្តិច ដែលមានប្រវែងប្រមាណជា ២០-២៥ ស.ម

ហើយមានស្លឹកផងដែរ រួចដាក់ត្រាំក្នុងទឹកភ្លាមៗ ដើម្បីការពារកុំឱ្យកំណាត់មែកបាត់បង់ជាតិទឹក។

ការកាត់កំណាត់មែកអាកាស្យាដែលបានមកពីដើមមេត្រូវអនុវត្តដូចខាងក្រោម៖

-ស្លឹកនៃកំណាត់មែកត្រូវកាត់ដោយប្រើកន្ត្រៃយ៉ាងមុតប្រមាណមួយភាគបីនៃស្លឹក ដើម្បីធ្វើឲ្យទឹកស្រោចចូលគ្រប់កំណាត់មែក កាត់បន្ថយការចាប់យកសារធាតុចិញ្ចឹមងាយស្រួលក្នុងការថែទាំ និងកាត់បន្ថយការបំភាយ ចំហាយទឹក

-ការកាត់តម្រឹមដើមដោយទុកប្រវែងពី១០-១៥ស.ម គឺកាត់នៅខាងលើថ្នាំង ដោយរក្សាទុកថ្នាំងយ៉ាងហោចណាស់ ចាប់ពី ២ឡើងទៅ។ ការកាត់តម្រឹមនេះ គឺត្រូវកាត់ជារាងចំណិតត្រសក់ ឬកាត់ជារាងមាត់ចាប (កាត់ចំណិតត្រសក់សងខាង) ដោយធ្វើការកាត់យ៉ាងថ្នមៗ ដោយប្រើនូវកន្ត្រៃមុតល្អ និងមានអនាម័យ ធ្វើយ៉ាងណាមិនត្រូវឲ្យបែក ឬ សាញត្រង់មុខកាត់នោះទេ។



ការកាត់តម្រឹមស្លឹក និងតួដើម

## ៥-ការប្រើប្រាស់អ័រម៉ូន និងបច្ចេកទេសដោតកំណាត់មែក

អ័រម៉ូន គឺជាសារធាតុគីមីដែលត្រូវបានគេប្រើក្នុងគោលបំណងជួយជំរុញការដុះលូតលាស់ឫសរបស់កំណាត់មែក។ ការស្រាវជ្រាវពិសោធន៍លើការកាត់ត្រួយបណ្តុះត្រូវបានប្រើប្រាស់ប្រភេទអ័រម៉ូនផ្សេងៗគ្នាដូចជាអ័រម៉ូនទឹក និងអ័រម៉ូនម្សៅក្នុងបរិមាណខុសៗគ្នា និងបានបង្ហាញអំពីប្រសិទ្ធភាពនៃការដុះឫសរបស់កំណាត់មែកខុសគ្នាដែរ។

កំណាត់មែកទាំងអស់ក្រោយពីកាត់រួចហើយ ត្រូវជ្រលក់អ័រម៉ូនសិនមុននឹងយកទៅស្ទូងក្នុងត្រេ ឬ ថង់។ ជាទូទៅ ត្រូវយកឈើដោតចូលដីបង្កើតជារន្ធល្មមដែលអាចស្ទូងកំណាត់មែកបាន បន្ទាប់មកធ្វើការជ្រលក់ថ្នមៗនៃកំណាត់មែកចូលទៅក្នុងម្សៅអ័រម៉ូន ឬអ័រម៉ូនទឹក ប្រវែងប្រមាណ ១,៥ស.ម ទើបស្ទូងចូលក្នុងថង់ និងបិទរន្ធដីឲ្យជិត ដើម្បី កុំឲ្យកំណាត់មែករលំដួល។

របៀបស្ទូងកំណាត់មែកទៅក្នុងថង់ ឬ ត្រេ ត្រូវមានដំណាក់កាលរបស់វាដូចខាងក្រោម ៖

-មុនពេលធ្វើការដោត ត្រូវបាញ់ទឹកលើកញ្ច្រែងត្រេ ឬថង់ឱ្យសើមជោគសិន ដើម្បីឲ្យដីផ្សំបានត្រជាក់

-ធ្វើការចោះរន្ធដីឱ្យប្រហោង ដើម្បីងាយស្រួលក្នុងការដោត ទំហំធំជាងកំណាត់មែកជម្រៅពី ១ - ១,៥ ស.ម ដែលអាចទប់លំនឹងដើមបាន

-យកកំណាត់មែក ដែលជ្រលក់អ័រម៉ូនរួចស៊កថ្នមៗ លៃយ៉ាងណាកុំឱ្យជ្រុះអ័រម៉ូន និងប៉ះពាល់ដល់កំណាត់មែក

-ពេលដោតត្រូវប្រើមេដៃ និងចង្អុលដៃចុចថ្នមៗឲ្យបានជិតល្អ កុំឲ្យខ្យល់ចូលបាន

-ក្រោយពេលដោតហើយ ត្រូវធ្វើការបាញ់ទឹកភ្លាមៗការពារកុំឲ្យបាត់បង់ជាតិទឹក។



កំណាត់ត្រួយអាកាស្យាដែលបានស្ទូងក្នុងឃ្លុប

## ៦. ការថែទាំកំណាត់មែកក្នុងឃ្លុប

### *ក. ការផ្ដល់សំណើម*

សំណើមមានតួនាទីសំខាន់ណាស់ អាចជះឥទ្ធិពលដល់ដំណើរការនៃការដុះឫស ឬមិនដុះឫស។ ការរៀបចំប្រព័ន្ធទឹក គឺតម្រូវឲ្យសម្ពាធនៃការបាញ់ចេញផ្សែងក្រូចមិនមែនជាដំណក់ទឹកនោះទេ។ ការផ្ដល់សំណើមនេះគឺអាស្រ័យស្ថានភាពអាកាសធាតុ (ក្ដៅ និងត្រជាក់) ដោយចាប់ផ្ដើមបាញ់ទឹកផ្ដល់ជាសំណើមនេះ ចាប់ផ្ដើមពីម៉ោង ៧ព្រឹក ដល់ម៉ោង ៥ល្ងាច។ ចំពោះធាតុអាកាសក្ដៅបាញ់ទឹក ៣០នាទីម្ដង រយៈពេល ៣ ទៅ ៥នាទី ប្រសិនបើធាតុអាកាសត្រជាក់ដោយបាញ់ទឹក រយៈពេល ១ម៉ោងម្ដង (រយៈពេល ៣ ទៅ ៥នាទី)។ ដោយឡែក កូនសំណាបដែលយកចេញពីឃ្លុបគឺធ្វើការស្រោចទឹក ២ដង/ថ្ងៃ ដោយស្រោចឱ្យជោគល្អ។

### *ខ. សីតុណ្ហភាព*

សីតុណ្ហភាព និងសំណើមមានការពាក់ព័ន្ធនឹងគ្នាដោយកាលណាសំណើមឡើងខ្ពស់សីតុណ្ហភាពចុះត្រជាក់ ដូច្នេះការបាញ់ទឹកផ្ដល់សំណើម ឃ្លុប និងសំណាញ់បៃតងនៅពីខាងលើ អាចធ្វើឱ្យសីតុណ្ហភាពចុះត្រជាក់ ដែលអាចជួយដល់កំណាត់មែកទទួលបានអត្រាដុះឫសខ្ពស់។

### *គ. ការប្រើសារធាតុគីមីជំនួយឫស*

ជី Osmocote គឺជាប្រភេទជីគីមី ដែលអាចជំនួយដល់ការលូតលាស់របស់ឫសអាកាស្យាបានរយៈពេល ៦ខែ ដោយលាយជាមួយល្បាយផ្សំក្នុងចំណុះ ១ក្រាម និង ២ក្រាម នៃជីលាយជាមួយល្បាយ១០លីត្រ។ ជី Osmocote គឺជាប្រភេទគ្រាប់ៗ ហើយរលាយបន្តិចម្ដងៗនៅពេលធ្វើការបាញ់ទឹក។

លទ្ធផលនៃការពិសោធន៍កន្លងមកបានបង្ហាញថា អត្រារស់នៃកំណាត់មែកអាកាស្យា Hybrid គឺមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទរវាងការប្រើប្រាស់អ័រម៉ូន លក្ខខណ្ឌសីតុណ្ហភាព និងសំណើម ព្រមទាំងការប្រើប្រាស់ល្បាយលាយរវាងដី និងសារធាតុផ្សំ។ បទពិសោធន៍នៃការស្រាវជ្រាវនៅស្ថានីយម្សៅក្រដាស់ ហ៊ុន សែន មានកបាន បង្ហាញថា អត្រារស់នៃកំណាត់មែកគឺបានត្រឹមតែ៦៤ភាគរយ ក្នុងលក្ខខណ្ឌសីតុណ្ហភាពពី ៣០-៣៥អង្សាសេ និងសំណើម ៨០ភាគរយ ដោយប្រើប្រាស់ ប្រភេទអ័រម៉ូនម្សៅ Hormoril, Extra TONIC root និងអ័រម៉ូនទឹក Vitamin B-1 នៅកម្រិត ៦០០០ppm (P ≤ ៥ ភាគរយ Sig = 0.00១១) ក្នុងសមាមាត្រ ៦៤:៦៣:៥៦ភាគរយ។

លទ្ធផលខាងលើនេះគឺទទួលបានអត្រារស់ទាបជាងការស្រាវជ្រាវពិសោធន៍កាត់ត្រួយបណ្ដុះនៅថ្នាលបណ្ដុះកូនឈើនៅស្រុកកំពង់សិលា ខេត្តព្រះសីហនុ ដែលបានប្រើប្រាស់សារធាតុផ្សំក្នុងកម្រិតផ្សេងៗគ្នា រួមមាន ល្បាយអាចម៍រណារ ជី Osmocote ជីកំប៉ុស្ដិ៍ និងអ័រម៉ូនប្រភេទម្សៅ គឺទទួលបាននូវអត្រាដំណុះប្រែប្រួលពី៧០-៩៤ភាគរយ។

ការផលិតកូនឈើអាកាស្យាតាមរយៈការកាត់ត្រួយបណ្ដុះ មិនសូវមានលក្ខណៈពិបាកនោះទេ ក៏ប៉ុន្តែទាមទារឲ្យមានឧបករណ៍គ្រប់គ្រាន់ បច្ចេកទេស ការលាយល្បាយ ការអនុវត្តដោយព្យាយាម និងយកចិត្តទុកដាក់ទើបទទួលបានអត្រាដំណុះខ្ពស់៕

### *ឯកសារយោង៖*

១) ឆេង គឹមហួត (២០១៩) ឥទ្ធិពលនៃការប្រើប្រាស់អ័រម៉ូនទៅលើការដុះលូតលាស់កូនអាកាស្យា តាមរយៈការកាត់ត្រួយបណ្ដុះ នៅស្ថានីយដាំឈើម្សៅក្រដាស ហ៊ុន សែន មានក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

២) ឌុក មួយឡៀង (២០១៩) ការសិក្សាអំពីឥទ្ធិពលនៃល្បាយលើដំណុះឫស និងការលូតលាស់របស់អាកាស្យាអ៊ីប្រ៊ីត នៅក្នុងក្រុមហ៊ុនខេម៉ាហ្វ្រា ស្ថិតនៅស្រុកកំពង់សិលា ខេត្តព្រះសីហនុ។ មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

# រុក្ខជាតិឱសថ
# អង្គាបុស្ស
## *Millingtonia hortensis*
## Bignoniaceae





ផ្កា ស្លឹក និងដើមអង្គាបុស្ស

អង្គាបុស្ស Millingtonia hortensis (Millingtonia) ស្ថិតក្នុងអំបូរ Bignoniaceae ជាដើមឈើដុះត្រង់ សំបកដើមបែកក្រម៉ មែកសំយុង។ ស្លឹកស្នឹតរួមមាន២ទៅ៣ស្និតកូនស្លឹកនីមួយៗរាងដូចលំពែង ស្រួចចុង គែមរាងធ្មេញរណា ពណ៌បៃតងចាស់ផ្នែកខាងលើ បៃតងភ្លាវខាងក្រោម។ ផ្កាពណ៌ស មានក្លិនក្រអូប។ ផ្លែជាប្រភេទផ្លែស្ងួត ស្រួចចុង ស្រួចដើម។ គ្រាប់ជាបន្ទះស្តើងតំរៀបគ្នារហូតដល់ចុងផ្លែ។

**-កន្លែងដាំដុះ៖** ដុះឯងៗនៅក្នុងព្រៃ ឬដាំក្នុងស្រុកលំអ គេប្រើជាឱសថ និងជាបន្លែ។

-ផ្នែកប្រើប្រាស់៖ ផ្កា ស្លឹក និងឫស។

**-ការព្យាបាល៖** ជំងឺលើសឈាម គ្រួសក្នុងតំរងនោម រិលមុខនោម ទាស់ពុលអាហារ ហើមដោយសាររលាកតម្រង នោម សត្វល្អិតទិច ហ៊ឹងត្រចៀក គ្រុន ឈឺត្រចៀក រោយក រោយសាច់ដុំ គ្រុនក្តៅ បែកញើសច្រើនខុសប្រក្រតី។

**-កម្រិត និងរបៀបប្រើ៖** ស្លឹក និងផ្កាប្រើជាបន្លែ។ ឫសស្ងួតដាំទឹកផឹក ពី ១០០ ទៅ ២០០មីលីលីត្រសម្រាប់ព្យាបាលជំងឺលើសឈាម រិលមុខ និងពុលអាហារ។ ផ្កាស្ងួត ប្រើដាំទឹកផឹកដូចតែសម្រាប់កុំឲ្យចេញញើសខុសប្រក្រត្រី។ ស្លឹកស្រស់ ស្ងួជាមួយសាច់ សម្រាប់ព្យាបាលជំងឺគ្រួសក្នុងតម្រងនោម និង រលាកតំរងនោម។ ស្លឹកស្ងួតស្ងោរផឹកសម្រាប់ព្យាបាលជំងឺ ដូចខាងលើ និងជំងឺឈឺត្រចៀក ស្ពឹក និងគ្រុន។



ផ្លែអង្គាបុស្ស (រាងស្រួចចុង ស្រួចដើម)

ដោយសារតែឈ្មោះដ៏ពីរោះ និងក្លិនផ្កាក្រអូបឈ្ងុយឈ្ងប់ផងនោះ ត្រូវបានកវីខ្មែរយកមកចងក្រងជាបទចម្រៀងមនោសញ្ចេតនាដ៏សែនពីរោះ "*អង្គាបុស្សអើយ*" ...។

ដោយលោក **ឃឿន អឿនគិច** រដ្ឋបាលព្រៃឈើ

*ឯកសារយោង៖ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ*



# អាថ៌កំបាំងរបស់សត្វឃ្មុំ





*ស្រាវជ្រាវ និងរៀបរៀងដោយ បណ្ឌិត* ***ឆេង គីមស៊ុន***

សត្វឃ្មុំជាសត្វរស់នៅជាសមូហភាព និងមានភាពឧស្សាហ៍ព្យាយាមខុសពីសត្វដទៃ។ សត្វឃ្មុំមានច្រើនប្រភេទ ហើយសត្វឃ្មុំដែលគេចិញ្ចឹមជាពូជសត្វឃ្មុំព្រៃតដែលនៅក្នុងធម្មជាតិវារស់នៅក្នុងរន្ធដើមឈើ ឬក៏រន្ធក្នុងដីដែលមានផ្លិត(សំបុក)ជាច្រើនស្រទាប់។ សិល្បៈនៃការចិញ្ចឹមឃ្មុំត្រូវបានមនុស្សយើងធ្វើរាប់ពាន់ឆ្នាំមកហើយ រីឯទឹកឃ្មុំក៏ត្រូវបានគេស្គាល់នូវអត្ថប្រយោជន៍របស់វា និងត្រូវបានគេយកប្រើប្រាស់ជាយូរណាស់មកហើយ។ ផលិតផលសំខាន់ពីសត្វឃ្មុំមាន ទឹកឃ្មុំ ក្រមួនឃ្មុំ ពិសឃ្មុំ ស្តេចចាហួយ (Royal Jelly) ហើយសេវាដែលទទួលបានពីសត្វឃ្មុំវិញគឺបង្កើនប្រសិទ្ធភាពកសិកម្ម ព្រោះវាជាសត្វនាំដំណើរលំអងសម្រាប់រុក្ខជាតិមានផ្លែ ដោយវាបាននាំកេសរឈ្មោលពីផ្កាមួយទៅបង្កាត់ជាមួយកេសរញីបង្កើតជាផ្លែ។

នៅក្នុងសំបុកមួយមាន**ស្តេចឃ្មុំ**(Queen) មួយក្បាល ឃ្មុំឈ្មោល (Drone) មួយចំនួនតូច ក្រៅពីនោះជា **ឃ្មុំញី** ឬ ហៅថា**ឃ្មុំកម្មករ** (Worker)។




ឃ្មុំមួយសំបុកមានមេឃ្មុំតែមួយគត់ដែលជា ស្តេចឃ្មុំ និងជាមេនៃឃ្មុំទាំងឡាយក្នុងសំបុក។ នៅមានឃ្មុំឈ្មោលមួយចំនួនតូច ហើយនិងមានឃ្មុំញីជាច្រើនដែលជាឃ្មុំកម្មករជាអ្នកស្វែងរកលំអងផ្កាមកធ្វើសំបុក និងរកទឹកដមផ្កាដើម្បីបង្កើតជាទឹកឃ្មុំសម្រាប់ប្រើប្រាស់ក្នុងសហគមន៍របស់ខ្លួន។

### ឃ្មុំញី ឬឃ្មុំកម្មករ (Worker)

ភាគច្រើនលើសលប់នៃសត្វឃ្មុំក្នុងសំបុកសុទ្ធសឹងជាសត្វញី ឬគេហៅថាឃ្មុំកម្មករសម្អាតសំបុកចាប់តាំងពីវាញាស់នៅថ្ងៃទីមួយមកម្ល៉េះ។ បន្ទាប់ពីដើរសម្អាតសំបុកបានប្រហែលមួយសប្តាហ៍ វាចាប់ផ្តើមជួយកសាងសំបុកជួយពាំយកអាហារទៅចិញ្ចឹមមេឃ្មុំ ឃ្មុំឈ្មោល ពិសេសនាំយកអាហារទៅចិញ្ចឹមកូនដង្កូវឃ្មុំដែលនៅក្នុងបន្ទប់(រន្ធ)នីមួយៗ និងជួយរក្សាសីតុណ្ហភាពក្នុងសំបុកឲ្យនៅថេរ។ នៅពេលវាមានអាយុប្រហែលមួយខែ វាចាប់ផ្តើមហើរស្វែងរកចំណីដូចជា ទឹកដមផ្កាលំអងផ្កាដើម្បីចិញ្ចឹមស្តេចឃ្មុំ ឃ្មុំឈ្មោល និងកូនឃ្មុំ កសាងសំបុកនិងក្បាលទឹក។ ឃ្មុំញីមានក្រពេញក្រមួនបួនគូនៅពីក្រោមពោះ។ វាចាប់ផ្តើមជួយកសាងសំបុកចាប់ពីវាមានអាយុមួយអាទិត្យហើយជួយការពារសំបុក និង



ឃ្មុំញី ឬ ឃ្មុំកម្មករ ( Worker )

រក្សាសីតុណ្ហភាពក្នុងសំបុកឲ្យនៅថេរ។ វាហើរបានក្នុងល្បឿន ២៥គីឡូម៉ែត្រ ក្នុងមួយម៉ោង ហើយអាចរកចំណីអាហារ ក្នុងរង្វង់ពី ២ ទៅ ៤គីឡូម៉ែត្រពីសំបុក។ វាទាក់ទងគ្នាតាម រយៈការរលាស់ស្លាបរាំផ្តល់សញ្ញាឲ្យគ្នា។ អាយុមធ្យមរបស់ ឃ្មុំញី ឬឃ្មុំកម្មករនេះគឺ *ប្រហែល ៦០ថ្ងៃ* ប៉ុណ្ណោះ។

**ឃ្មុំឈ្មោល** ( Drone )

ក្រៅពីស្តេចឃ្មុំនៅមានឃ្មុំឈ្មោល(Drone)ប្រហែល ៥០០ក្បាល នៅក្នុងដំណាក់កាលដែលឃ្មុំត្រូវការបំបែក សំបុក និងបង្កើតមេឃ្មុំថ្មី (Queen)បន្តពូជ។ **ឃ្មុំឈ្មោល** (Drone)វារស់នៅពឹងផ្អែកលើឃ្មុំកម្មករជាអ្នករកចំណីអាហារ មកចិញ្ចឹម។ នៅពេលដែលបន្តពូជរួចរាល់ ឃ្មុំញីសម្លាប់ ឃ្មុំឈ្មោលទាំងនោះចោល។ អាយុរបស់ឃ្មុំឈ្មោលមាន រយៈពេលប្រមាណត្រឹម *៧០ថ្ងៃ* តែប៉ុណ្ណោះ។



ឃ្មុំឈ្មោល ( Drone )

**មេឃ្មុំ ឬស្តេចឃ្មុំ** ( Queen )

ឃ្មុំរស់នៅជាសហគមន៍ដែលមួយសំបុកមានសមាជិក គ្រួសារចាប់ពីជាង ១ម៉ឺន ទៅ ១០ម៉ឺនឃ្មុំ។ នៅក្នុងសំបុក មួយមានមេឃ្មុំតែមួយប៉ុណ្ណោះដែលគេហៅថា **ស្តេចឃ្មុំ** ( **Queen** )។ ស្តេចឃ្មុំមានអាយុដល់ទៅ *៤ ឬ៥ឆ្នាំ* ។ ក្នុង មួយជីវិតវា វាហើរចេញពីសំបុកតែម្តងប៉ុណ្ណោះ គឺនៅ ពេលបន្តពូជ (ដោយញីឈ្មោល) ក្រៅពីនោះមានករណីខ្លះ មេឃ្មុំត្រូវបំបែកសំបុកនៅពេលដែលសមាជិកគ្រួសារកើន ឡើងលើសចំណុះ។ ករណីនេះមុននឹងបំបែកសំបុក ឃ្មុំបាន បង្កើតស្តេចថ្មី រហូតដល់ស្តេចថ្មីនោះមានលទ្ធភាពបន្តពូជ បាន ទើបស្តេចចាស់ត្រូវនាំសមាជិកគ្រួសារប្រហែលពាក់ កណ្តាលនៃសំបុកហើរចេញពីសំបុកដើម្បីបង្កើតសំបុកថ្មី។ ស្តេចឃ្មុំមានតួនាទីទទួលបន្ទុកពងដាក់គ្រប់បន្ទប់ក្នុង សំបុកដើម្បីបង្កើតជាសហគមន៍។ សត្វឃ្មុំទាំងអស់នៅក្នុង សំបុកជាកូនរបស់ស្តេចឃ្មុំ។ សត្វឃ្មុំស្គាល់សំបុករបស់វា ច្បាស់ណាស់មិនដែលច្រឡំសំបុកឡើយទោះបីជាគេចិញ្ចឹម វាជាច្រើនប្រអប់ដាក់ក្បែរៗគ្នាក៏ដោយ។ ហេតុអ្វីបានជាវា មិនច្រឡំសំបុកសញ្ញា? ដូចលោកអ្នកជ្រាបហើយថានៅក្នុង សំបុកនីមួយៗគ្រប់គ្រងដោយស្តេចឃ្មុំ(មេឃ្មុំ)មួយ ហើយ ស្តេចឃ្មុំនីមួយៗបញ្ចេញនូវសារធាតុគីមីម្យ៉ាងពីក្នុងខ្លួនទាក់ ទាញឃ្មុំក្នុងសំបុកមកទទួលសារធាតុគីមីនោះ ជាហេតុធ្វើ ឲ្យវាស្គាល់ក្លិនគ្នីគ្នាក្នុងសំបុកជាក់លាក់តាមរយៈក្លិននោះ។ នៅពេលដែលបរិមាណសត្វឃ្មុំក្នុងសំបុកកើនឡើងច្រើន ប្រហែល៥ម៉ឺនក្បាលសត្វឃ្មុំកម្មករមិនបានចូលមកជិតក្រេប ក្លិនស្តេចឃ្មុំបានគ្រប់គ្នាឡើយ ម៉្លោះហើយឃ្មុំដែលមិនបាន ទៅជិតស្តេចមិនបានទទួលសារធាតុគីមីបញ្ចេញពីខ្លួនស្តេច ឃ្មុំធ្វើឲ្យវាបាត់ក្លិន បាត់ការទាក់ទង ម៉្លោះហើយនៅពេល នោះហើយដែលជាពេលដែលឃ្មុំត្រូវការបំបែកសំបុក។



មេឃ្មុំ ឬស្តេចឃ្មុំ ( Queen )



មេឃ្មុំ ឬស្តេចឃ្មុំ (Queen) ក្នុងសំបុក

## តើឃ្មុំបំបែកសំបុករបៀបណា?

នៅក្នុងសំបុកឃ្មុំចិញ្ចឹមមួយប្រអប់ មានសត្វឃ្មុំចាប់ពីប្រាំពាន់ ទៅ បីរយពាន់ក្បាល។ ចំណីសំខាន់របស់ឃ្មុំ គឺលំអង និងទឹកដមផ្កា។ វានាំយកលំអងដែលជាប់នឹងខ្លួនវាពីផ្កាមួយទៅផ្កាមួយ ជំរុញដល់ការបង្កាត់ពូជតាមរយៈដំណើរលំអងនេះ។ លំអងមួយចំនួនវានាំទៅសំបុកដើម្បីបង្កើតជាក្រមួន កសាងសំបុក(ផ្លិតឃ្មុំ)។តាមរយៈអង់ស៊ីមក្នុងខ្លួនវា ទឹកដមផ្កាត្រូវបានបំប្លែងសាខារ៉ូស ទៅជាហ្វ្រុកតូស និងគ្លុយកូសក្នុងទឹកឃ្មុំ។ ទឹកឃ្មុំ ក្រមួនឃ្មុំ ពិសឃ្មុំ និងស្តេចចាហួយ (Royal Jelly) គឺជាផលិតផលដែលបានមកពីការចិញ្ចឹមឃ្មុំ។ ក្រមួនឃ្មុំបានមកពីសំបុកទទេយកទៅរំលាយប្រើសម្រាប់ធ្វើថ្នាំប៉ូលា ទៀន ក្រែមលាបមុខ និងក្នុងឧស្សាហកម្មដទៃទៀត។ បរិមាណដ៏តិចតួចនៃ Royal Jelly បានស្តុកទុកនៅក្នុងសំបុកស្តេចឃ្មុំត្រូវបានគេយកមកប្រើប្រាស់ជាឱសថដ៏មានតម្លៃ។ ពិសឃ្មុំត្រូវបានប្រើប្រាស់ជាថ្នាំបំបាត់ ការឈឺចាប់តាមសន្លាក់។ នៅប្រទេសខ្លះមិនបានយកពិស និង Royal Jelly ពីការចិញ្ចឹមឃ្មុំឡើយ។

## វដ្តជីវិតរបស់សត្វឃ្មុំ

ដូចបានជម្រាបជូនខាងលើបន្ទាប់ពីឃ្មុំកម្មករបានកសាងសំបុក(ផ្លិត) ដែលកើតឡើងពីការរៀបចំរន្ធជាបន្ទប់ៗខណ្ឌចែកដោយជញ្ជាំងប្រាំមួយជ្រុងជាច្រើនជាប់ៗគ្នាសម្រាប់ដាក់ពងឃ្មុំ ដែលស្តេចឃ្មុំពងដាក់គ្រប់រន្ធ។ បន្ទាប់ពីមេឃ្មុំពងដាក់រួច តួនាទីថែរក្សាត្រូវបានក្រុមឃ្មុំមួយក្រុមមានភារកិច្ចពាំនាំយកចំណីដែលមានសណ្ឋានដូចចាហួយសភ្លាវមកដាក់គ្រប់រន្ធ ដើម្បីឲ្យកូនដង្កូវញាស់ចេញពីពងមេឃ្មុំស៊ីចិញ្ចឹមជីវិត។ បន្ទាប់ពីវាញាស់ចេញជាដង្កូវ វាត្រូវស៊ីចំណីរយៈពេលមួយអាទិត្យទើបវាបំប្លែងខ្លួនទៅជាដឹកដឿ។ នៅក្នុងដំណាក់កាលក្លាយជាដឹកដឿនេះ វាមិនត្រូវការចំណីអាហារនោះឡើយ គឺវារស់ដោយសារធាតុចិញ្ចឹមដែលវាស៊ីនៅក្នុងអំឡុងពេលវានៅជាដង្កូវ។ នៅពេលក្លាយជាដឹកដឿនេះ ឃ្មុំកម្មករបានយកធ្វើការភ្ជិតមាត់រន្ធនៃបន្ទប់នីមួយៗដែលមានដឹកដឿក្នុងនោះដើម្បីរក្សាសីតុណ្ហភាពឱ្យវាលូតលាស់ក្នុងដំណាក់កាលសម្ងំនេះ។ បន្ទាប់ពីផ្ជិតរន្ធបានមួយអាទិត្យដឹកដឿបានញាស់ដុះស្លាប់ពេញរូបពេញរាងទើបវាខាំបំបែកក្រមួនមាត់សំបុករួចចេញមកក្រៅ។ នៅពេលញាស់ចេញមកភ្លាមវាក៏មានការងារធ្វើភ្លាមដែរ គឺវាដើរ



ដឹកដឿ (Pupa) ក្នុងសំបុកឃ្មុំ

សម្អាតបន្ទប់ក្នុងសំបុកដើម្បីទុកសម្រាប់ស្តេចឃ្មុំពងបន្ត។ ដោយឡែក នៅពេលឃ្មុំច្រើនលើសចំណុះដូចបានជម្រាបជូនខាងលើ ដែលមានរហូតដល់ប្រហែល ៣ម៉ឺនក្បាល ឃ្មុំបានកសាងបន្ទប់(រន្ធ)សម្រាប់បង្កើតស្តេចឃ្មុំថ្មីដោយកសាងបន្ទប់ធំជាងបន្ទប់ដាក់ឃ្មុំកម្មករចំនួន ១០ ទៅ ១២បន្ទប់ ទុកឲ្យមេឃ្មុំពងដាក់ដូចរន្ធដទៃទៀតដែរ។ ប៉ុន្តែអ្វីដែលខុសគ្នានោះគឺអាហារបំប៉នដែលត្រូវយកមកចិញ្ចឹមអនាគតស្តេចឃ្មុំនេះ។ ពួកវាបានសម្រិតសម្រាំងអាហារពិសេសជា ស្តេចចាហួយដែលគេហៅថា Royal Jelly មកដាក់ក្នុងបន្ទប់ពិសេសទាំងនេះ។ ដោយសារតែបន្ទប់ធំ និងមានអាហារពិសេសធ្វើឲ្យដង្កូវដែលញាស់ចេញមកធំជាងដង្កូវដទៃទៀត។

ដំណើរការប្រព្រឹត្តទៅដូចជានៅក្នុងសំបុកធម្មតាដែរគឺបន្ទាប់ពីវាចូលដល់ដំណាក់កាលដឹកដឿ ឃ្មុំរក្សាសំបុកចាប់ផ្តើមភ្ជិតមាត់រន្ធ រហូតដល់វាវិវឌ្ឍន៍ពេញរូបរាង ដុះស្លាប ខាំបំបែកមាត់សំបុកលូនចេញមកក្រៅ។ នៅពេលវាញាស់ជាស្តេចឃ្មុំភ្លាម វាចាប់ផ្តើមបន្លឺសំឡេងទន្ទឹមគ្នានឹងការខាំបំបែកមាត់រន្ធ។ ជាសភាវគតិធម្មជាតិស្តេចឃ្មុំដែលទើបនឹងញាស់នេះបានវារទៅរកសំបុកស្តេចឃ្មុំដទៃទៀតជាបងប្អូនដើម្បីសម្លាប់ចោលទាំងអស់ ទោះបីជាទ្រនិចជាអាវុធរបស់វាមិនទាន់រឹងមាំក៏ដោយ។ បន្ទាប់ពីសម្លាប់រួចហើយសត្វឃ្មុំជាបរិវារបានខាំទាញស្តេចឃ្មុំដែលរៀបនឹងញាស់នេះទៅចោលនៅក្រៅឆ្ងាយពីសំបុកដោយមិនមានមនោសញ្ចេតនាបន្តិចសោះឡើយ។ ក្នុងករណីចៃដន្យក្នុងសំបុកតែមួយដែលមានស្តេចឃ្មុំពីរក្បាលញាស់មកដំណាលគ្នានោះឆាកប្រយុទ្ធរវាងស្តេចឃ្មុំថ្មីថ្មោងទាំងពីរក្បាលចាប់ផ្តើមហើយបញ្ចប់ទៅវិញដោយអ្នកចាញ់ត្រូវស្លាប់ ហើយអ្នកឈ្នះត្រូវក្លាយជាស្តេចគ្រប់គ្រងអាណាចក្រ។ នៅពេលនោះក្នុងសំបុកទាំងមូលមាន ស្តេចឃ្មុំពីរ គឺស្តេចឃ្មុំជាម្តាយ និងស្តេចឃ្មុំជាកូនទើបនឹងញាស់ទទួលបានជោគជ័យក្នុងការប្រយុទ្ធកន្លងមកនេះ។ នៅពេលដែលកូនស្តេចឃ្មុំធំពេញរូបរាងអាចបន្តពូជបន្តបាន ស្តេចឃ្មុំជាម្តាយត្រូវចាកចេញទៅធ្វើសំបុកថ្មី ដោយនាំកូនចៅប្រហែលពាក់កណ្តាលនៃសំបុកទៅជាមួយ។ នៅសល់ឃ្មុំពាក់កណ្តាលទៀតស្តេចកូនគ្រប់គ្រងបន្ត។

## ការបន្តពូជ

នៅក្នុងពេលវាដោយញីឈ្មោល ស្តេចឃ្មុំបានហើរឡើងលើខ្ពស់ពីដីប្រមាណកម្ពស់២០ម៉ែត្រ ហែរហមហើរដេញពីក្រោយដោយឃ្មុំឈ្មោល(Drone) មួយចំនួន ហើយទីបំផុតមានតែឃ្មុំឈ្មោលបួនប្រាំក្បាលប៉ុណ្ណោះដែលបានពាក់ស្តេចឃ្មុំនេះ ប៉ុន្តែរាល់ឃ្មុំឈ្មោលទាំងប៉ុន្មានដែលបានរួមរក្សជាមួយស្តេចឃ្មុំរួច ត្រូវធ្លាក់មកដីងាប់បន្ទាប់ពីរួមរក្សហើយ។ នេះហើយជាធម្មជាតិរបស់ស្តេចឃ្មុំ។ ស្តេចឃ្មុំបន្ទាប់ពីដោយឈ្មោលរួច មានតួនាទីបង្កើតកូនដោយត្រូវទម្លាក់ពងគ្រប់រន្ធដើម្បីបន្តអត្ថិភាពសហគមន៍។ ក្នុងការរួមរក្សខាងលើនេះទឹកកាមដែលទទួលបានពីឃ្មុំឈ្មោលទាំងនោះអាចឲ្យវាមានសមត្ថភាពពងបានប្រមាណមួយលានពងក្នុងរយៈពេលប្រាំឆ្នាំ ហើយក្នុងមួយថ្ងៃវាអាចពងបាន ១៥០០ពង។ សូមជម្រាបជូនជ្រាបផងដែរថា រាល់ពេលវាពង វាតែងបញ្ចេញទឹកកាមដែលស្តុកទុកក្នុងខ្លួនវាទៅលើពងនោះដើម្បីបង្កើតជាឃ្មុំញី ឬឃ្មុំកម្មករ។ ប៉ុន្តែពងខ្លះមិនបានទទួលទឹកកាមនៅពេលវាពងនោះទេ ដែលជាហេតុនាំឲ្យវាញាស់មកជាសត្វឃ្មុំឈ្មោល។

## គុណភាពទឹកឃ្មុំសុទ្ធ

គេបានសិក្សាស្រាវជ្រាវបង្កើតជាស្តង់ដារសម្រាប់ទឹកឃ្មុំដែលសុទ្ធល្អ ចាំបាច់ត្រូវមានលក្ខណៈដូចខាងក្រោម៖

-សំណើមត្រូវមានតិចជាង ២៥%
(Moisture Content less than 25%)

-ស្ករស៊ូក្រូសតិចជាង ៥%
(Sucrose sugar less than 5%)

-ហ្វ្រុកតូស/គ្លុយកូស ច្រើនជាង ០.៩៥%
(សីតុណ្ហភាព ២៧អង្សាសេ temperature 27 °C)
(Fructose / Glucose More than 0.95 %)

- TRS (Total Reducing Sugar) អប្បបរមា៦៥%
(TRS Minimum 65%)

-ដង់ស៊ីតេ ១.៣៥%( Density Minimum 1.35)

-អាស៊ីតអតិបរមា០.២% (Acidity Maximum 0.2%)

# វឌ្ឍនភាពនៃការសិក្សាស្រាវជ្រាវតាមដានអំពីហានិភ័យ នៃជំងឺឆ្លងពីថនិកសត្វតូចៗ ប្រចៀវ និងជ្រើង មកមនុស្ស

## “Investigating the Risk of Human Disease from Parasites of Small Mammals and Bats”

ដោយ លោក ឈាង ដានី លោក ញ៉ាន ប៊ុនថន លោក គឹម សុបុណ្យ លោកស្រី លឹម សុភាព លោក សាយ ស៊ិនលី លោក វណ្ណ វន្តែ
លោក ប៊ូរ វុឌ្ឍី លោក ប៉ាង ដានិត លោក អះ ប្រុសដែន លោក គឹមជរ ម៉ាសាឡែន លោក លឹម សុភា លោកហូ ប៊ុនយ៉េតលោក នួន ស៊ីធន់

រដ្ឋបាលព្រៃឈើ សហការជាមួយអគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វ នៃព្រះរាជាណាចក្រកម្ពុជា សាកលវិទ្យាល័យ DUKE សាកលវិទ្យាល័យ UC Davis សហរដ្ឋអាមេរិក សាកលវិទ្យាល័យជាតិសឹង្ហបុរី មន្ទីរពិសោធន៍ NAMRU II សាកលវិទ្យាល័យភូមិន្ទភ្នំពេញ អង្គការ FFI ដើម្បីការសិក្សាស្រាវជ្រាវតាមដានអំពីហានិភ័យនៃ ជំងឺឆ្លងពីថនិកសត្វតូចៗ ប្រចៀវ និងជ្រើង ឆ្លងមកមនុស្ស "Investigating the Risk of Human Disease from Parasites of Small Mammals and Bats" សម្រាប់រយៈពេល០៥ឆ្នាំចាប់ពីឆ្នាំ២០១៦-២០២០។ គម្រោងនេះឧបត្ថម្ភថវិកាដោយ Defense Threat Reduction Agency of the Department of Defense, USA ("DTRA")។

**គោលបំណង ៖**

- កំណត់សក្តានុពលអេពីដេមី ការវិវត្តនៃមេរោគដែលបង្កឡើងពីថនិកសត្វតូចៗ ពពួកសត្វប្រចៀវ និងបាក់តេរីមានសក្តានុពលដែលអាចចម្លងជំងឺសត្វ (Zonotic Disease)
- សិក្សាអង្កេតអំពីវិសាលភាពនៃការឆ្លងនៃប៉ារ៉ាស៊ីតដែលបង្កឡើងដោយថនិកសត្វតូចៗ មកមនុស្ស
- ផលិត spatio-temporal ម៉ូឌែលសម្រាប់ការវិភាគពីហានិភ័យនៃប៉ារ៉ាស៊ីតដែលអាចកើតឡើងពីមនុស្ស-ថនិកសត្វតូចៗពពួកសត្វប្រចៀវ-មនុស្ស។

**លទ្ធផល** ក្នុងឆ្នាំ ២០១៩ សកម្មភាពផ្តោតលើ៖

**ការចុះប្រមូលសំណាក ៖** បានចុះប្រមូលសំណាក (ឈាម ទឹកមាត់ លាមក និងជាលិកា) ពីពពួកថនិកសត្វតូចៗ និងសត្វប្រចៀវ ចំនួន ១០៧ទីតាំង ស្ថិតក្នុងខេត្តកំពត តាកែវ ព្រះសីហនុ កោះកុង កំពង់ស្ពឺ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កណ្តាល ក្រចេះ កំពង់ធំ សៀមរាប កំពង់ចាម ព្រះវិហារ និងខេត្តព្រៃវែង។ សរុបបានសំណាកចំនួន១១៦៧១សំណាកស្មើ១៣០៤ក្បាល ត្រូវជា ៥០ប្រភេទ ដែលក្នុងនោះមាន ប្រចៀវចំនួន ៣៥ប្រភេទ និងថនិកសត្វតូចៗ (កណ្តុរ កង្កិច និងកង្ហែន) ចំនួន ១៥ប្រភេទ។ ក្នុងនេះមានប្រភេទប្រចៀវ ចំនួន ០៣ ប្រភេទ នៅក្នុងប្រកាសលេខ ០២០ និងមាន ៣២ប្រភេទ ដែលទើបតែរកឃើញ និងកត់ត្រាថ្មី នៅប្រទេសកម្ពុជា រីឯថនិកសត្វតូចៗចំនួន ១៥ប្រភេទ មាន០២ ប្រភេទនៅក្នុងប្រកាសលេខ០២០ និងមាន ១៣ប្រភេទ ដែលទើបតែ រកឃើញ និងកត់ត្រាថ្មីនៅប្រទេសកម្ពុជា។ សំណាកទាំងនោះរក្សានៅមន្ទីរពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងនៅមន្ទីរពិសោធន៍ NAMRU2 ដើម្បីធ្វើតេស្តពិសោធន៍។













*សកម្មភាពនៃការចុះប្រមូលសំណាក (ឈាម ទឹកមាត់ លាមក និងជាលិកា) ពីពពួកថនិកសត្វតូចៗ និងសត្វប្រចៀវ*



*ប្រចៀវ Scotophillus healthii*



*ប្រចៀវ Cynopterus sphinx*



*ប្រចៀវ Megarderma lyra*




*កំប្រុកស្លាបតូច*




*កណ្តុរ Mus cervicolor*


VIETNAM
LAO PDR
THAILAND
Ratanak Kiri
Mondul Kiri
Stung Treng
Kratie
Preah Vihear
Kampong Thom
Tboung Khmum
Kampong Cham
Svay Rieng
Prey Veng
Kandal
Phnom Penh
Takeo
Otdar Meanchey
Siem Reap
Kampong Chhnang
Kampong Speu
Kampot
Kep
Banteay Meanchey
Battambang
Pursat
Koh Kong
Preah Sihanouk
Pailin
1:1,800,000
0 10 20 40 60 80
Kilometers
N
Legend
Probabilistic Sites
Probabilistic Sampling Sites
Country boundary
Major Rivers
Province Boundary
KAP Survey Sites
Human Sera Sampling Sites

**ការចុះធ្វើសម្ភាសន៍៖** ស្ដីអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត (Knowledge Attitude Practice)៖ បានចុះធ្វើសម្ភាសន៍ជាមួយប្រជាសហគមន៍ចំនួន ៨៥៦នាក់ (ស្រី៥០១នាក់) នៅខេត្តបាត់ដំបង កំពង់ឆ្នាំង ព្រះវិហារ កំពង់ធំ ត្បូងឃ្មុំ និងខេត្តកណ្ដាល ដែលនៅក្នុង ឃុំតាគ្រាម (៣១សំណាក) ឃុំបាយដំរាំ(៦០ សំណាក) ឃុំឈើទាល (៥២សំណាក) ឃុំអញ្ចាញរូង (៥៧សំណាក) ឃុំពោធិ៍បាន (២៧៤ សំណាក) ឃុំរុងរឿង (៦៦ សំណាក) ឃុំរម្មណីយ (១៣០សំណាក) ឃុំក្រយា (១២៦សំណាក) និងឃុំរការប្រាំ (៦០សំណាក) ស្ដីពី "ការអនុវត្តការយល់ឃើញ និងចំណេះដឹងស្ដីពីការការពារជំងឺឆ្លងពីសត្វមកមនុស្សតាមរយៈការប្រើប្រាស់ និងការជួញដូរសត្វព្រៃ"។



សកម្មភាពនៃកិច្ចសម្ភាសន៍ជាមួយប្រជាសហគមន៍

**ការចុះយកសំណាកសេរ៉ូម និងឈាម(មនុស្ស)៖**

បានចុះប្រមូលសំណាកសេរ៉ូម និងឈាមពីប្រជាសហគមន៍ចំនួន៤៦៥នាក់ ចំនួន០៨ឃុំ ក្នុងខេត្តបាត់ដំបង កំពត ពោធិ៍សាត់ កំពង់ឆ្នាំង កណ្ដាល និងខេត្តកំពង់ចាម ដើម្បីយកមកធ្វើការវិភាគពិសោធន៍រកមើលមេរោគដែលអាចចម្លងពីមនុស្ស-សត្វ-មនុស្ស។ សំណាកសេរ៉ូម និងឈាមនេះ បានរក្សា ទុកនៅមន្ទីរពិសោធន៍ NAMRU II ដើម្បីធ្វើតេស្តនាពេល ខាងមុខ។



សកម្មភាពនៃការប្រមូលសេរ៉ូម និងឈាមដើម្បីវិភាគ

**ការធ្វើតេស្តសំណាកសត្វព្រៃដែលប្រមូលបាននៅវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ និងបសុព្យាបាល នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ** នៅរាជធានីភ្នំពេញ និងសំណាកសេរ៉ូម និងឈាម (មនុស្ស) នៅមន្ទីរពិសោធន៍ NAHPRI រួមមាន៖ ការរៀបចំធ្វើការបំបែកជាលិកាសំណាកពីសួត លំពែង និងក្រលៀន (តំរងនោម) ចំនួន១១២៣ សំណាក (RNA/DNA Extraction) និងការធ្វើតេស្ត PCR from RNA to cDNA ចំនួន១១១០ សំណាក ពីជាលិកា សួត លំពែង និងក្រលៀន (តំរងនោម) និង ២៧៣៦សំណាក ពីតម្បាររន្ធគូថ (rectal swabs)។ ការធ្វើ DNA Extraction ១១០៩សំណាក ពីជាលិកាសួត លំពែង និងក្រលៀន (តំរងនោម) និង ៨៧២សំណាក ពី blood samples។ ការធ្វើ PCR តេស្តទទួលបានលទ្ធផលដូចខាងក្រោម៖

– PCR Testing for Arenavirus: ៣៤៦ សំណាក (សំណាកទាំងអស់អវិជ្ជមាន)

– PCR Testing for Bartonella: ២៣០១សំណាក (២៤០សំណាកវិជ្ជមាន)

– PCR Testing for Coronavirus: ៣២៩០សំណាក (២៣៧សំណាកវិជ្ជមាន)

– PCR Testing for Paramyxovirus:១១២៨សំណាក (៣៩៥សំណាកវិជ្ជមាន)

– PCR Testing for Barcoding: 1530 samples and continue with sequencing for confirmation of the results ។




កិច្ចប្រជុំប្រចាំឆ្នាំរបស់គម្រោងសិក្សាតាមដានហានិភ័យនៃការចម្លងជំងឺមកមនុស្ស ពីប៉ារ៉ាស៊ីតរបស់ពពួកថនិកសត្វតូចៗ និងសត្វប្រចៀវ ដោយមានការចូលរួមមកពីរដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សាកលវិទ្យាល័យ សឹង្ហបុរី វិទ្យាស្ថានជាតិសុខភាពសាធារណៈ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ កម្មវិធី CBEP, DTRA NAMRU2 អង្គការ FFI, FAO, WHO សរុបចំនួន៥១នាក់ ក្នុងនោះមានស្ត្រីចំនួន១៨នាក់

**ផែនការសកម្មភាពឆ្នាំ២០២០ ផ្ដោតលើៈ**

-ចុះប្រមូលសំណាកសត្វប្រចៀវ ជ្រីង និងថនិកសត្វតូចៗដើម្បីយកសំណាក (ឈាម ទឹកមាត់ លាមក និងជាលិកា) នៅគោលដៅចំនួន ៧០ ក្នុងខេត្តចំនួន ១០

-ចុះយកសំណាកសេរ៉ូម និងឈាម (មនុស្ស) ពីប្រជាជនសហគមន៍មូលដ្ឋាន ជាពិសេសផ្ដោតលើអ្នកប្រមូលលាមកសត្វប្រចៀវសម្រាប់លក់ អ្នកចាប់សត្វកណ្ដុរ និងអ្នកលក់សត្វកណ្ដុរ នៅក្នុងខេត្តចំនួន ៥

-ធ្វើការវិភាគស្ដីអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត (Knowledge Attitude Practice) ក្នុងខេត្តចំនួន ៧ អំពីចំណេះដឹង ឥរិយាបថ និងការអនុវត្តលើការការពារជំងឺឆ្លងពីសត្វមកមនុស្ស(Zoonosis)តាមរយៈការជួញដូរ និងការប្រើប្រាស់សត្វព្រៃ

-ធ្វើតេស្តសំណាកសត្វព្រៃដែលប្រមូលបាននៅវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ និងបសុព្យាបាលនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វនៅរាជធានីភ្នំពេញ និងធ្វើការវិភាគសំណាកសេរ៉ូម និងឈាម (មនុស្ស) នៅមន្ទីរពិសោធន៍ NAMRU II

-រៀបចំសៀវភៅមគ្គុទេសក៍សម្រាប់កំណត់អត្តសញ្ញាណសត្វប្រចៀវ ជ្រីង និងថនិកសត្វតូចៗនៅកម្ពុជា

-រៀបចំឯកសារសម្រាប់ការស្នើដាក់បញ្ចូលនូវប្រភេទសត្វប្រចៀវ ជ្រីង និងថនិកសត្វតូចៗដែលបានរកឃើញ និងកត់ត្រាថ្មីនៅប្រទេសកម្ពុជាចូលក្នុងប្រកាសស្ដីពី ចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃនៅកម្ពុជា (សម្រាប់ក្រុមប្រភេទមានដោយបង្គួរ)។

-Probabilistic Sampling Sites: ទីតាំងចុះប្រមូលសំណាកសត្វប្រចៀវ ជ្រីង និងថនិកសត្វតូចៗ ដើម្បី យកសំណាក (ឈាម ទឹកមាត់ លាមក និងជាលិកា)

-KAP Survey Sites: ទីតាំងចុះសម្ភាសន៍ ស្ដីអំពីចំណេះដឹង ឥរិយាបទ និងការអនុវត្ត (Knowledge Attitude Practice-)លើការការពារជំងឺឆ្លងពីសត្វមកមនុស្ស(Zoonosis) តាមរយៈការជួញដូរ និងការប្រើប្រាស់សត្វព្រៃ

-Human Sera Sampling Sites: ទីតាំងចុះប្រមូលសំណាកសេរ៉ូម និងឈាម (មនុស្ស) ពីប្រជាជនសហគមន៍មូលដ្ឋានជាពិសេសផ្ដោតលើអ្នកប្រមូលលាមកសត្វប្រចៀវសម្រាប់លក់អ្នកចាប់-លក់សត្វកណ្ដុរ៕



ដោយ **ឃៀង អៀងគិច** ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ

### ☺ មិនស្ដាប់ឲ្យចប់សិន

នាព្រលប់មួយ មីងចែម ដែលមានមាឌខាំង និងកាចអស្ចារ្យម្នាក់ ក្រោយពីចម្អិនអាហាររួច មើលម៉ោងឃើញថាយប់ណាស់ ហើយមិនទាន់ឃើញប្ដីរបស់គាត់មកដល់ផ្ទះដើម្បីហូបបាយជុំគ្រួសារ ក៏ក្ដៅចិត្ត ហើយបានប្រើអាច្រូចដែលជាកូនប្រុស ឲ្យយកទូរស័ព្ទគាត់ខលហៅឪវាមកហូបបាយ។

បន្តិចក្រោយមកអាច្រូច បានស្រែកប្រាប់ម៉ាក់វាថា *"ម៉ាក់ៗ មានសម្លេងមនុស្សស្រីឆ្លើយក្នុងទូរស័ព្ទថា ..."* ទើបតែនិយាយដល់ត្រឹមនេះមីងចែមស្រែកកាត់កូនថា *"បានហើយម៉ាក់ស្គាល់ហើយស្រីនោះ ឈប់និយាយនាំក្ដៅចិត្តទេ!..."* មួយសន្ទុះក្រោយមក ពូចក់ជាប្ដីបានមកដល់។ មិនបង្អង់យូរ មីងចែមបានប្រើកណ្ដាប់ដៃហោះផាច់ៗ ធ្វើឲ្យពូចក់ដាច់ថ្ងារ ផ្អើលដល់អ្នកជិតខាងរោមមើលជុំជិត។ មីងចែមបានស្រែកឲ្យអាច្រូចនិយាយភស្ដុតាងទាំងអស់ឲ្យអ្នកជិតខាងបានស្ដាប់ផង ថាតើសម្លេងស្រីក្នុងទូរស័ព្ទពេលខលទៅប៉ាវានោះ ថាម៉េចខ្លះ!? ពេលនោះច្រូចនៅស្ទាក់ស្ទើរមិនចង់ហ៊ាននិយាយ តែខ្លាចម៉ាក់វា វាក៏និយាយខ្លាំងៗឡើងថា *"សម្លេងស្រី នោះនិយាយថា ទូរស័ព្ទលោកអ្នកពុំមានទឹកប្រាក់គ្រប់គ្រាន់ក្នុងការហៅចេញបានទេ!..."*

**មីងចែម៖** *ហាក!!! ចឹងទេ?*

(អំពើហិង្សាក្នុងគ្រួសារ ជាអំពើល្មើសច្បាប់...)

### ☺ ថ្នាំផ្ដាច់ស្រា

នាង ភីម ដោយទ្រាំនឹងភាពប្រមឹកស្រវឹងខូបរបស់ប្ដីលែងបាន ក៏ទៅពិគ្រោះជាមួយគ្រូពេទ្យជំនាញ...។

**គ្រូពេទ្យ៖** មានវិធីព្យាបាលដ៏ល្អមួយ គឺអ្នកស្រីត្រូវយកពែងកាហ្វេមកចាក់ស្រាលាយកាហ្វេឲ្យប្ដីអ្នកស្រីផឹករៀងរាល់ព្រឹក-ល្ងាច ធ្វើបែបនេះប្រាកដណាស់ប្ដីលោកស្រីច្បាស់ជាអាចផ្ដាច់ស្រា បែរមកផឹកកាហ្វេជំនួសវិញមិនខានឡើយ។

*មួយខែក្រោយមកនាងភីមបានទៅជួបគ្រូពេទ្យ ....*

**គ្រូពេទ្យ៖** អ្នកស្រីបានធ្វើតាមការណែនាំរបស់ខ្ញុំ ហើយបានលទ្ធផលម៉េចដែរ?

**នាងភីម៖** ចាស គឺប្ដីខ្ញុំ បែរជាឈប់ផឹកកាហ្វេ ហើយមកផឹកស្រាទាំងព្រឹក ទាំងល្ងាចតែម្ដង។

**គ្រូពេទ្យ៖** អុញ!!! ...

### ☺ សុខភាពនៅដដែល

តាសុខ និង តាសៅ បានអង្គុយសំណេះសំណាលគ្នានៅសួនច្បារមាត់ទន្លេ។

**តាសុខ៖** សុខភាពរបស់ខ្ញុំ កាន់តែធ្លាក់ពីមួយថ្ងៃ ទៅមួយថ្ងៃ ដែលកាលពីក្មេងដើររាប់សិបគីឡូម៉ែត្រ អត់ទាន់ហត់ទេ តែសព្វថ្ងៃដើរត្រឹមពីរ បី គីឡូម៉ែត្រហត់សឹងដកដង្ហើមមិនដល់គ្នាទៅហើយ។

**តាសៅ៖** ទេ! ចំណែកខ្ញុំវិញគឺនៅដដែល។

**តាសុខ៖** អូ! ធ្វើម៉េចបាននៅដដែលផ្ដល់បទពិសោធន៍ផង

**តាសៅ៖** គឺពុំមានធ្វើអីពិសេសទេ តែវាជាអំណោយផលពីធម្មជាតិតើ គឺថា កាលពីខ្ញុំអាយុជាង ២០ឆ្នាំនោះ បាវអង្ករទម្ងន់ត្រឹម ៥០គីឡូក្រាម ខ្ញុំលីអត់រួចទេ ហើយឥឡូវ នៅតែលីអត់រួចដដែល។

### ☺ ជើងខ្លាំង

បុរសម្នាក់បានជិះរថយន្តរបស់ខ្លួនចូលក្នុងកន្លែងផឹកស៊ីមួយ ដោយមិនបានដឹងថាទីនោះគឺជាកន្លែងដែលសម្បូរចោរនោះឡើយ។ បន្ទាប់ពីផឹករួចចេញមកដល់ខាងក្រៅស្រាប់តែបាត់រថយន្ត មិនដឹងជាអ្នកណាលួចបាត់ ខឹងណាស់បុរសរូបនោះ ដើរចូលទៅក្នុងហាងផឹកស៊ីវិញ រួចស្រែកសន្ធាប់ខ្លាំងៗ ព្រមទាំងគំរាមថា បើមិនយកឡានឲ្យវិញ ប្រយ័ត្នអញធ្វើដូចនៅស្រុកអញវើយ! កាលនោះអញផឹកថែមមួយកំប៉ុងទៀត ហើយអ្វីៗគឺត្រូវចប់ ! ឥឡូវអញផឹកថែមដែរ...។

បន្ទាប់មកបុរសនោះបានចេញមកខាងក្រៅហាងស្រាប់តែឃើញឡានវិញ។ ហៀបនឹងចេញទៅវិញហើយស្រាប់តែអ្នកបម្រើក្នុងហាងសួរបុរសនោះថា កាលនៅស្រុកលោកមានរឿងចឹង តើលោកធ្វើម៉េច? បុរសជើងខ្លាំងឆ្លើយវិញថា មានម៉េចកាលណោះ ខ្ញុំជិះម៉ូតូឌុបទៅផ្ទះវិញតើ !




# កង្វល់ម្រឹគព្រៃ

**បទពាក្យប្រាំពីរ**

ដោយលោក៖ **អ៊ូ វណ្ណារ៉េត** រដ្ឋបាលព្រៃឈើ

សូរិយាចែងចាំងពាសឥស្ថា
សប្បាយអឹងកងលើបុព្វតា
សហាសវត្សទំនើបថ្មី
ល្អនចតុប្បាទជួបអំពល់
សត្វព្រៃតូចធំគ្រប់សន្តាន
គឺមនុស្សអប្រិយចូលអុកឡុក
បរបាញ់ឆក់ទាក់កាប់សម្លាប់
ទ្រូងចុកពើតផ្សាស្មើរបែកធ្លាយ
ចាបចៀបចាបពួកចាបព្រៃរ៉ែង
រៀបរាប់ប្រាប់គ្នាជាទំលាប់
មនុស្សយកពួកគេទៅធ្វើម្ហូប
រៀបចំសម្លាប់គេឲ្យចមុន
ខ្លែងស្រាកប្រវឹកស្ទាំងប្រវ៉ែក
ស្មោញរំពេកុកពាក់អំប្រោះ
សត្វខ្វែកប្រឹងស្រែកប្រាប់សត្វទៀវ
ពិតាក្សាគ្នារួមជាក្រុម
ដោះស្រាយយ៉ាងណាឲ្យរួចភ័យ
ប្រមូលគ្នីគ្នារួមប្រជុំ
ពពិចស្រែកប្រាប់ទៅល្វាចេក
ប្រាប់ជាដំណឹងសត្វទាំងឡាយ
ក្រោយពីទទួលបានដំណឹង
ចាត់ចែងចចាររឿងទុក្ខធំ
សឹង្ហសត្វអារកាត់លើកសេចក្ដី
បានជាប្រជុំម្រឹគគ្រប់គ្នា

បក្សីម្រឹគាស្រែកខ្សៀវខ្សារ
ក្នុងព្រៃព្រឹក្សាគ្មានកង្វល់ៗ
បក្សាម្រឹគព្រៃចលាចល
ខ្វះង្គស្គាល់យល់តែកលិយុគៗ
ជួបភ័យវិនាសកើតក្ដីទុក្ខ
បំផ្លាញក្ដីសុខតាពសប្បាយៗ
រុករានចងចាប់បង្ខាំងវាយ
វាចារាយមាយចង់តែស្លាប់ៗ
លលកប្រជែងពោលរ៉ាយរ៉ាប់
ពីរឿងក្ដីស្លាប់ទុក្ខទារុណៗ
ចាបមាសចាកលោករងទុក្ខធ្ងន់
ឈឺផ្សាពេកពន់ឲ្យចទាំងរស់ៗ
តាវ៉ៅកុកក្អែកខ្សឹបព្រាបកោះ
ត្រចៀកកាំកោះត្រដក់ធំៗ
គួរអំពាវនាវគ្នាមកជុំ
បើកអង្គជំនុំរើសមេធំៗ
ពួកសត្វបក្សីល្អនម្រឹគធំ
ចតុប្បាទខ្វះង្គជួយដោះស្រាយៗ
ទៅប្រើសត្វសេកឲ្យទៅឆ្វាយ
នៅជិតនៅអាយមកប្រជុំៗ
មកទាំងសត្វសឹង្ហម្រឹគកកកុំ
បើកអង្គជំនុំពិភាក្សាៗ
ឲ្យសត្វដំរីប្រាប់ហេតុការណ៍
ត្បិតយើងម្រឹគាជួបទុក្ខភ័យៗ








(នៅមានត)



